សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ចមេធាវី
# នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **អ៊ុង សុគន្ធកញ្ញា**
លោក **អ៊ឹង គីមហុក**

សាស្ត្រាចារ្យណែនាំ
**លោក ជួន ចុំនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១៨
ជំនាន់ទី ២២ ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **អ៊ុង សុគន្ធកញ្ញា** និង **អ៊ឹង គីមហុក** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០២២ ជំនាន់ទី ២២។

## **យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

**លោកឪពុក** និង **អ្នកម្តាយ** ជាទីគោរព ដែលលោកទាំងពីរមាននូវមហាឧបការគុណដ៏ឧត្តុមឧត្តម និងធំធេងបំផុត គ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណបានផ្តល់នូវ កំណើតចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅដល់រូបកូន ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូន ចាប់តាំងពីថ្ងៃដែលកូននៅក្នុងផ្ទៃម្តាយរហូតដល់ពេញវ័យ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ លោកអ្នកមានគុណ ទាំងពីរបានអប់រំ ណែនាំ ទូន្មានប្រៀនប្រដៅកូនឱ្យចេះដឹងល្អខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម ដែលពោរពេញទៅដោយចិត្តមេត្តា សណ្តោះប្រណីដល់រូបកូនទាំងពីរ ព្រមទាំងលោកទាំងពីរបានជំរុញទឹកចិត្ត ឱ្យកូនខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ដោយបានបញ្ជូនកូនទៅរៀននៅសាលារៀន ព្រមទាំងឧបត្ថម្ភកូន គ្រប់បែបយ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត និងសម្ភារៈរហូតដល់កូនបានបញ្ចប់ការសិក្សានេះដោយទទួលបាន ជោគជ័យ។ សូមជូនពរលោកទាំងពីរ ដែលជាអ្នកមានគុណ មានសុខភាពល្អ អាយុយឺនយូរ ជៀសផុតពីជម្ងឺ។

យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបាន ខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង បង្ហាត់បង្រៀន និងចែករំលែក ចំណេះដឹងជូនសិស្សនិស្សិតកន្លងមក។

សូមថ្លែងអំណរគុណ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យដឹកនាំ ដោយបានខិតខំ ប្រឹងប្រែងយកចិត្តទុកដាក់ និងផ្តល់ជាគំនិតក្នុងការជួយ ដោយអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ គ្រប់គ្រងជួយសម្រួលយ៉ាងចិត្តទុកដាក់រហូតធ្វើសារណានេះបានលេចចេញជារូបរាង។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិត ដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្តែងសេចក្តីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណ ដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរ ជាពិសេសសូមប្រសិទ្ធពរជ័យសិរីសួស្តី វិបុល សុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានការជោគជ័យគ្រប់ភារ កិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់ក្នុងដៃនេះ គឺជាវណ្ណៈកម្មរបស់ក្រុមយើងខ្ញុំជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្រុមយើងខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវឡើយ ដើម្បីទុកជាស្នាដៃសម្រាប់លោកអ្នក ក្រុមយើងខ្ញុំបានព្យាយាមស្រាវជ្រាវនេះឡើង គឺក្រុមយើងខ្ញុំបានសម្រេចចិត្ត ក្នុងការជ្រើសរើសយកការសរសេរសារណាបញ្ចប់ការសិក្សា ជំនួសការប្រឡងចេញវិញ។ សៀវភៅ ជាក្បួនច្បាប់ផ្សេងៗ ផ្នែកសីលធម៌នៅក្នុងសង្គមរបស់កម្ពុជាយើងបានបាត់បង់នៅពេលប្រទេសយើងជួបបញ្ហាសង្គ្រាម និងជួបវិបត្តិផ្សេងៗ។ ការសរសេរសារណាយើងខ្ញុំបានខិតខំសិក្សា ស្រាវជ្រាវសរសេរឡើង ជាសមិទ្ធិផលមួយក្នុងការចែករំលែកចំណេះដឹង។ ក្រុមយើងខ្ញុំមានកាលានុវត្តភាព ជួបជាមួយអស់លោកអ្នក តាមរយៈសំណេររបស់ក្រុមយើងខ្ញុំ ទុកជាស្នាដៃសម្រាប់លោកអ្នកអានក្នុងសហស្សវត្សថ្មីនេះ។ ហើយម្យ៉ាងទៀត កម្រងឯកសារដែលបានលើកឡើងក្នុងអត្ថបទ ដែលមិត្តនិស្សិត លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ កំពុងតែអាននេះនៅក្នុងដៃ។

យើងខ្ញុំបានជ្រើសរើសប្រធានបទ **តួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ** នេះឡើង ពីព្រោះយើងខ្ញុំបានសិក្សាស្រាវជ្រាវ ដោយមានការយកចិត្តទុកដាក់ និងមានចិត្តចង់យល់ចង់ដឹងបន្ថែមអំពីតួនាទី និងភារកិច្ចរបស់មេធាវី ដើម្បីទុកជាស្នាដៃ ដែលមានការព្យាយាមការសរសេរពីក្រុមយើងខ្ញុំ ដើម្បីទុកឱ្យប្អូនៗជំនាន់ក្រោយបានធ្វើការសិក្សាបន្ថែមសម្រាប់ការរៀនសូត្រ។ យើងខ្ញុំក៏សង្ឃឹមថា នៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សា យើងខ្ញុំបានពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយ ក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗដោយជាអចេតនាពុំខាន។ ការចងក្រងឡើងនូវពាក្យពេចន៍ សម្ដីសំដៅ អត្ថបទប្រាកដជាមានការឆ្គាំឆ្គងឃ្លៀងឃ្លាតជាមិនខាន ដូចជាមានសុភាសិតមួយបានពោលថា ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច។ ដូច្នេះយើងខ្ញុំសូមអភ័យទោសពីសំណាក់អ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រចារ្យ ដោយការគោរពស្មោះត្រង់ពីក្រុមយើងខ្ញុំនូវរាល់កំហុសខុសឆ្គងទាំងឡាយណាដែលអាចកើតចេញដោយអចេតនាក្ដី និងសូមខន្តីអភ័យទោស ដោយគោរពហើយយើងខ្ញុំទទួលស្វាគមន៍ក្នុងការរិះគន់បែបស្ថាបនាដើម្បីកែលម្អបន្ថែមនូវមតិយោបល់ដើម្បីទទួលបាននូវកិច្ចការសារណាបញ្ចប់ការសិក្សានេះមួយដែលល្អ។

ជាចុងក្រោយយើងខ្ញុំជានិស្សិតនីតិសាស្ត្រ ជំនាន់ទី២២ ឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំមានចិត្តសប្បាយរីករាយក្ដីក្នុងការយកប្រធានបទនេះក្នុងការសិក្សាស្រាវជ្រាវឡើង ដើម្បីជាចំណងដៃសម្រាប់សាលា មិត្តអ្នកអាន និងខ្លួនឯងផ្ទាល់។ ហើយក្រុមយើងខ្ញុំសូមប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ សិស្សនិស្សិត សាស្ត្រចារ្យ ជួបប្រទះនូវពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ.......................................................................... ១

២. ចំណោទបញ្ហានៃការដោះស្រាយ .......................................................................... ២

៣. គោលបំណងនៃការស្រាវជ្រាវ.......................................................................... ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......................................................................... ៤

៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ.......................................................................... ៤

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ .......................................................................... ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......................................................................... ៥


## ជំពូកទី១

## សញ្ញាណទូទៅរបស់មេធាវីនៃព្រះរាជាណាចក្រកម្ពុជា


**១.១. ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី** .......................................................................... ៦

**១.២. នីតិវិធីការចូលប្រកបវិជ្ជាជីវៈមេធាវី** .......................................................................... ៨

១.២.១. តាមរយៈការប្រឡង.......................................................................... ៨

១.២.១.១. លក្ខខណ្ឌ .......................................................................... ៨

១.២.១.២. ការប្រឡង.......................................................................... ៨

១.២.១.៣. ការចុះកម្មសិក្សា .......................................................................... ៨

១.២.២. តាមរយៈការស្នើសុំ.......................................................................... ៩

១.២.២.១. លក្ខខណ្ឌ.......................................................................... ៩

១.២.២.២ ការដាក់ស្នើសុំ.......................................................................... ៩

១.២.២.៣ ការដាក់ពាក្យធ្វើកម្មសិក្សា .......................................................................... ១០


## ជំពូកទី២

## តួនាទី និងភារកិច្ចរបស់មេធាវី


**២.១. តួនាទីមេធាវី និងការទទួលខុសត្រូវរបស់មេធាវី** .......................................................................... ១១

២.១.១. កាតព្វកិច្ចគោរពនូវការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ .......................................................................... ១១

២.១.២. ទំនួលខុសត្រូវចំពោះអតិថិជន ........ ១១
២.១.២.១. ភាពស្មោះត្រង់ក្នុងការបំពេញបេសកម្មជូនអតិថិជន ........ ១១
២.១.២.២. កាតព្វកិច្ចរបស់មេធាវីចំពោះអតិថិជន ........ ១២
២.១. ២.៣. ទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងទណ្ឌកម្មវិន័យ ........ ១៣
**២.២. តួនាទីមេធាវីក្នុងការទាក់ទង និងការប្រកបវិជ្ជាជីវៈ** ........ ១៣
**២.៣. តួនាទីរបស់មេធាវីក្នុងការផ្តល់ប្រឹក្សាផ្នែកច្បាប់** ........ ១៤
២.៣.១. ការប្រឹក្សាយោបល់ក្នុងវិស័យគតិយុត្តិ ........ ១៤
២.៣.២. ការការពារកូនក្តី ........ ១៤
២.៣.៣. តាក់តែង និងចងក្រងលិខិតគតិយុត្តិ ........ ១៤
២.៣.៤ មេធាវីអ្នកសម្របសម្រួល និងអាជ្ញាកណ្តាល ........ ១៥
២.៣.៥. ការតំណាងជូនកូនក្តី ........ ១៥
២.៣.៦. ការបង់វិភាគទាន ........ ១៦
**២.៤. ទំនាក់ទំនងរបស់មេធាវី និងបុគ្គលផ្សេងទៀត** ........ ១៧
២.៤.១. ទំនាក់ទំនងជាមួយអតិថិជន ........ ១៧
២.៤.២. ទំនាក់ទំនងជាមួយអតិថិជនច្រើនគ្នា ........ ១៧
២.៤.៣. ទំនាក់ទំនងជាមួយអតីត អតិថិជន ........ ១៧
២.៤.៤. ទំនាក់ទំនងអតិថិជនជាប់ឃុំ ........ ១៨
២.៤.៥. ទំនាក់ទំនងជាមួយភាគីម្ខាងទៀត និងសាក្សី ........ ១៨
**២.៥. ទំនាក់ទំនងជាមួយតុលាការ** ........ ១៨
២.៥.១. ទំនាក់ទំនងជាមួយចៅក្រម ........ ១៨
២.៥.២. ទំនាក់ទំនងជាមួយព្រះរាជអាជ្ញា ........ ១៩
២.៥.៣. ទំនាក់ទំនងជាមួយក្រឡាបញ្ជី ........ ១៩
២.៥.៤ ទំនាក់ទំនងជាមួយសហភាតា នៃសមាជិកនៃវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា ........ ២០
២.៥.៥ ទំនាក់ទំនងជាមួយគណៈមេធាវី ........ ២០
**ជំពូកទី៣**
**តួនាទីសំខាន់ៗរបស់មេធាវីក្នុងដំណាក់កាលនៃនីតិវិធី**

**៣.១. ដំណាក់កាលស៊ើបអង្កេតដោយនគរបាលយុត្តិធម៌** ....................................... ២១
៣.១.១. តួនាទីមេធាវីក្នុងការស៊ើបអង្កេតជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌................................ ២២
៣.១.២. តួនាទីមេធាវីក្នុងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌ .................................... ២២
៣.១.៣. សិទ្ធិទទួលបានមេធាវីរបស់ជនសង្ស័យ ........................................................................ ២៤
៣.១.៣.១. ចំពោះបទឧក្រិដ្ឋ ............................................................................................ ២៦
៣.១.៣.២. ចំពោះបទមជ្ឈិម ............................................................................................ ២៦
**៣.២. ដំណាក់កាលចោទប្រកាន់ដោយព្រះរាជអាជ្ញា** ........................................................ ២៦
៣.២.១. ការប្តឹងទៅយុត្តាធិការស៊ើបសួរតាមរយៈ(ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)..................... ២៧
៣.២.២. វត្តមានមេធាវីក្នុងពេលស្តាប់ចម្លើយ............................................................................ ២៧
**៣.៣. ដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរ** ......................................................... ២៨
៣.៣.១. កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ........................................................................... ២៩
៣.៣.១.១. វត្តមានមេធាវីក្នុងពេលសួរចម្លើយរបស់ជនត្រូវចោទ ................................................ ២៩
៣.៣.១.២. វត្តមានមេធាវីពេលស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..................................... ២៩
៣.៣.១.៣. ការស្តាប់ចម្លើយសាក្សី ..................................................................................... ៣០
៣.៣.១.៤. ការធ្វើកោសលវិច័យ........................................................................................ ៣១
៣.៣.១.៥ ការស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌................................................................ ៣១
៣.៣.២. វិធានការនិវន្តរាយ................................................................................................ ៣២
៣.៣.២.១. ការឃុំខ្លួនបណ្តោះអាសន្ន..................................................................................... ៣២
៣.៣.២.២ ជំនួយមេធាវីក្នុងការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ.............................................. ៣៤
៣.៣.២.៣. ការកោះហៅ និងជូនដំណឹងដល់មេធាវី ................................................................ ៣៤
៣.៣.២.៤. បណ្តឹងសុំកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ............................................ ៣៥
៣.៣.២.៥ ការស្នើសុំឱ្យបំពេញកិច្ចដោយមេធាវី ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី.................... ៣៦
៣.៣.៣. ការបិទការស៊ើបសួរ ............................................................................................. ៣៦
៣.៣.៤. ការប្តឹងអំពីសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ......................................................... ៣៧
៣.៣.៤.១. មោឃភាពនៃការស៊ើបសួរ ................................................................................ ៣៨
៣.៣.៤.២. បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ........................................................ ៣៩
**៣.៤. ដំណាក់កាលជំនុំជម្រះ** ........................................................................................ ៤០

៣.៤.១. នីតិវិធីមុនពេលសវនាការ ........ ៤១
៣.៤.១.១. នីតិវិធីនៃការសម្រេចមុនអង្គសេចក្តី ........ ៤១
៣.៤.១.២. ជំនួយរបស់មេធាវី ........ ៤១
៣.៤.១.៣. សមាសភាពក្នុងអង្គសវនាការ ........ ៤២
៣.៤.១.៤. វាក្យស័ព្ទដែលប្រើចំពោះជនប្រព្រឹត្តបទល្មើសតាមដំណាក់កាលនីតិវិធី ........ ៤២
៣.៤.១.៥. ដំណើរការកិច្ចនីតិវិធីក្នុងពេលសវនាការ ........ ៤២
៣.៤.២. ការពិភាក្សាដេញដោល ........ ៤៣
៣.៤.៣. ការបង្ហាញភស្តុតាង ........ ៤៤
៣.៤.៣.១. ចំពោះមេធាវីការពារជនជាប់ចោទ ........ ៤៤
៣.៤.៣.២. ការសន្និដ្ឋានការពារក្តីរបស់មេធាវី ........ ៤៤
៣.៤.៣.៣. សិទ្ធិ និងឆន្ទានុសិទ្ធិក្នុងការបញ្ចេញមតិក្នុងសវនាការ ........ ៤៥
៣.៤.៣.៤. ការសុំបន្ធូរបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៤៦
៣.៤.៣.៥. ការសុំឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៤៧
**៣.៥ ដំណាក់កាល និងនីតិវិធីក្រោយពេលជំនុំជម្រះ** ........ ៤៩
៣.៥.១. សេចក្តីសម្រេច ឬសាលក្រម ........ ៤៩
៣.៥.១.១. ការប្រកាសសាលក្រម ........ ៤៩
៣.៥.១.២. បណ្តឹងទាស់ ........ ៤៩
៣.៥.១.៣. បណ្តឹងឧទ្ធរណ៍ ........ ៥០
៣.៥.១.៤. បណ្តឹងសារទុក្ខ ........ ៥១
៣.៥.១.៥. បណ្តឹងសើរើ ........ ៥១
**សេចក្តីសន្និដ្ឋាន** ........ ៥៣
**អនុសាសន៍** ........ ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

វិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងមុនឆ្នាំ១៩៧៥។ ការបង្កើតនូវវិជ្ជាជីវៈស្មាក្តី ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៣២។ ហើយវិជ្ជាជីវៈនេះត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបសាធារណៈខ្មែរត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យផ្តួលរំលំ។ កាលនោះគេមិនបានហៅវិជ្ជាជីវៈនោះថាមេធាវីនោះទេគឺគេហៅថា "វិជ្ជាជីវៈស្មាក្តី" ដែលអ្នកប្រកបរបបនេះគេហៅថា "អ្នកថណាយក្តី"។ ក្រោយពីឆ្នាំ១៩៧៩ វិជ្ជាជីវៈនេះ ត្រូវបានកកើតឡើងវិញដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតឡើងដំបូងតាមរយៈមហាសន្និបាតរបស់គណៈមេធាវីដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ ដោយមានសមាជិកចំនួន ៣៣នាក់ ដែលបានស្បថចូលប្រកបវិជ្ជាជីវៈមេធាវីមុនគេ។ វិជ្ជាជីវៈមួយនេះបានកើតឡើងវិញជាផ្លូវការរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នមួយក្នុងការគ្រប់គ្រង ដោយអនុលោមទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីក្នុងឆ្នាំ១៩៩៥។ ក្រោយមកទៀត វិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីចំនួន២ផ្សេងៗទៀត ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីឆ្នាំ១៩៩៥ គឺមានក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី។

ព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងទៅលើគ្រប់វិស័យ ដែលនៅក្នុងនោះមានការរីកចម្រើនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានទាំងវិស័យយុត្តិធម៌ ទើបធ្វើឱ្យវិជ្ជាជីវៈមេធាវីមានការរីកចម្រើនខ្លាំង។ ដើម្បីធានាបាននូវភាពយុត្តិធម៌នៅក្នុងសង្គម របៀបរៀបរយនៃការប្រកបវិជ្ជាជីវៈដែលទទួលបានសេចក្តីថ្លៃថ្នូរ ឯករាជ្យ សេរីភាពនៃវិជ្ជាជីវៈ និងទទួលបាននូវទំនុកចិត្តពីអតិថិជន គណៈមេធាវីបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០១២។ លើសពីនេះទៅទៀត ក្រុមប្រឹក្សានៃគណៈមេធាវី បានធ្វើការអនុម័តលើសេចក្តីសម្រេចដាក់ឱ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យ និងមានការសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃលក្ខន្តិកៈមេធាវីនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ដើម្បីធ្វើការកំណត់ឱ្យបានច្បាស់លាស់ពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំចូលប្រកប វិជ្ជាជីវៈមេធាវីដោយមិនមានការឆ្លងកាត់ការប្រឡងនោះទេ។

មេធាវីដើរតួនាទីយ៉ាងសំខាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌ ដើម្បីការពារដើមចោទ និងចុងចម្លើយ។ មេធាវីជាអ្នកតំណាងដ៏សំខាន់ ជាពិសេសនៅក្នុងនីតិវិធីព្រហ្មទណ្ឌនេះ យើងខ្ញុំបានលើកយកប្រធានបទពីតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌមកធ្វើការសិក្សាស្រាវជ្រាវ។ ជាក់ស្តែងនៅក្នុងសង្គមបច្ចុប្បន្ននេះ តែងតែមានការកើតឡើងនៅរឿងក្តីព្រហ្មទណ្ឌ ដែលមានការបង្កឱ្យមានព្យសនកម្ម ធ្វើឱ្យខូចខាតនៅក្នុងសង្គម និងបង្កឱ្យមានគ្រោះថ្នាក់ទៅដល់អ្នកដ៏ទៃ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត សម្ភារៈ និងប្រយោជន៍សាធារណៈ ដែលជា

ហេតុបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវការមេធាវីក្នុងការការពារសិទ្ធិជាចាំបាច់ និងពិភាក្សាយោបល់ផ្នែកច្បាប់ដោយមានមេធាវីជាអ្នកប្រឹក្សាយោបល់។ មេធាវីពិតជាដើរតួនាទីយ៉ាងសំខាន់ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដោយសារតែជាប្រយោជន៍ដល់សាធារណៈ ដែលមានស្ថាប័នអយ្យការជាម្ចាស់បណ្តឹងអាជ្ញា ហើយអាចសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសណាមួយ។ មេធាវីមានតួនាទីការពារកូនក្តីរបស់ខ្លួនឱ្យរួចផុតពីបទល្មើស ឬការចោទប្រកាន់ការរំលោភបំពានលើរូបកាយ។ ជាពិសេសអនីតិជន ដើម្បីជាប្រយោជន៍ដល់កូនក្តីរួមទាំងជួយសម្រួលដល់ដំណើរការប្រព្រឹត្តទៅនៃនីតិវិធីរបស់តុលាការ ព្រោះមេធាវីអាចចូលរួមបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌដើម្បីស្វែងរកនូវភស្តុតាងដែលជាប្រយោជន៍សម្រាប់កូនក្តីរបស់ខ្លួន។ លើសពីនេះទៅទៀតតម្រូវឱ្យមេធាវីការពារក្តី ត្រូវមានសមត្ថភាពខ្ពស់ដើម្បីការពារក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព។ ការស្រាវជ្រាវនេះយើងខ្ញុំបានធ្វើការសិក្សាអំពី តួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ នៅក្នុងនីតិវិធីបណ្តឹងព្រហ្មទណ្ឌ ដែលជាអ្នកការពារស្របច្បាប់ដល់កូនក្តីក្នុងដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ។ ជាមួយគ្នានេះផងដែរ សៀវភៅសារណាស្តីពីតួនាទី និងភារកិច្ចមេធាវីក្នុងរឿងក្តីព្រហ្មទណ្ឌនៅគ្រប់ដំណាក់កាលនៃនីតិវិធីនេះ ដែលយើងខ្ញុំជានិស្សិតច្បាប់បានខិតខំស្រាវជ្រាវយកមកសរសេរ ចងក្រងឡើងយ៉ាងក្បោះក្បាយដែលពាក់ព័ន្ធអំពីតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនៅគ្រប់ដំណាក់កាលនៃនីតិវិធីជាពិសេសមុខងារ តួនាទី ភារកិច្ច និងលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌។ នៅក្នុងការប្រកបវិជ្ជាជីវៈមេធាវីឱ្យស្របតាមនីតិវិធីច្បាប់ ដើម្បីមានភាពច្បាស់លាស់ និងមានភាពស៊ីជម្រៅលម្អិតអំពីនីតិវិធីនានាដែលទាក់ទងទៅនិង វិស័យយុត្តិធម៌មកបង្ហាញដល់សាធារណជន។ ជាថ្មីម្តងទៀតយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅសារណាដែលយើងខ្ញុំបានចងក្រងឡើងនេះដែលបានចូលរួមចំណែកយ៉ាងសកម្ម ដើម្បីជាប្រយោជន៍ដល់អ្នកអាន អ្នកសិក្សា សិស្សនិស្សិតជំនាន់ក្រោយ ទទួលចំណេះដឹងយ៉ាងច្រើនពីសារណានេះ ដើម្បីឱ្យកាន់តែលម្អិតច្បាស់អំពីប្រធានបទ និងស៊ីជម្រៅទៅលើអត្ថបទនៃការស្រាវជ្រាវ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ប្រសិនបើយើងក្រឡេកមើលអំពីលក្ខន្តិកៈដើម្បីប្រកបចូលវិជ្ជាជីវៈ ឬដើម្បីទទួលបានការងារជាមេធាវី។ វិជ្ជាជីវៈមេធាវីជាជំនាញមួយមានការគ្រប់គ្រងច្បាស់លាស់ និងដើម្បីចូលរួមបម្រើស្វែងរកយុត្តិធម៌។ នៅក្នុងវិស័យយុត្តិធម៌នៅកម្ពុជា និងធ្វើឱ្យដំណើរការនីតិវិធីជំនុំជម្រះក្តីមួយប្រកបទៅដោយតម្លាភាព សុក្រឹត្យភាពយុត្តិធម៌ និងលទ្ធផលមួយដែលអាចទទួលយកបាន។ ដូចនេះទើបមានសិស្ស និស្សិត អ្នកអាន អ្នកស្តាប់មានចម្ងល់បានចោទជាសំណួរសួរថា៖

- តើវិជ្ជាជីវៈមេធាវីមានតួនាទី និងភារកិច្ចអ្វីខ្លះនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ?
- តើវិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈដូចម្តេច?

- តើវិជ្ជាជីវៈមេធាវីបានចូលរួមអ្វីខ្លះនៅក្នុងវិស័យយុត្តិធម៌?
- តើដើម្បីពឹងពាក់មេធាវីបាន តើកូនក្តីត្រូវធ្វើអ្វីខ្លះ?
- តើមេធាវីអាចចូលរួមគ្រប់ដំណាក់កាលនីតិវិធីបានដែរឬទេ?
- តើមេធាវីអាចសំណូមពរ ឬការពារកូនក្តីរបស់ខ្លួនតាមវិធីសាស្ត្របែបណា?
- តើមេធាវីអាចសុំឱ្យកូនក្តីរបស់ខ្លួននៅក្រៅឃុំបានដែរឬទេ?
- តើមេធាវីអាចសុំស្លានសម្រាលទោសជូនកូនក្តីបានដែរឬទេ?
- តើមេធាវីអាចស្វែងរកភស្តុតាងជូនសាលាជម្រះក្តីបានដែរឬទេ?
- តើមេធាវីមានតួនាទីអ្វីខ្លះនៅពេលសវនាការ?
- តើមេធាវីមានភារកិច្ចអ្វីខ្លះបន្ទាប់ពីសវនាការជំនុំជម្រះរួច?
- តើកូនក្តីមកពឹងពាក់មេធាវីតើអស់ថ្លៃសេវាមេធាវីដែរឬទេ?
- តើគណៈមេធាវីអាចផ្តល់មេធាវីជូនជនក្រីក្របានដែរឬទេ?

ហេតុដូចនេះហើយទើបយើងខ្ញុំជាអ្នកស្រាវជ្រាវបានលើកយកនូវ ប្រធានបទ "តួនាទី និងភារកិច្ចមេធាវីក្នុងសំណុំរឿងព្រហ្មទណ្ឌ" មកបកស្រាយចម្ងល់ទាំងនេះ ដោយមានការផ្អែក និងយោងពីឯកសារច្បាប់ជាច្រើន ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី បទបញ្ជាផ្ទៃក្នុងមេធាវី និងឯកសារច្បាប់ជាច្រើនទៀត។

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវចំពោះប្រធានបទតួនាទី និងភារកិច្ចរបស់មេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌមួយនេះ បានធ្វើការសិក្សាស្រាវជ្រាវឡើងក្នុងគោលបំណងសិក្សាស្វែងយល់អំពី ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និងនីតិវិធីនៃការប្រកបវិជ្ជាជីវៈមេធាវី។

ជាពិសេសក្នុងការសិក្សាស្រាវជ្រាវនេះឡើង មានគោលបំណងក្នុងការបង្ហាញអំពីនីតិវិធីលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈ ការបើកការិយាល័យមេធាវី តួនាទី និងភារកិច្ចរបស់មេធាវីក្នុងសំណុំរឿងព្រហ្មទណ្ឌ ព្រមទាំងនីតិវិធីនានារបស់មេធាវីដែលត្រូវបំពេញដើម្បីស្វែងរកផលប្រយោជន៍ជូនកូនក្តី។

គោលគំនិតសំខាន់នៅក្នុងប្រធានបទពីតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ឱ្យយើងយល់ច្បាស់ពីតួនាទីមេធាវី បន្ទាប់ពីជំនុំជម្រះរួច និងការស្វែងរកភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកនានា និងការចូលរួមរបស់មេធាវីទៅតាមដំណាក់កាលនីតិវិធីផងដែរ។ ដើម្បីស្វែងយល់ច្បាស់ពីមេធាវី និងការចូលប្រកបវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ស្វែងយល់បន្ថែមពីតួនាទី និងភារកិច្ចក្នុងសំណុំរឿងព្រហ្មទណ្ឌ ការទទួលខុសត្រូវរបស់មេធាវីចំពោះកូនក្តី។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សារណានេះមានដែនកំណត់ និងវិសាលភាពគ្របដណ្តប់ទៅលើទិដ្ឋភាពច្បាប់ ក៏ដូចជាការអនុវត្តដែលទាក់ទងទៅនិងតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ដែលដើរតួយ៉ាងសំខាន់សម្រាប់ការពារជូនកូនក្តីនៅក្នុងរឿងព្រហ្មទណ្ឌ និងនីតិវិធីនានាដែលមេធាវីត្រូវបំពេញកាតព្វកិច្ចជូនកូនក្តី និងភារកិច្ចមេធាវីនៅក្រោយពេលជំនុំជម្រះ។

មួយវិញទៀតចំណែកទំហំនៃការសិក្សាស្រាវជ្រាវ គឺយើងបានលើកឡើងនូវតួនាទី និងភារកិច្ចរបស់មេធាវី ដែនកំណត់នៃការស្រាវជ្រាវពីប្រធានបទនេះ និងមានការចងក្រងសារណានេះឡើង មានវិសាលភាពក្នុងក្របខណ្ឌនៃច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ឯកសារផ្សេងៗដែលទាក់ទងទៅនឹងវិជ្ជាជីវៈមេធាវី។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

សារណានេះមានសារៈប្រយោជន៍ជាច្រើនចំពោះការសិក្សាស្រាវជ្រាវផ្ទាល់ ដោយសារតែការសិក្សាស្រាវជ្រាវនេះបានវែកញែក វិភាគ បកស្រាយយ៉ាងលម្អិតអំពីតួនាទី និងភារកិច្ចមេធាវីដែលត្រូវបំពេញ និងទទួលបាននូវចំណេះដឹងថ្មីៗជាច្រើនសម្រាប់ទុកជាប្រយោជន៍ដល់អ្នកសិក្សា សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវសារណាផ្សេងៗទៀត និងជាសារណាមួយដែលសម្បូរទៅដោយប្រភពនៃចំណេះដឹងសម្រាប់បុគ្គលទូទៅដែលមានបំណង និងក្តីស្រម៉ៃចង់ប្រកបវិជ្ជាជីវៈមេធាវី និងបានពន្យល់ណែនាំយ៉ាងច្បាស់អំពីនីតិវិធីមុននឹងប្រកបវិជ្ជាជីវៈនេះផងដែរ។ ជាចុងបញ្ចប់នេះ សារណានេះបានផ្តល់នូវប្រយោជន៍ជាច្រើន និងបានបង្ហាញឱ្យឃើញពីតួនាទីរបស់មេធាវីនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានផ្តល់អនុសាសន៍មួយចំនួនក្នុងការរួមចំណែកដើម្បីបន្ថែមនូវការយល់ដឹង និងផ្សព្វផ្សាយ ក៏ដូចជាពង្រឹងនូវវិជ្ជាជីវៈមេធាវីនៅក្នុងប្រទេសកម្ពុជាផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងនាមយើងខ្ញុំជានិស្សិត ដែលបានធ្វើការសិក្សាស្រាវជ្រាវនូវប្រធានបទនេះឡើងយកជាគោល និងមានបកស្រាយនៅក្នុងការសរសេរសារណានេះបានធ្វើការសិក្សា ស្រាវជ្រាវឡើង ដែលជាមូលដ្ឋានគ្រឹះប្រកបដោយសុក្រឹត្យភាព រួមមានការពាក់ព័ន្ធនិងច្បាប់នានា និងពឹងផ្អែកទៅលើការសុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា សុំមតិយោបល់ពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មេធាវី សិស្សច្បង ឯកសារបទដ្ឋានគតិយុត្តនានាមានដូចជា ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងរបស់មេធាវី ក្រមសីលធម៌របស់មេធាវី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឯកសារពីវគ្គបណ្តុះបណ្តាល ឯកសារបច្ចេកទេសការពារក្តី និងឯកសារទាក់ទងនិងមេរៀនទាក់ទងនិងវិជ្ជាជីវៈមេធាវីផងដែរ ព្រមទាំងបានចូលរួមនូវសិក្ខាសាលាស្តីពីការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌៖ ការផ្សព្វផ្សាយពីតួនាទី និងការទទួលខុសត្រូវរបស់មេធាវី។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះ ក្នុងការទទួលបានចំណេះដឹង ងាយស្រួល និងច្បាស់លាស់ពីប្រធានបទតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ជារួមមកប្រធានបទស្រាវជ្រាវអំពី តួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ ត្រូវបានបែងចែកជា០៣ជំពូកធំៗរួមមាន៖

- **ជំពូកទី១ សញ្ញាណទូទៅរបស់មេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

  បកស្រាយអំពី ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី និងនីតិវិធីនៃការប្រកបវិជ្ជាជីវៈរបស់មេធាវី និងលក្ខខណ្ឌក្នុងការប្រកបវិជ្ជាជីវៈមេធាវី។

- **ជំពូកទី២ តួនាទី និងភារកិច្ចរបស់មេធាវី**

  បកស្រាយអំពី តួនាទី និងភារកិច្ចរបស់មេធាវី ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ តាក់តែងចងក្រងលិខិតគតិយុត្តិ និងមានទំនាក់ទំនងជាមួយតុលាការ មានចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី។

- **ជំពូកទី៣ តួនាទីសំខាន់ៗរបស់មេធាវីក្នុងដំណាក់កាលនៃនីតិវិធី**

  បកស្រាយអំពី តួនាទីសំខាន់ៗរបស់មេធាវីនៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងបួន ដែលនៅក្នុងនោះរួមាន ដំណាក់កាលមន្ត្រីនគរបាលយុត្តធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។

- **សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

  នៅក្នុងសេចក្ដីសន្និដ្ឋាន យើងខ្ញុំបានលម្អិត និងមានការសង្ខេបពីតួនាទី និងភារកិច្ចរបស់មេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ និងមានការស្វែងរកនូវចំណុចវិជ្ជមាន និងអវិជ្ជមាន ដែលមាននៅក្នុងប្រធានបទនេះឡើង យើងខ្ញុំបានធ្វើការសិក្សា ស្រាវជ្រាវ ក្នុងការចូលរួមផ្តល់ចំណេះដឹង និងមានការចែករំលែក។

# ជំពូកទី១
# សញ្ញាណទូទៅរបស់មេធាវីនៃ
# ព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី១

# សញ្ញាណទូទៅរបស់មេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## ១.១. ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី

ប្រវត្តិមេធាវីនៅកម្ពុជានៅក្នុងឆ្នាំ១៩៣២ ដែលមានការណែនាំឱ្យស្គាល់ជាផ្លូវការនូវវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រមប្រកាសលេខ៣២ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៣២ ហើយក្រោយមកត្រូវបានធ្វើវិសោធនកម្មដោយព្រះរាជក្រមលេខ៦៤៨ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៥១។ ព្រះរាជក្រមប្រកាសលេខ៣២ បានណែនាំឱ្យស្គាល់អ្នកអនុវត្តវិជ្ជាជីវៈនេះ ដែលត្រូវបានគេហៅថា **អ្នកថណាយក្តី**។ វិជ្ជាជីវៈមេធាវីនៅកម្ពុជា បានទទួលរងបញ្ហាដោយសារតែមានការផ្លាស់ប្តូររបបនយោបាយ និងសង្គមជាច្រើនដំណាក់កាល។ ទើបធ្វើឱ្យវិជ្ជាជីវៈមួយនេះជួបប្រទះទៅនឹងផលប៉ះពាល់។ ចំពោះសេវារបស់មេធាវី គឺមានការរីកចម្រើន ដោយសារតែមានការរីកចម្រើនលើផ្នែកវិនិយោគសេដ្ឋកិច្ច សកម្មភាពពាណិជ្ជកម្ម ផលវិបាកនៃប្រព័ន្ធច្បាប់ និងនីតិវិធីរបស់តុលាការ រួមទាំងការកើតឡើងនូវសកម្មភាពជាបទល្មើសនៅក្នុងសង្គមជាដើម។ សិទ្ធិក្នុងការទទួលបានការការពារផ្នែកច្បាប់បានត្រូវមានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ នៅក្នុងឆ្នាំ១៩៤៧ ប្រទេសកម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញទី១របស់ខ្លួនដែលបានទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប មានដូចជា ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនអាចធ្វើទៅបាន លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការចាប់ខ្លួន ត្រូវផ្អែកទៅតាមនីតិវិធីដែលកំណត់នៅក្នុងច្បាប់ហើយមានមូលដ្ឋានជាក់លាក់ និងត្រូវបានសម្រេចដោយស្ថាប័នតុលាការ។ រដ្ឋធម្មនុញ្ញបានទទួលស្គាល់នូវសិទ្ធិមូលដ្ឋានផ្សេងទៀតរបស់មនុស្ស។ លើសពីនេះទៅទៀត រដ្ឋធម្មនុញ្ញនៅក្នុងឆ្នាំ១៩៧២ បានចែងពីសិទ្ធិរបស់ជនគ្រប់រូបក្នុងការការពារខ្លួនតាមផ្លូវតុលាការ។[1] ក្រោយមកសិទ្ធិជាមូលដ្ឋានក៏ត្រូវបានលុបចោល ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ប្រជាជនកម្ពុជាបានបាត់បង់នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ របបខ្មែរក្រហមបានធ្វើឱ្យមានការដាក់ទណ្ឌកម្ម និងប្រហារជីវិត ត្រូវបានយកមកអនុវត្តដោយស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ដែលពុំមានការជំនុំជម្រះតាមផ្លូវតុលាការនោះឡើយ។ ការចាត់តាំងមេធាវីបានចាប់ផ្តើម បន្ទាប់ពីមានការបង្កើតតុលាការខេត្តក្រុង បដិវត្តប្រជាជនក្នុងឆ្នាំ១៩៧៩។[2] តុលាការកំពូលនៅក្នុងឆ្នាំ១៩៨៥ និងសាលាឧទ្ធរណ៍នៅក្នុងឆ្នាំ១៩៩២។ លុះដល់ឆ្នាំ១៩៩២ មានការជួយពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

[1] មាត្រា ៦ រដ្ឋធម្មនុញ្ញទី១នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៤៧។

[2] ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៨៥ តុលាការមានតែ១ថ្នាក់ទេ គឺតុលាការខេត្តក្រុង សេចក្តីសម្រេចតុលាការត្រូវមានការពិនិត្យពីក្រសួងយុត្តិធម៌ មានកំហុសសេចក្តីសម្រេចបញ្ជូនទៅក្រុមប្រឹក្សារដ្ឋ តាមច្បាប់ស្តីពីការរៀបចំតុលាការ។

ក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត បទប្បញ្ញត្តិពាក់ព័ន្ធទៅនិងច្បាប់ព្រហ្មទណ្ឌ ច្បាប់យុត្តាធិការ ព្រមទាំងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តក្នុងអំឡុងពេលអន្តរកាលដែលមានឈ្មោះថា បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ។ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជា នៅក្នុងសម័យកាលអន្តរកាលដែលគេអោយឈ្មោះថា "**ច្បាប់ព្រហ្មទណ្ឌអន្តរកាល**"។ ច្បាប់ព្រហ្មទណ្ឌអន្តរកាលបានផ្តល់នូវលទ្ធភាពក្នុងការបង្កើតគណៈមេធាវី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការមានមេធាវីជាតំណាង រួមទាំងមានការការពារសិទ្ធិនៅក្នុងដំណាក់កាលជំនុំជម្រះក្តី។[3] អំឡុងពេលអន្តរកាល បុគ្គលដែលមានសញ្ញាបត្រស្មើនិងសញ្ញាបត្រនីតិសាស្ត្រ ឬមានបទពិសោធន៍ ០៥ (ប្រាំ) ឆ្នាំនៅក្នុងវិស័យច្បាប់ ឬវិស័យតុលាការទើបអាចអនុវត្តវិជ្ជាជីវៈមេធាវី។ សិទ្ធិក្នុងការទទួលបានការតំណាង និងការពារសិទ្ធិជនជាប់ចោទនៅក្នុងដំណាក់កាលជម្រះក្តី មិនមានតែនៅក្នុងច្បាប់អន្តរកាលឆ្នាំ១៩៩២នោះទេ។ ប៉ុន្តែរដ្ឋធម្មនុញ្ញទី៥នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏បានបញ្ជាក់ទទួលស្គាល់នេះផងដែរ។ [4] រដ្ឋធម្មនុញ្ញកម្ពុជាបានទទួលសិទ្ធិមូលដ្ឋានរបស់មនុស្ស ដូចដែលបានប្រកាសនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ មានអនុសញ្ញា កតិកាសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដទៃទៀត។[5] ម្យ៉ាងទៀត សិទ្ធិមានមេធាវីក៏បានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ផងដែរ។ [6] ទោះបីសិទ្ធិទទួលបានសិទ្ធិការពារ និងការបង្កើតនូវវិជ្ជាជីវៈមេធាវីត្រូវបានទទួលស្គាល់ក៏ដោយមេធាវីក៏មិនអាចអនុញ្ញាតប្រកបវិជ្ជាជីវៈ ដែលមានលក្ខណៈឯកជននៅក្រៅតុលាការឡើយ។ នៅពេលដែលគ្មានច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មេធាវីអាចត្រឹមតែជាអ្នកការពារក្តី។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានអនុវត្តចប់សព្វគ្រប់ដោយរដ្ឋសភានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៥។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើង និងដំណើរការជាផ្លូវការនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ តាមរយៈមហាសន្និបាតលើកទី១ មានការប្រកួតប្រជែងក្នុងការបោះឆ្នោត ជ្រើសរើសជាប្រធានគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាមេធាវី។ ក្រោយមកមានការកើនឡើងចំនួន តាមតម្រូវការរបស់សង្គម ដើម្បីធានាការពារសិទ្ធិ និងសេរីភាព ដែលទទួលបានការធានាឱ្យបានយុត្តធម៌ សម្រាប់ប្រជាជនគ្រប់រូបព្រមទាំងពង្រឹងវិស័យយុត្តិធម៌។ ចំណែកនៅក្នុងឆ្នាំ២០០១ មានអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹត្យការវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមជ្ឈមណ្ឌលពុំទាន់មានការបង្កើតនៅក្នុងឆ្នាំនោះនៅឡើយទេ។ រហូតដល់ឆ្នាំ២០០២ ទើបមានការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវីឱ្យចូលរៀននៅមជ្ឈមណ្ឌលនោះ។

[3] មាត្រា ៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

[4] មាត្រា ៣៨ រដ្ឋធម្មនុញ្ញទី៥នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៩៣។

[5] មាត្រា ៣៨ រដ្ឋធម្មនុញ្ញទី៥នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៩៣។

[6] មាត្រា ៧៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

## ១.២. នីតិវិធីការចូលប្រកបវិជ្ជាជីវៈមេធាវី

### ១.២.១. តាមរយៈការប្រឡង

ជនដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវី គឺជាបេក្ខជនដែលមានសញ្ជាតិខ្មែរទាំង២ភេទ ត្រូវឱ្យមាននូវសញ្ញាបត្រច្បាប់ បរិញ្ញាបត្រច្បាប់ និងមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដែលមានការបណ្តុះបណ្តាលពីគ្រូវិជ្ជាជីវៈមេធាវី។

#### ១.២.១.១. លក្ខខណ្ឌ

ដើម្បីប្រឡងចូលជាសិស្សមេធាវី និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបានត្រូវបំពេញលក្ខខណ្ឌដូចជា៖[7]

- ត្រូវមានសញ្ជាតិជាខ្មែរ[8]
- ត្រូវមានបរិញ្ញាបត្រច្បាប់ សញ្ញាបត្រច្បាប់ ឬវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដែលបានប្រកាសថាមានតម្លៃសមមូល។
- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ។
- ត្រូវមានក្រមសីលធម៌ និងកាយសម្បទាគ្រប់គ្រាន់។[9]

#### ១.២.១.២. ការប្រឡង

ការកំណត់ចំនួនសិស្សមេធាវី និងនីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវី កម្មវិធីបណ្តុះបណ្តាលដោយគ្រូបណ្តុះបណ្តាល និងការប្រឡងយកវិញ្ញាបនបត្រសម្បទាវិជ្ជាជីវៈមេធាវី ត្រូវពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។ [10] ការប្រឡងមានវិញ្ញាសារពីរប្រភេទ គឺវិញ្ញាសារសរសេរ និងវិញ្ញាសារផ្ទាល់មាត់។

#### ១.២.១.៣. ការចុះកម្មសិក្សា

នៅពេលដែលបានបញ្ចប់វគ្គសិក្សានៅមជ្ឈមណ្ឌលដោយជោគជ័យរួច ក្រុមប្រឹក្សាគណៈមេធាវី និងធ្វើការពិនិត្យមើលរាល់លក្ខខណ្ឌដែលបេក្ខជនបានបំពេញ និងធ្វើការសម្រេច ចំពោះការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈ។ បន្ទាប់មកអ្នកដែលត្រូវទទួលបានការសិក្សានៅមជ្ឈមណ្ឌលចប់ និងទទួលបានការជោគជ័យជាសិស្សមេធាវីទាំងអស់។ មេធាវីដែលបានប្រកបវិជ្ជាជីវៈត្រូវធ្វើសច្ចាប្រណិធានជាមុន នៅចំពោះមុខប្រធានសាលាឧទ្ធរណ៍ដែលមានវត្តមានប្រធានគណៈមេធាវីផង។ បន្ទាប់មកទៀតមេធាវីដែលទើបតែបានចុះឈ្មោះនោះ ត្រូវធ្វើកម្មសិក្សារយៈពេល ០១ (មួយ) ឆ្នាំ។ ក្រោយមកមេធាវីនោះត្រូវទទួលការបំប៉នបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី

[7] មាត្រា ៣១ វាក្យខ័ណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[8] ច្បាប់ ៣១ ស្តីពីសញ្ជាតិអនុម័តនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦។

[9] មាត្រា៣១ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[10] មាត្រា ៦ អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឆ្នាំ២០០៨។

និងត្រូវបានកំណត់ឱ្យចូលរួមបំពេញការងារពិតប្រាកដ ជាសហការីក្នុងការិយាល័យមេធាវីណាមួយ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ ហើយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងការណែនាំ និងការគ្រប់គ្រងដោយមេធាវីម្នាក់ និងមាននូវក្រុមប្រឹក្សាគណៈមេធាវីដែលចាត់តាំងឱ្យទទួលខុសត្រូវលើកម្មសិក្សានោះ ។[11]

### ១.២.២. តាមរយៈការស្នើសុំ

#### ១.២.២.១. លក្ខខណ្ឌ

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបានត្រូវបំពេញលក្ខខណ្ឌមានដូចជា៖

ករណីគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈ និងបរិញ្ញាបត្រច្បាប់

- ចៅក្រមដែលបានបំពេញការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ០៥ (ប្រាំ) ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ ហើយដែលបានបម្រើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ០២ (ពីរ) ឆ្នាំ។
- អ្នកដែលមានបរិញ្ញាបត្រ ហើយដែលបានបំពេញការងារវិស័យច្បាប់ ឬតុលាការលើសពី ០២ (ពីរ) ឆ្នាំ។

ករណីគ្មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈ តែត្រូវមានបរិញ្ញាបត្រច្បាប់។

- មេធាវីដែលមានសញ្ជាតិខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ។
- អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់។[12]

#### ១.២.២.២. ការដាក់ពាក្យស្នើសុំ

បុគ្គលណាដែលមានបំណងចង់ស្នើសុំប្រកបវិជ្ជាជីវៈ ហើយបានបំពេញតាមលក្ខខណ្ឌនៃមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវធ្វើការទាក់ទងនៅការិយាល័យរដ្ឋបាលនៃគណៈមេធាវី។ ការដាក់ពាក្យស្នើសុំតម្រូវឱ្យបង់ថ្លៃលើពាក្យសុំ។ [13] ការកំណត់ដាក់ពាក្យស្នើសុំ ដែលត្រូវធ្វើឡើងដោយគណៈមេធាវីផ្ទាល់។ បន្ទាប់ពីបំពេញពាក្យសុំរួចរាល់ត្រូវយកពាក្យសុំនោះទៅដាក់នៅការិយាល័យរដ្ឋបាលនៃគណៈមេធាវី ដោយភ្ជាប់មកជាមួយឯកសារមួយចំនួន ដែលមានពាក្យសុំប្រកបវិជ្ជាជីវៈ ប្រវត្តិរូបសង្ខេបសាមីខ្លួន លិខិតថ្កោលទោសដែលមានសុពលភាព និងឯកសារចាំបាច់ផ្សេងទៀតដែលកំណត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។[14]

- ពាក្យសុំចូលប្រកបវិជ្ជាជីវៈតាមមាត្រា៣២
- ប្រវត្តិរូបសង្ខេបសាមីខ្លួន
- លិខិតថ្កោលទោសដែលមានសុពលភាព
- ឯកសារតម្រូវផ្សេងៗទៀត ដែលកំណត់ដោយគណៈមេធាវី។

---

[11] មាត្រា ៣៥ និងមាត្រា ៣៦ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[12] មាត្រា ៣១ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[13] ប្រការ ៦ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ ឆ្នាំ២០០៧។

[14] ប្រការ ៧ នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ ឆ្នាំ២០០៧។

**១.២.២.៣. ការដាក់ពាក្យធ្វើកម្មសិក្សា**

បន្ទាប់ពីគណៈមេធាវីបានពិនិត្យ និងបញ្ជូនឯកសារពាក្យសុំទៅក្រុមអធិការកិច្ច ហើយក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ៣០ (សាមសិប) ថ្ងៃត្រូវរាយការណ៍ជូនអធិការកិច្ច និងបញ្ជូនរបាយការណ៍នោះទៅកាន់ប្រធាននាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ មុនបញ្ជូនទៅគណៈមេធាវី។ នៅក្នុងរបាយការណ៍មានលក្ខណៈគ្រប់គ្រាន់ហើយនោះ។ ប្រធានគណៈមេធាវី ត្រូវកំណត់ពេលដើម្បីធ្វើការសម្ភាសន៍បេក្ខជនផ្ទាល់ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។[15] នៅពេលមានការសម្រេចពីក្រុមប្រឹក្សាគណៈមេធាវី ដែលបានបោះឆ្នោតសម្រេចយល់ព្រម ចំពោះសំណើនោះដោយមានសំឡេងគាំទ្រភាគច្រើននោះ បញ្ជាក់ថាបេក្ខជនទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈជាស្ថាពរ។ បេក្ខជនចូលប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍ និងត្រូវដាក់ពាក្យសុំចុះកម្មសិក្សារយៈពេល ០១ (មួយ) ឆ្នាំ។ របាយការណ៍បញ្ចប់ការសិក្សាដាក់ឱ្យគណៈមេធាវីធ្វើការត្រួតពិនិត្យ និងសម្រេចលើការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យក្លាយជាមេធាវីពេញសិទ្ធិ។

[15] ប្រការ ១៤ សេចក្ដីសម្រេចពីនីតិវិធីនៃការទទួលពាក្យពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី (មាត្រា៣២)។

# ជំពូកទី២
# តួនាទី និងភារកិច្ចរបស់មេធាវី

# ជំពូកទី២

# តួនាទី និងភារកិច្ចរបស់មេធាវី

## ២.១. តួនាទីមេធាវី និងការទទួលខុសត្រូវរបស់មេធាវី

### ២.១.១. ភាតព្វកិច្ចគោរពនូវការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវីត្រូវតែរក្សាការសម្ងាត់វិជ្ជាជីវៈមេធាវីជាដាច់ខាត។ ដោយសារតែការសម្ងាត់នេះមិនអាចត្រូវឱ្យជនណាម្នាក់ទទួលបាននូវការសម្ងាត់នោះបានទេ ទោះបីជាអតិថិជនរបស់ខ្លួនក៏ដោយ។ មេធាវីពុំអាចបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំឱ្យបំពាន លើការសម្ងាត់នៃវិជ្ជាជីវៈខ្លួនបានឡើយ ទោះបីនៅមុខតុលាការក៏ដោយ។ មេធាវីត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ឯកសារផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសម្រាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវីនិងអតិថិជនផ្ញើទាក់ទងគ្នា។ ការរក្សាការសម្ងាត់នេះមានន័យថា ពេលមេធាវីទទួលពិគ្រោះច្បាប់ ឬការពារក្តី ឬតំណាងក្តីឱ្យអតិថិជនណាម្នាក់ហើយ គឺមិនអាចនិយាយ ឬទម្លាយរឿងហេតុ ដែលខ្លួនឱ្យទៅជាសាក្សី ឬឱ្យប៉ះពាល់ដល់អាថ៌កំបាំងវិជ្ជាជីវៈ។ មេធាវីក៏មិនអាចអន្តរាគមន៍ទៅបានដែរ កាលណាការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួន ត្រូវចោទប្រកាន់ឡើង។ មេធាវី គឺមិនអាចពិគ្រោះយោបល់ច្បាប់នៅទីកន្លែងសាធារណៈបានឡើយ។ [16]

### ២.១.២. ទំនួលខុសត្រូវចំពោះអតិថិជន

#### ២.១.២.១. ភាពស្មោះត្រង់ក្នុងការបំពេញបេសកកម្មជូនអតិថិជន

មេធាវីត្រូវមានសីលធម៌ខ្ពស់ចំពោះការងារ ដោយធ្វើយ៉ាងណាឱ្យអតិថិជនមានការពេញចិត្ត និងមានភាពជឿជាក់លើខ្លួន។ មេធាវីមានសេរីភាពទទួល ឬមិនទទួលកូនក្តី ប្រសិនបើខ្លួនយល់ឃើញថាមានការប៉ះពាល់ដល់សម្បជញ្ញៈរបស់ខ្លួន។ ការចាត់តាំងដោយប្រធានគណៈមេធាវី មេធាវីត្រូវតែទទួលយក។ ប៉ុន្តែប្រសិនបើមានហេតុផលបញ្ជាក់ច្បាស់លាស់ថា មានការប៉ះពាល់ដល់សម្បជញ្ញៈខ្លួន មេធាវីអាចប្រកែកមិនទទួលយកបាន ទើបមេធាវីអាចទទួលរឿងក្តីតាមរយៈកូនក្តីផ្ទាល់ ឬតាមរយៈតតិយជន។ [17] មេធាវី ត្រូវមានភាពសុចរិត និងភាពស្មោះត្រង់មេធាវីត្រូវតែគោរពនិងប្រតិបត្តិការ នូវគោលការណ៍សុចរិត និងភាពស្មោះត្រង់។[18] ដូចនេះ មេធាវីត្រូវប្រកាន់យកអត្តចរិតថ្លៃថ្នូរ មានសតិសម្បជញ្ញៈ មានការទទួលខុសត្រូវ មានសីលធម៌គុណធម៌ ទៀតទាត់ មានមនុស្សធម៌ ឯករាជ្យ និងគោរពសិទ្ធិអ្នកដទៃ។

[16] មាត្រា ៥៨ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[17] មាត្រា ២២ ក្រមសីលធម៌មេធាវីចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[18] មាត្រា ៧ ក្រមសីលធម៌មេធាវីចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

### ២.១.២.២. ភាតព្វកិច្ចរបស់មេធាវីចំពោះអតិថិជន

មេធាវី និងអតិថិជនដែលជាកូនក្តីត្រូវបានចងកាតព្វកិច្ចដោយសារតែមានកិច្ចសន្យាផ្តល់សេវាកម្មច្បាប់រវាងមេធាវី និងអតិថិជន។ មេធាវីត្រូវតែបំពេញការងាររបស់ខ្លួនជូនអតិថិជន ទៅតាមកាតព្វកិច្ចដែលបានកំណត់នៅក្នុងកិច្ចសន្យាផ្តល់សេវាកម្មច្បាប់។ មេធាវីត្រូវមានការយល់ដឹងថា ខ្លួនជាម្ចាស់នៃមធ្យោបាយការពាររបស់អតិថិជនខ្លួន។ នៅក្នុងកិច្ចសន្យាផ្តល់សេវាមេធាវី ត្រូវបានកំណត់ផងដែរអំពីប្រាក់កម្រៃរបស់ខ្លួន ឱ្យបានច្បាស់លាស់ ដូចជាការកំណត់ជាទឹកប្រាក់សរុប គិតកម្រៃតាមដំណាក់កាលក៏បាន។ ដើម្បីបំពេញការងារឱ្យអតិថិជនរបស់ខ្លួនឱ្យបានត្រឹមត្រូវ មេធាវីត្រូវមានលិខិតពឹងពាក់មេធាវីពីកូនក្តី ឬលិខិតប្រគល់សិទ្ធិតំណាងពីកូនក្តី។ មេធាវីដែលទទួលការពារក្តីឱ្យអតិថិជនហើយ ត្រូវខិតខំបំពេញការងាររបស់ខ្លួនឱ្យបានល្អ ឱ្យអស់ពីលទ្ធភាពសមត្ថភាពដែលខ្លួនមាន។ មេធាវីត្រូវធ្វើយ៉ាងណាដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ជូនកូនក្តីរបស់ខ្លួនទៅតាមលទ្ធភាពមួយដែលអាចធ្វើទៅបាន។ មេធាវីត្រូវមានភារកិច្ចយ៉ាងសំខាន់ក្នុងការបំពេញកិច្ចរបស់ខ្លួនជូនអតិថិជន និងធ្វើយ៉ាងណាឱ្យអតិថិជនជឿជាក់មកលើខ្លួន ក្នុងការធានាឱ្យបានជោគជ័យ ជាមួយគ្នានេះដែរដើម្បីឱ្យមេធាវីទទួលខុសត្រូវចំពោះការបាត់បង់ផលប្រយោជន៍ របស់ខ្លួនបានអតិថិជនត្រូវលើកបង្ហាញចំណុចសំខាន់ដូចខាងក្រោម៖

- **កំហុសរបស់មេធាវី**

  មេធាវីធ្វើកិច្ចការរបស់ខ្លួនមិនគោរពកាតព្វកិច្ចវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ ដោយមានការខ្ជីខ្ជាធ្វេសប្រហែស ឬមិនព្រមបំពេញកាតព្វកិច្ចដែលធ្វើឱ្យខូចខាតនូវប្រយោជន៍របស់កូនក្តី។

- **មានការខូចខាត ឬខូចនូវប្រយោជន៍របស់កូនក្តី**

  ដើម្បីឱ្យមេធាវីទទួលខុសត្រូវចំពោះខ្លួនបាន អតិថិជនត្រូវបង្ហាញឱ្យឃើញពីការខូចប្រយោជន៍របស់ខ្លួន ប្រសិនបើគ្មានការខូចខាតនោះទេ ក៏មិនអាចឱ្យមេធាវីទទួលខុសត្រូវនូវកំហុសបានឡើយ។

- **មានចំណងទាក់ទងរវាងកំហុស និងការខូចប្រយោជន៍**

  ការខូចខាតប្រយោជន៍ត្រូវតែចេញដោយផ្ទាល់ ពីកំហុសមេធាវី ពោលគឺការខូចប្រយោជន៍នោះកើតចេញពីលទ្ធផលនៃកំហុស។ ប្រសិនបើជាការខូចខាតប្រយោជន៍នោះ មិនមែនចេញពីកំហុសទេ នោះមេធាវីមិនអាចទទួលនូវកំហុសបានដែរ។

- **កំហុសរបស់អតិថិជន**

  ប្រសិនបើកំហុសមួយ ដែលបានកើតឡើងត្រូវបានរកឃើញថាមកពីភាពយឺតយ៉ាវរបស់អតិថិជននោះ ដោយមានការយឺតយ៉ាវទៅលើសំណុំរឿងរបស់អតិថិជន ប្រសិនបើជាការខូចខាតប្រយោជន៍នោះមិនមែនចេញពីកំហុសរបស់អតិថិជន នោះមេធាវីមិនអាចទទួលនូវកំហុសបានដែរ។

### ២.១.២.៣ ទំនួលខុសត្រូវផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងទណ្ឌកម្មវិន័យ

ទង្វើរបស់មេធាវីដែលមានកំហុសឆ្គងផ្នែកវិជ្ជាជីវៈ តម្រូវឱ្យមេធាវីទទួលខុសត្រូវចំពោះអតិថិជនដូចជា៖

- **ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី** ក្នុងករណីដែលមេធាវីណាម្នាក់ធ្វើការងារធ្វេសប្រហែសដែលធ្វើឱ្យមានការខូចខាតនូវប្រយោជន៍របស់អតិថិជន មេធាវីនោះត្រូវតែប្រឈមមុននិងការទទួលខុសត្រូវសងសំណងរដ្ឋប្បវេណីទៅលើការខូចខាតនោះ។ មេធាវីនោះអាចត្រូវបានអតិថិជនប្តឹងទៅគណៈមេធាវី និងទៅតុលាការដើម្បីទាមទារនូវសំណងដែលខ្លួនបានខូចខាត ដោយសារកំហុសមេធាវីនោះផងដែរ។ អាស្រ័យហេតុនេះហើយ បានជាច្បាប់តម្រូវឱ្យមេធាវីម្នាក់ៗត្រូវការទទួលខុសត្រូវចំពោះវិជ្ជាជីវៈខ្លួន។
- **ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ** ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនមេធាវីត្រូវប្រឈមមុខនិងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្នុងករណីដែលមេធាវីរំលោភបំពានលើការសម្ងាត់វិជ្ជាជីវៈមេធាវី។ ប្រសិនបើជនណាប្រព្រឹត្តបទល្មើស ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ។[19]
- **ទណ្ឌកម្មវិន័យ** មានដូចតទៅ ការព្រមាន ការស្តីបន្ទោស ការហាមឃាត់ប្រកបវិជ្ជាជីវៈមួយរយៈពេលដែលពុំអាចលើសពី ០២ (ពីរ) ឆ្នាំការលុបឈ្មោះចោលពីបញ្ជីនៃគណៈមេធាវី ឬពីបញ្ជីនៃមេធាវីកម្មសិក្សា ឬការហូតងារកិត្តិយស។[20]

## ២.២ តួនាទីមេធាវីក្នុងការទាក់ទង និងការប្រកបវិជ្ជាជីវៈ

មេធាវី មានតួនាទីក្នុងការពិគ្រោះយោបល់ ផ្តល់ប្រឹក្សា ឬការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីក្នុងរឿងព្រហ្មទណ្ឌ។ មេធាវីក៏អាចជួយការពារកូនក្តី នៅចំពោះមុខក្រុមប្រឹក្សាវិន័យបានផងដែរ។ មេធាវីជាអ្នកផ្តល់យោបល់ និងតាក់តែងលិខិតគតិយុត្តិផ្សេងៗ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់សាធារណជនទូទៅ។ មេធាវី អាចត្រូវបានចាត់តាំងដោយកូនក្តី ឬចៅក្រមឱ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬជាអ្នកដែលសម្រុះសម្រួល ឬអាជ្ញាកណ្តាលក្នុងករណីដែលច្បាប់អនុញ្ញាត។ ដោយមានការពឹងពាក់ពីអតិថិជន មេធាវីក៏មានសិទ្ធិធ្វើជាការពារផលប្រយោជន៍ស្របច្បាប់ឱ្យអតិថិជននៅចំពោះមុខស្ថាប័ន មានសមត្ថកិច្ចនានាផ្សេងទៀតផងដែរ។ ដើម្បីឱ្យមានការប្រព្រឹត្តទៅនៃវិជ្ជាជីវៈដែលមិនប្រាសចាកភាពត្រឹមត្រូវ ចាំបាច់មេធាវីគ្រប់រូបត្រូវតែមានការទាក់ទង និងការប្រកបវិជ្ជាជីវៈ ដោយត្រូវស្វែងរកនូវយុត្តិធម៌ ហើយព្យាយាមលុបបំបាត់ភាពអយុត្តិធម៌។ ការប្របកវិជ្ជាជីវៈមេធាវី ត្រូវតែមានការកំណត់តាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង ក៏មានដូចជា នៅក្នុងច្បាប់ផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌ។

---

[19] មាត្រា ៧៨ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។
[20] មាត្រា ៦៣ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

## ២.៣. តួនាទីរបស់មេធាវីក្នុងការផ្តល់ប្រឹក្សាផ្នែកច្បាប់

ក្នុងការបំពេញមុខងាររបស់ខ្លួន មេធាវីដើរតួជាអ្នកបកស្រាយច្បាប់ ក៏ដូចជាពន្យល់អត្ថន័យ និងអំពីសារៈសំខាន់នៃច្បាប់ទាំងនោះទៅកាន់ប្រជាពលរដ្ឋ។ លើសពីនេះទៀតក្នុងករណីដែលច្បាប់ណាមួយមិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋ មេធាវីក៏អាចផ្តល់ជាជំនួយក្នុងការប្រឹក្សាយោបល់ ដើម្បីធ្វើការកែសម្រួលច្បាប់នោះផងដែរ។ ក្រៅពីនេះមេធាវីក៏ដើរតួនាទីណាស់ ជាអ្នកតំណាងការពារកូនក្តីរបស់ខ្លួននៅក្នុងដំណើរការតុលាការ និងតវ៉ាដើម្បីការពារសិទ្ធិរបស់កូនក្តីចំពោះមុខតុលាការ។

### ២.៣.១. ការប្រឹក្សាយោបល់ក្នុងវិស័យគតិយុត្តិ

ការប្រឹក្សាផ្នែកច្បាប់ មេធាវីត្រូវតែយល់ឱ្យច្បាស់ពីអង្គហេតុ និងច្បាប់នានាដែលពាក់ព័ន្ធនិងរឿងក្តីមុននិងធ្វើការផ្តល់ប្រឹក្សាច្បាប់។ ដើម្បីយល់ឱ្យច្បាស់នូវអង្គហេតុ មេធាវីគប្បីជម្រុញឱ្យអតិថិជន រៀបរាប់ហេតុការណ៍ឱ្យបានលម្អិតដែលពាក់ព័ន្ធនិងអង្គហេតុ។ មេធាវីត្រូវកាត់ត្រារាល់ចំណុចសំខាន់ទាំងអស់ ដែលពាក់ព័ន្ធនិងអង្គហេតុជាពិសេសអង្គហេតុចម្បងរបស់រឿងក្តីនីមួយៗ បន្ទាប់ពីធ្វើការវិភាគលើអង្គហេតុ មេធាវីត្រូវកំណត់ច្បាប់ណាខ្លះដែលគួរលើកយកមកអនុវត្ត និងមានបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធដើម្បីឱ្យមេធាវីអាចផ្តល់ប្រឹក្សាច្បាប់ត្រឹមត្រូវទៅកាន់អតិថិជនរបស់ខ្លួន។

### ២.៣.២. ការការពារកូនក្តី

មុខងាររបស់មេធាវី គឺដើម្បីការពារនូវផលប្រយោជន៍របស់កូនក្តីខ្លួន។ មេធាវីអាចការពារកូនក្តីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ការពារដើមបណ្តឹងរដ្ឋប្បវេណី និងការពារឱ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ មេធាវីអាចការពារសិទ្ធិជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ តាមរយៈពាក្យសុំពឹងពាក់មេធាវីក្នុងរឿងព្រហ្មទណ្ឌ ប៉ុន្តែមេធាវីមិនអាចតំណាងជននោះបានឡើយ លើកលែងក្នុងករណីអនុវត្តបទប្បញ្ញត្តិពិសេសនៃច្បាប់។ ការការពារកូនក្តីនៅក្នុងតុលាការ មេធាវីត្រូវលើកយកអំណះអំណាង និងភស្តុតាងផ្សេងៗដែលធ្វើឱ្យចៅក្រមសម្រេចក្តីអាចផ្តល់ប្រយោជន៍ឱ្យកូនក្តីបានស្របតាមច្បាប់ជាធរមាន។

### ២.៣.៣. តាក់តែង និងចងក្រងលិខិតគតិយុត្តិ

មេធាវីមានតួនាទីជាអ្នកប្រឹក្សាយោបល់ផ្នែកច្បាប់ និងតាក់តែងលិខិតគតិយុត្តិផ្សេងៗក្នុងវិស័យច្បាប់ដំណាក់កាលដំបូងនៃទំនាក់ទំនងរវាងមេធាវី និងអតិថិជន។ ក្នុងដំណាក់កាលប្រឹក្សាយោបល់នេះមេធាវីត្រូវជួបដោយផ្ទាល់ជាមួយកូនក្តី និងស្តាប់ពីអង្គហេតុ ដែលកូនក្តីបានរៀបរាប់បន្ទាប់មកមេធាវីមានការផ្តល់យោបល់ផ្នែកច្បាប់ជូនកូនក្តី និងជួយណែនាំពីសិទ្ធិ និងករណីយកិច្ចស្របតាមច្បាប់ដែលមានការពាក់ព័ន្ធដល់សិទ្ធិ និងករណីយកិច្ចស្របតាមច្បាប់ចំពោះរឿងក្តី។ មេធាវីត្រូវតែយល់ឱ្យច្បាស់ពីអង្គហេតុ និងច្បាប់នានាដែលពាក់ព័ន្ធ

មុននិងធ្វើការផ្តល់យោបល់ប្រឹក្សាផ្នែកច្បាប់។ មេធាវី ត្រូវកត់ត្រាទុកនូវចំណុចសំខាន់ៗទាំងអស់ ដែលពាក់ព័ន្ធនឹងអង្គហេតុនៃរឿងក្តី។ បន្ទាប់ពីវិភាគអង្គហេតុរួចមេធាវីត្រូវកំណត់ថាច្បាប់ណាដែលគួរយកមកអនុវត្ត និងមើលថាមានបទបញ្ញត្តិណាដែលពាក់ព័ន្ធ ដើម្បីឱ្យមេធាវីអាចផ្តល់ការប្រឹក្សាច្បាប់ដ៏ត្រឹមត្រូវ ជូនចំពោះអតិថិជនរបស់ខ្លួន។ ជាទូទៅការពិគ្រោះនេះគឺជាកិច្ចដំបូងដែលមេធាវីត្រូវធ្វើពោលគឺក្រោយពីស្តាប់ និងវិភាគអង្គហេតុរួចមេធាវីត្រូវរំលេចនូវអង្គច្បាប់ និងរៀបចំលិខិតស្នាមផ្សេងៗដែលកូនក្តីចង់បាន។ ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងស្នាមលិខិតគតិយុត្តិបានឡើយលើកលែងតែការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខងាររបស់ខ្លួន ឬជាមុខងារដែលច្បាប់អនុញ្ញាត។[21]

## ២.៣.៤. មេធាវីអ្នកសម្របសម្រួល និងអ្នកអាជ្ញាកណ្តាល

មេធាវីមានមុខងារជាអ្នកផ្សះផ្សា និងអ្នកសម្របសម្រួលទៅដល់ភាគីតាមការស្នើសុំរបស់ភាគីនីមួយៗ ឬតាមការចាត់តាំងពីចៅក្រមហើយមេធាវីក៏អាចក្លាយជាអាជ្ញាកណ្តាលផងដែរតាមច្បាប់អនុញ្ញាត។ រឿងក្តីវិវាទណាមួយរបស់ភាគីតាមសំណូមពររបស់កូនក្តីព្រមទាំងបង្ហាញនូវផលល្អ ឬផលមិនល្អ និងការខាតបង់នានាដែលអាចកើតមានឡើង។ ប្រសិនបើរឿងក្តីនៅតែបន្តដោះស្រាយតាមនីតិវិធីតុលាការ។ មេធាវីអាចធ្វើការណាត់ជួបភាគីម្ខាងទៀត ឬរៀបចំការជួបគ្នារវាងភាគីទាំងពីរដើម្បីជជែកពិភាក្សារកដំណោះស្រាយសមស្របណាមួយដែលភាគីអាចទទួលបាន។ មេធាវីក៏អាចក្លាយជាអាជ្ញាកណ្តាលផងដែរទៅលើរឿងក្តីវិវាទណាមួយ របស់គូភាគីតាមសំណូមពររបស់កូនក្តី និងច្បាប់បានកំណត់។[22]

## ២.៣.៥. ការតំណាងជូនកូនក្តី

ទំនាក់ទំនងរវាងមេធាវី និងអតិថិជនគឺជាទំនាក់ទំនងតាមកិច្ចសន្យាហើយកិច្ចសន្យានេះអាចមានប្រភពពីទំនៀមទម្លាប់ និងការព្រមព្រៀងគ្នាទៅវិញទៅមក។[23] មេធាវីអាចតំណាងឱ្យកូនក្តីបានតាមការយល់ព្រមពីកូនក្តីដោយជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី លើកលែងមានបទប្បញ្ញត្តិច្បាប់ចែងផ្ទុយ។ កូនក្តីបានប្រគល់សិទ្ធិនោះមេធាវីអាចមានសិទ្ធិចូលរួមដោះស្រាយ ឬដាក់ពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ចជំនួសកូនក្តីរបស់ខ្លួនដូចជាទៅអាជ្ញាធរភូមិ ឃុំ សង្កាត់ និងតុលាការ ធ្វើយ៉ាងណាដើម្បីការពារផលប្រយោជន៍កូនក្តីខ្លួនស្របតាមច្បាប់។ ម្យ៉ាងវិញទៀតនៅក្នុងរឿងព្រហ្មទណ្ឌមេធាវីក៏មិនអាចតំណាងឱ្យកូនក្តីបានដែរ។ ពីព្រោះមេធាវីមិនអាចឆ្លើយជំនួសកូនក្តីបានឡើយ និងសកម្មភាពសំណើរឿង

[21] មាត្រា ៤ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។
[22] មាត្រា ៣ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។
[23] មាត្រា ១៨ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

កូនក្តីរបស់ខ្លួនពោលគឺមេធាវីអាចបានតែការពារសិទ្ធិផលប្រយោជន៍ឱ្យកូនក្តីតែប៉ុណ្ណោះនៅក្នុងរឿងព្រហ្មទណ្ឌ។ ការតំណាងឱ្យកូនក្តីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ មេធាវីអាចតំណាងបានចំពោះការតំណាងឱ្យជនរងគ្រោះ និងអ្នកតំណាងឱ្យបុគ្គលដែលតាំងខ្លួនក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីពីព្រោះការតំណាងគឺដើម្បីទាមទារ ការពារសិទ្ធិ និងផលប្រយោជន៍ឱ្យកូនក្តីខ្លួន។ មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ។[24]

## ២.៣.៦. ការបង់វិភាគទាន

មូលនិធិគណៈមេធាវីត្រូវបានបង្កើតឡើងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលមានឈ្មោះថាវិភាគទានគណៈមេធាវី។[25] ការអនុវត្តជាក់ស្តែងជំនួយផ្នែកច្បាប់នៅកម្ពុជា ត្រូវបានបែងចែកជា៣ផ្នែកៈ

- រាល់សមាជិកគណៈមេធាវី ត្រូវបង់វិភាគទានជារៀងរាល់ឆ្នាំ ទៅឱ្យមូលនិធិគណៈមេធាវី។
- រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ថវិកាជំនួយផ្នែកច្បាប់ជារៀងរាល់ឆ្នាំ។
- ជំនួយផ្នែកច្បាប់ផ្សេងទៀតក៏ត្រូវបានផ្តល់ដោយវិស័យឯកជន អង្គការ ឬរដ្ឋាភិបាលបរទេស។

មូលនិធិរបស់គណៈមេធាវីត្រូវបានប្រើប្រាស់សម្រាប់សកម្មភាព និងតម្រូវការរបស់គណៈមេធាវីសម្រាប់ឧបត្ថម្ភទៅឱ្យមេធាវី ដែលបានការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ។ អង្គការក្រៅរាជរដ្ឋាភិបាលមួយចំនួនបានផ្តល់មេធាវីដើម្បីការពារ និងបានលើកកម្ពស់នូវសិទ្ធិមនុស្ស ឬបានផ្តល់ជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។ ជំនួយផ្នែកច្បាប់នេះអាចការពារពីការធ្វើទណ្ឌកម្មក្នុងអំឡុងពេលឃុំខ្លួន និងកាត់បន្ថយការផ្តន្ទាទោសដោយគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ។ គណៈមេធាវីមានឯករាជ្យផ្នែករដ្ឋបាល និងស្វ័យភាពហិរញ្ញវត្ថុដាច់ដោយឡែកពីស្ថាប័នរដ្ឋាភិបាលទាំងឡាយ។ គណៈមេធាវី មិនស្ថិតនៅចំណុះឱ្យអំណាចសាធារណៈ និងមិនប្រើប្រាស់ថវិកាជាតិ ដូចជាស្ថាប័នសាធារណៈដ៏ទៃទៀតឡើយ។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវី។ មេធាវីទាំងអស់ដែលបច្ចុប្បន្នមានឈ្មោះក្នុងបញ្ជីត្រីមាសដោយត្រូវបង់នៅបំណាច់ត្រីមាសនីមួយៗ។ មេធាវីម្នាក់ៗ ត្រូវបង់វិភាគទានឱ្យបានទាន់ពេលវេលាដែលបានកំណត់។ មេធាវីណាដែលមិនបានបង់វិភាគទានត្រូវទទួលទណ្ឌកម្មជាបទពិន័យ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។ មេធាវីត្រូវបង់ឱ្យទាន់ពេលកំណត់ ប្រសិបើមេធាវីមិនបានបង់ភាគទាន ត្រូវទទួលទណ្ឌកម្មហាមឃាត់មិនឱ្យប្រកបវិជ្ជាជីវៈមេធាវីឡើយ។[26] ដូចនេះ រាល់សមាជិករបស់គណៈមេធាវី ត្រូវមានការបង់វិភាគទានទៅឱ្យមូលនិធិគណៈមេធាវី ដើម្បីក្នុងការការពារ លើកកម្ពស់ និងផ្តល់ជាជំនួយទៅដល់ប្រជាពលរដ្ឋដែលមានកង្វះខាតនៅក្នុងសង្គមផ្នែកច្បាប់ និងមានការអភិវឌ្ឍផ្នែកច្បាប់ ព្រមទាំងបង្កើនធនធាននៅក្នុងប្រទេស ដែលមានចំណេះដឹងផ្នែកច្បាប់ឱ្យកាន់តែច្រើន។

[24] មាត្រា ២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[25] មាត្រា ២៩ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

[26] មាត្រា ៥៥ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។

## ២.៤. ទំនាក់ទំនងរបស់មេធាវី និងបុគ្គលផ្សេងទៀត

### ២.៤.១. ទំនាក់ទំនងជាមួយអតិថិជន

ការទំនាក់ទំនងជាមួយអតិថិជនត្រូវធ្វើដោយចំពោះ និងផ្ទាល់ខ្លួន។ មេធាវីមិនអាចទទួលរឿងក្តីតាមរយៈតតិយជនបានឡើយ។ ប្រសិនបើជាខ្លួនគ្មានសេរីភាព និងចូលទៅទាក់ទងផ្ទាល់ខ្លួនជាមួយអតិថិជនដែលមាននៅក្នុងរឿងក្តីនោះ។ វិធាននេះមិនត្រូវបានប្រតិបត្តិកាលណាមេធាវីដើរតួជាអ្នកឆ្លើយឆ្លងរបស់មេធាវីម្នាក់ទៀត។[27] មេធាវីជាបុគ្គលប្រកបដោយចំណេះដឹង មានសតិសម្បជញ្ញៈ មានភាពថ្លៃថ្នូរ និងជាបុគ្គលរួសរាយរាក់ទាក់ សុភាពរាបសារ តែម៉ឺងម៉ាត់នៅក្នុងការងារ។ ដើម្បីរក្សានូវតម្លៃរបស់ខ្លួនរាល់ការទំនាក់ទំនងដែលមេធាវីធ្វើឡើងទោះបីជាមួយអតិថិជនក្តី ឬជាមួយសមាជិកក្នុងវិជ្ជាជីវៈក្តី ឬជាមួយស្ថាប័នផ្សេងៗទៀតក៏ដោយ។ មេធាវីត្រូវគោរពតាមបញ្ញត្តិច្បាប់ និងក្រមសីលធម៌ជានិច្ចទោះក្នុងកាលៈទេសៈណាក៏ដោយ។ ទំនាក់ទំនងមេធាវីជាទំនាក់ទំនងពិសេសដោយឡែក ក្នុងការប្រកបវិជ្ជាជីវៈ ដោយសេរី និងឯករាជ្យ ក្នុងវិស័យគតិយុត្តិ។

### ២.៤.២. ទំនាក់ទំនងជាមួយអតិថិជនច្រើនគ្នា

ការទាក់ទងជាមួយអតិថិជនច្រើនគ្នាដែលពឹងពាក់ក្នុងរឿងក្តី ឬក្នុងការប្រតិបត្តិការតែមួយដូចគ្នា មេធាវីមិនត្រូវកាន់ជើង ផ្តល់ប្រយោជន៍ឱ្យតែអតិថិជនណាមួយឡើយ។ មេធាវីត្រូវតែជូនដំណឹងទៅភាគីទាំងអស់ដោយគ្រប់ៗគ្នា។ បើប្រសិនកើតឡើងនូវទំនាស់ផលប្រយោជន៍គ្នាណាមួយ។ ប្រសិនជារឿងនេះកើតឡើងមែនក្នុងពេលដែលមេធាវីធ្លាប់ជាទីប្រឹក្សារបស់ភាគីច្រើនគ្នានោះ មេធាវីនឹងអាចការពារប្រយោជន៍ភាគីណាមួយបានលុះត្រាតែទៅជម្រាបទៅភាគីឯទៀតឱ្យបានដឹងសិន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពគួរសមថ្លៃថ្នូរ និងអាថ៌កំបាំងវិជ្ជាជីវៈផង។

### ២.៤.៣. ទំនាក់ទំនងជាមួយអតីត អតិថិជន

ក្នុងរឿងតុលាការមេធាវីដែលបានផ្តល់យោបល់ ឬបានជួយ ឬបានតំណាងភាគីណាមួយ មិនអាចទៅធ្វើអន្តរាគមន៍ជួយខាងគូប្រឆាំងក្នុងរឿងក្តីដដែល ឬនៅក្នុងរឿងដែលពាក់ព័ន្ធនឹងរឿងក្តីដដែលបានឡើយ។ ក្នុងគ្រប់រឿងទាំងអស់មេធាវីនិងអាចធ្វើអន្តរាគមន៍ប្រឆាំងនិងកូនក្តី ដែលខ្លួនធ្លាប់បានជួយពីលើកមុន បានតែក្នុងលក្ខខណ្ឌតឹងរឹងនៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ និងភាពគួរសមថ្លៃថ្នូរប៉ុណ្ណោះ។ បទបញ្ញត្តិនេះ ត្រូវអនុវត្តលើគ្រប់មេធាវីទាំងអស់ដែលធ្វើការនៅក្នុងរចនាសម្ព័ន្ធតែមួយរួមគ្នាហើយទៅលើសហការី ឬនិយោជិតទាំងអស់។ មេធាវីទាំងឡាយណា ដែលជាសមាជិកនៃក្រុមប្រមូលផ្តុំមធ្យោបាយអាចនិងត្រូវបានផ្តល់យោបល់ ឬតំណាង

[27] មាត្រា ១៨ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

ភាគីនានាដែលមានប្រយោជន៍ប្រឆាំងគ្នា បានលុះត្រាតែមានការយល់ព្រមពីអតិថិជនរៀងៗខ្លួន និងក្នុងលក្ខខណ្ឌនៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ។[28]

### ២.៤.៤. ទំនាក់ទំនងអតិថិជនជាប់ឃុំ

មេធាវីត្រូវតែប្រុងប្រយ័ត្នឱ្យហ្មត់ចត់ កុំឱ្យអតិថិជនរបស់ខ្លួននូវមធ្យោបាយអ្វីទាំងអស់ ដែលសម្រាប់ឱ្យរត់រួចពីដំណើរការធម្មតារបស់តុលាការ ឬដែលសម្រាប់បំភាន់ការស៊ើបសួរជាដំបូង។ មេធាវីត្រូវហាមឃាត់មិនឱ្យប្រគល់ ទៅឱ្យអតិថិជនរបស់ខ្លួន ឬផ្ញើពីក្រៅនូវវត្ថុ ឬឯកសារ ឬសំបុត្រ ឬសារតាមសំដីទាំងឡាយ លើកលែងតែមានសេចក្តីអនុញ្ញាតពីចៅក្រមស៊ើបសួរ (ក្នុងករណីជាប់ឃុំបណ្តោះអាសន្ន) ឬពីអាជ្ញាធរពន្ធនាគារ (បើសិនជាអតិថិជនត្រូវជាប់ទោសគុកជាស្ថាពររួចហើយ)។[29]

### ២.៤.៥. ទំនាក់ទំនងជាមួយភាគីម្ខាងទៀត និងសាក្សី

មេធាវីត្រូវមានទំនាក់ទំនងជាមួយភាគីម្ខាងទៀត ក្នុងការចរចារដោះស្រាយទាក់ទងទៅនឹងរឿងក្តី។ ការមានទំនាក់ទំនងល្អជាមួយភាគីម្ខាងទៀត មានភាពងាយស្រួល ដោយជួបពិភាក្សាគ្នាទៅវិញទៅមក ដោយមិនឆ្លងទៅក្នុងប្រព័ន្ធតុលាការដែលមានលក្ខណៈស្មុគស្មាញខ្លាំង មេធាវីអាចជួយដោះស្រាយក្រៅប្រព័ន្ធតុលាការបាន។ ចំណែកសាក្សីគឺជាបុគ្គលដែលសំខាន់នៅក្នុងរឿងក្តី សាក្សីអាចដឹងឮ នូវរឿងហេតុដែលបង្កហេតុដោយភាគី សាក្សីដើរតួយ៉ាងសំខាន់ក្នុងដំណើរស្វែងរកឱ្យឃើញនូវយុត្តធម៌ក្នុងរឿងក្តី។

## ២.៥. ទំនាក់ទំនងជាមួយតុលាការ

មេធាវី ត្រូវតែមានទំនាក់ទំនងល្អជាមួយតុលាការក្នុងការតាមដាននូវសំណុំរឿងរបស់ខ្លួន។ មេធាវីត្រូវមានទំនាក់ទំនងល្អជាមួយចៅក្រម ក្រឡាបញ្ជី ងាយស្រួលនៅក្នុងការថតចម្លងសំណុំរឿងក្នុងនីតិវិធី ព្រមទាំងមានភាពងាយស្រួលនៅក្នុងការតាមដានសំណុំរឿងរបស់ខ្លួន។

### ២.៥.១. ទំនាក់ទំនងជាមួយចៅក្រម

ទំនាក់ទំនងភាគច្រើននៅក្នុងសង្គម តែងតែស្ថិតនៅក្នុងក្របខណ្ឌនៃប្រភេទរឿងព្រហ្មទណ្ឌ។ ទំនាស់នេះ ជាសមត្ថកិច្ចដោះស្រាយរបស់ស្ថាប័នគ្រប់ជាន់ថ្នាក់ មានតុលាការខេត្តក្រុង តុលាការយោធា សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ក្នុងទំនាក់ទំនងនេះពេលដែលមេធាវីចូលដល់តុលាការលើកដំបូង ត្រូវទៅជួបប្រធានតុលាការជាមុន ហើយត្រូវសម្តែងនូវការគោរព ដើម្បីសម្តែងការគួរសមចំពោះមុខងារ និងតំណែងរបស់គាត់។ ក្រោយពីសំណេះសំណាលរួចហើយ មេធាវីត្រូវសុំជួបចៅក្រម។ នៅពេលបំពេញកិច្ចក្នុងតុលាការ មេធាវីត្រូវគោរពចំពោះបទបញ្ជាផ្ទៃក្នុងរបស់តុលាការ និងគោរពតាមទម្លាប់ដែលគេធ្លាប់ធ្វើកន្លងមក។ ការគោរពចំពោះ

[28] មាត្រា ២០ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[29] មាត្រា ២១ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

តុលាការគឺសម្តែងភាពថ្លៃថ្នូររបស់មេធាវី មិនត្រូវគោរពហួសហេតុ ដែលធ្វើអោយប៉ះពាល់ភាពថ្លៃថ្នូររបស់មេធាវី។ ម្យ៉ាងវិញទៀតមេធាវីអាចធ្វើការជំទាស់ និងតុលាការផងដែរ នៅពេលដែលតុលាការរំលោភនូវនីតិវិធីព្រមទាំងសិទ្ធិរបស់មេធាវី។[30] មេធាវីត្រូវសម្តែងជូនចៅក្រមក្នុងភាពឯករាជ្យ និងភាពថ្លៃថ្នូរនូវការគោរពទៅតាមមុខងារ។ មេធាវីត្រូវគោរពតាមវិធាននៃនីតិវិធីហើយនឹងទម្លាប់នៃតុលាការ។ មេធាវីមិនត្រូវជាដាច់ខាតប្រើវិធីមិនស្មោះត្រង់ហើយត្រូវតែគោរពវិធីតទល់មុខគ្នា។ មេធាវីក៏មានសិទ្ធិសម្តែងឡើងនូវអ្វីៗដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។ ក្នុងករណីកើតហេតុជាមួយចៅក្រមមេធាវីត្រូវសុំអន្តរាគមន៍ពីប្រធានពីគណៈមេធាវី។ វិបត្តិទាំងឡាយដែលកើតឡើងរវាងសហភាគា ក្រៅតែអំពីការអនុវត្តនៃវិធាននីតិវិធីតុលាការត្រូវធ្វើឡើងទៅរកការសម្រុះសម្រួលនៃប្រធានគណៈមេធាវី។[31]

### ២.៥.២. ទំនាក់ទំនងជាមួយព្រះរាជអាជ្ញា

មេធាវីត្រូវតែទំនាក់ទំនងជាមួយព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ នៅពេលអតិថិជនមកពឹងឱ្យការពាររឿងក្តីព្រហ្មទណ្ឌហើយរឿងក្តីនោះស្ថិតនៅក្នុងដៃព្រះរាជអាជ្ញានៅឡើយ។ (មានសេចក្តីថា ព្រះរាជអាជ្ញាពុំទាន់ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យចៅក្រមស៊ើបសួរនៅឡើយ)។ មេធាវីត្រូវបញ្ជាប់ទំនាក់ទំនងជាមួយព្រះរាអាជ្ញាដើម្បីផ្តល់ជាភស្តុតាង និងសាក្សី ឬនិយាយរៀបរាប់ពីដំណើរហេតុនៃរឿងក្តីដើម្បីឱ្យព្រះរាជអាជ្ញា ពិនិត្យតាមផ្លូវច្បាប់ដែលជាប្រភេទរឿងក្តីព្រហ្មទណ្ឌ ឬរឿងនោះមានពិរុទ្ធភាពសមល្មមគួរឱ្យចោទប្រកាន់ ឬរឿងនោះគ្មានពិរុទ្ធភាព នាំឱ្យលើកលែងចោទប្រកាន់ក្នុងបំណងចោទប្រកាន់ឱ្យបានត្រឹមត្រូវតាមអំពើដែលកូនក្តីបានប្រព្រឹត្ត។ ទំនាក់ទំនងនេះមេធាវីត្រូវសម្តែងជូនព្រះរាជអាជ្ញានូវឥរិយាបទ និងសំដីសំដៅប្រកបដោយឯករាជ្យ ភាពថ្លៃថ្នូរសមរម្យ ដោយគោរពទៅតាមមុខងាររបស់ខ្លួនជានិច្ច។

### ២.៥.៣. ទំនាក់ទំនងជាមួយក្រឡាបញ្ជី

ក្រឡាបញ្ជី ពុំមានសិទ្ធិអំណាចធ្វើការចោទប្រកាន់ស៊ើបអង្កេត ឬកាត់សេចក្តីចាញ់ឈ្នះ។ ក្រឡាបញ្ជីអាចជួយសម្រួលទៅដល់កិច្ចការមេធាវីឱ្យមានដំណើរការក្នុងភាពរលូន ឆាប់រហ័ស និងមិនសូវស្មុគស្មាញ។ មេធាវីក៏ត្រូវមានទំនាក់ទំនងជាមួយក្រឡាបញ្ជីដូចជាមេធាវីសុំថតសំណុំរឿង ចៅក្រមតែងប្រគល់ភារកិច្ចនេះឱ្យក្រឡាបញ្ជីទទួលខុសត្រូវ មេធាវីទាក់ទងជាមួយក្រឡាបញ្ជី ដើម្បីសុំថត និងចម្លងសុំណុំរឿង។ មេធាវីត្រូវទាក់ទងក្រឡាបញ្ជីមានភារៈកិច្ចជាច្រើនទៀតដូចជា ការសុំសម្រង់សាលក្រម សាលដីកា ការសុំឱ្យក្រឡាបញ្ជីរៀបចំសំណុំរឿងឱ្យឆាប់រហ័សដើម្បីបញ្ជូនមកសាលាឧទ្ធរណ៍ ឬតុលាការកំពូល។ កិច្ចការទាំងនេះគឺក្រឡាបញ្ជីជាអ្នកធ្វើមេធាវីត្រូវមានទំនាក់ទំនងល្អមានភាពធូរស្រាលមួយកម្រិត និងចំណេញពេលវេលាសម្រាប់មេធាវី

[30] មាត្រា ២៤ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[31] មាត្រា ២៤ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

ដែលអាចបន្តការងារផ្សេងទៀត។ ទំនាក់ទំនងជាមួយក្រឡាបញ្ជីគឺប្រព្រឹត្តក្នុងឥរិយាបទសមរម្យ និងថ្លៃថ្នូរទៀតផងហើយក៏ត្រូវតែគោរពមុខងាររបស់ក្រឡាបញ្ជីផងដែរ។ ដូចនេះ មេធាវីត្រូវតែមានការទំនាក់ទំនងល្អជាមួយក្រឡាបញ្ជី ចៅក្រម ព្រះរាជអាជ្ញា គឺទំនាក់ទំនងចាំបាច់ ព្រមទាំងញឹកញាប់ទៀតផង។

### ២.៥.៤. ទំនាក់ទំនងជាមួយសហភាគា នៃសមាជិកនៃវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា

គ្រប់ការទំនាក់ទំនងរវាងមេធាវីខ្លួនឯង ត្រូវប្រព្រឹត្តនៅក្នុងស្មារតីនៃសហភាគាសមរម្យ និងគួរសមជានិច្ច។ ក្នុងការគោរពផលប្រយោជន៍របស់អតិថិជនរបស់ខ្លួន មេធាវីមិនត្រូវធ្វើអ្វីដែលអាចនាំឱ្យខូចខាតដល់សហភាគានៃខ្លួនឡើយ។ មេធាវីត្រូវជូនដំណឹងជាមុនដល់បដិវាទករអំពីការសុំផ្អាកពេល ព្រមទាំងការចាប់ផ្តើមនីតិវិធីថ្មីណាមួយ លើកលែងតែមានការចាំបាច់ផ្ទុយទៅវិញ ក្នុងគោលប្រយោជន៍ដល់អតិថិជន។ មេធាវីត្រូវប្រាប់បដិវាទករឱ្យដឹងអំពីឧបាស្រ័យដែលខ្លួនបានធ្វើ។ មេធាវីត្រូវជៀសវាង មិនឱ្យមានការយឺតយ៉ាវក្នុងការផ្តល់ និងការទំនាក់ទំនងនានាឱ្យសោះ ហើយត្រូវប្រគល់ច្បាប់ដើមទាំងអស់ នៃឯកសារដែលខ្លួនបានទទួល ដោយគ្មានបង្អែបង្អន់ឡើយ។ ទោះជាក្នុងករណីណាក៏ដោយ មេធាវីក៏មិនត្រូវប្រគល់ឯកសារទាំងអស់នេះទៅអតិថិជនរបស់ខ្លួនឡើយ។ ការប្រជុំ ឬការណាត់ជួបគ្នាត្រូវកំណត់ដោយកិច្ចព្រមព្រៀងជាមួយគ្នា ឱ្យសមស្របនឹងអធ្យាស្រ័យរៀងៗខ្លួន។ លំដាប់ថ្នាក់ហៅចូលសវនាការត្រូវចាត់ឡើងស្មើភាពគ្នាទាំងអស់រវាងសហភាគា លើកលែងតែប្រធានគណៈមេធាវីដែលត្រូវហៅមុនគេ។ ទំនាស់សព្វយ៉ាងដែលកើតឡើងរវាងសហភាគា ត្រូវបានដោះស្រាយដោយប្រធានគណៈមេធាវី។ [32]

### ២.៥.៥. ទំនាក់ទំនងជាមួយគណៈមេធាវី

មេធាវីទាំងអស់ជាសមាជិកនៃគណៈមេធាវី។ គណៈមេធាវីមានសេវាជូនមេធាវី ជួយជ្រោមជ្រែងមេធាវី និងការពារមេធាវី។ គណៈមេធាវី តំណាងមេធាវី គ្រប់គ្រងកិច្ចការរួមនៃមន្ទីរគណៈមេធាវី ជាពិសេសការពារក្តី និងការចូលទៅតុលាការ។ ដោយអាកប្បកិរិយាល្អ មេធាវីម្នាក់ៗ ត្រូវជាអ្នកទទួលខុសត្រូវចំពោះកេរ្តិ៍ឈ្មោះរបស់គណៈមេធាវីចំពោះអំណាចរបស់គណៈមេធាវី និងអំពីប្រសិទ្ធិផលនៃក្រុមប្រឹក្សាគណៈមេធាវី។ [33] ដូចនេះមេធាវីត្រូវមានទំនាក់ទំនងល្អជាមួយគណៈមេធាវី ក្នុងការជួយលើកស្ទួយទៅដល់គណៈមេធាវី ដែលមានការគ្រប់គ្រងទៅលើមេធាវីគ្រប់រូបក្នុងការបណ្តុះមេធាវីដែលទទួលបាននូវចំណេះដឹង និងមានសមត្ថភាពនៅក្នុងវិជ្ជាជីវៈ ហេតុដូចនេះហើយ គណៈមេធាវីតែងតែបើកវគ្គបណ្តុះបណ្តាល និងមានការពន្យល់ទៅដល់មេធាវីគ្រប់រូបក្នុងការតាំងខ្លួនជាមេធាវីល្អម្នាក់ នៅក្នុងសង្គម ដែលមានការប្រកបវិជ្ជាជីវៈមួយដែលត្រឹមត្រូវទៅតាមច្បាប់។ មេធាវីត្រូវតែមានទំនាក់ទំនងល្អជាមួយគណៈមេធាវី។

[32] មាត្រា ២៥ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[33] មាត្រា ៣៤ ក្រមសីលធម៌មេធាវីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

# ជំពូកទី៣
# តួនាទីសំខាន់ៗរបស់មេធាវីក្នុង
# ដំណាក់កាលនៃនីតិវិធី

# ជំពូកទី៣
# តួនាទីសំខាន់ៗរបស់មេធាវីក្នុងដំណាក់កាលនៃនីតិវិធី

ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្ដល់នូវភារកិច្ចជូនមេធាវីអ្នកការពារសិទ្ធិឱ្យជនល្មើស និងការពារសិទ្ធិឱ្យទៅជនរងគ្រោះទៅតាមដំណាក់កាលនីមួយៗនៃនីតិវិធី។ មុនពេលដែលជនជាប់ឃុំត្រូវបានគេបញ្ជូនមកដល់ពន្ធនាគារ ជនជាប់ឃុំត្រូវបានឃាត់ខ្លួននៅមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀតស្ថិតនៅក្នុងដំណាក់កាលឃាត់ខ្លួននេះ អាចមានសិទ្ធិស្នើសុំមេធាវីដើម្បីការពារខ្លួន។ ក្នុងករណីដែលមេធាវីជាអ្នកការពារសិទ្ធិឱ្យជនល្មើស។ មេធាវីមានតួនាទីចូលរួមពិនិត្យមើលអំពីការទទួលស្គាល់ និងប្រើប្រាស់សិទ្ធិសម្រាប់ជនល្មើសពីសំណាក់អាជ្ញាធរសមត្ថកិច្ចតាមដំណាក់កាលនីតិវិធី។ ចំពោះតួនាទីមេធាវីក៏ដើរតួយ៉ាងសំខាន់ នៅនីតិវិធីព្រហ្មទណ្ឌផងដែរ។

## ៣.១. ដំណាក់កាលស៊ើបអង្កេតដោយនគរបាលយុត្តិធម៌

ដំណាក់កាលស៊ើបអង្កេតបឋម មេធាវីអមជាមួយជនសង្ស័យ ដែលជននេះផ្ដល់ចម្លើយតាមការសាកសួរពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីដែលជនសង្ស័យគ្មានមេធាវីហើយត្រូវបានឃាត់ខ្លួន ឬជនល្មើសត្រូវបានឃាត់ខ្លួនក្នុងបទល្មើសជាក់ស្ដែង ជននេះអាចមានសិទ្ធិមានមេធាវីបាន។ បន្ទាប់ពីមានការឃាត់ខ្លួនក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោងបានកន្លងផុតទៅ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា បានធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើហិង្សា ដើម្បីឱ្យជនល្មើស ឬជនជាប់សង្ស័យផ្ដល់ចម្លើយតាមការបង្ខំ ឬឱ្យឆ្លើយសារភាព មេធាវីអាចប្ដឹងលើកំណត់ហេតុនោះទុកជាមោឃៈ ដើម្បីដកចេញពីសំណុំរឿង។ ដំណាក់កាលស៊ើបអង្កេតបឋមនេះ ត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ដើរតួយ៉ាងសំខាន់ក្នុងការធានានូវប្រសិទ្ធិភាពនៃបណ្ដឹងអាជ្ញា និងការស្វែងរកនូវភស្តុតាងដាក់បន្ទុកជនល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ជាជំនួយការស្ថាប័នតុលាការ និងស្ថាប័នអយ្យការ និងមានភារកិច្ចធ្វើការត្រួតពិនិត្យបទល្មើស បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។[34] សមាសភាពរបស់នគរបាលយុត្តិធម៌រួមមាន មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យធ្វើការត្រួតពិនិត្យបទល្មើសខ្លះៗក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។ [35]ដូចនេះដំណាក់កាលស៊ើបអង្កេត ដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ ក្រោមការត្រួតពិនិត្យ និងការទទួលខុសត្រូវពីព្រះរាជអាជ្ញា និងតំណាងអយ្យការ ដែលជាជំនួយការរបស់អំណាចតុលាការ។ មេធាវីនៅក្នុងដំណាក់កាលស៊ើបសួរ មានសិទ្ធិការពារជនល្មើស ក្នុងការការពារមិនឱ្យមានការចាប់បង្ខំ។

[34] មាត្រា ៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[35] មាត្រា ៥៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

### ៣.១.១. តួនាទីមេធាវីក្នុងការស៊ើបអង្កេតជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌

អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង។[36] បទល្មើសជាក់ស្តែងរួមមានបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ និងមានបទល្មើសជាក់ស្តែង គឺជាបទល្មើសដែលកំពុងតែប្រព្រឹត្ត ឬបទល្មើសដែលប្រព្រឹត្តរួចរាល់ភ្លាមៗ។ គ្រប់អំពើដែលសន្មតថាជាបទល្មើសជាក់ស្តែង។ កាលណាការប្រព្រឹត្តអំពើទុច្ចរិតរួចភ្លាមៗ ហើយជនសង្ស័យដែលជាជនប្រព្រឹត្តបទល្មើសត្រូវបានសាធារណៈជនស្រែក ហើយមានការដេញប្រផាប់ចាប់ប្រភីង ឬជនដែលត្រូវបានគេរកឃើញមានវត្ថុ ឬស្លាកស្នាម តម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាដែលនាំឱ្យគេអាចសន្និដ្ឋានបានថាបុគ្គលនោះពិតជាបានប្រព្រឹត្តបទល្មើស ឬបានចូលរួមប្រព្រឹត្តបទល្មើស។[37] ហើយត្រូវបានចាត់ទុក ដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ។ ខាងលើក៏ដោយគ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងរបស់អ្នកកាន់កាប់នៅទីនោះត្រូវមានការសុំពីព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។[38] ការឃុំខ្លួន ឬចាប់ខ្លួនតែងតែកើតមានឡើងនៅពេលមានពាក្យបណ្តឹង ដោយសារមានការប្រពឹត្តបទល្មើសជាក់ស្តែង។ អាជ្ញាធរអាចឃុំខ្លួន ឬចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើឬលើសពី ០១ (មួយ) ឆ្នាំឡើងទៅ។ ចំពោះនីតិជន ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០៦ (ប្រាំមួយ) ខែបានទេប៉ុន្តែនៅពេលផុតថិរវេលានេះចៅក្រមស៊ើបសួរ អាចពន្យាពេល ក្នុងការឃុំខ្លួនជាបណ្តោះអាសន្នបាន ០៦ (ប្រាំមួយ) ខែដោយដីកាមានសម្អាងហេតុយ៉ាងត្រឹមត្រូវនិងច្បាស់លាស់។ ចៅក្រមស៊ើបសួរ អាចសម្រេចពន្យាការឃុំខ្លួនបណ្តោះអាសន្នបានតែ ០២ (ពីរ) ដងគត់។[39] ចំពោះនីតិជន ក្នុងបទមជ្ឈិមការឃុំខ្លួនមិនអាចលើសពី ០៤ (បួន) ខែបានទេ ហើយអាចពន្យាពេលបាន ០២ (ពីរ) ដងតែប៉ុណ្ណោះ។

### ៣.១.២. តួនាទីមេធាវីក្នុងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងដំណាក់កាលស៊ើបអង្កេត មេធាវីមានភារកិច្ចអមជាមួយជនរងគ្រោះ ដើម្បីចូលបំភ្លឺអង្គហេតុតាមការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា។ ដំណើរការនៃការស៊ើបអង្កេតបឋម ត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីដែលមានបទល្មើស បទឧក្រិដ្ឋ បទមជ្ឈិម បទលហុជាដើម។ ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមបានកើតឡើង មន្ត្រីនគរបាលយុត្តិធម៌

[36] មាត្រា ៨៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[37] មាត្រា ៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[38] មាត្រា ៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[39] មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ ការស៊ើបអង្កេតបឋម ដែលមានបទល្មើសឧក្រិដ្ឋជាក់ស្តែង ឬក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុតទៅ។ ដោយថេរវេលានៃការស៊ើបអង្កេតនេះ បទល្មើសជាក់ស្តែង មិនអាចលើសពី ០៧ (ប្រាំពីរ) ថ្ងៃគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។ កិច្ចស៊ើបអង្កេត ត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ។ ប្រសិនបើការស៊ើបអង្កេត មិនបានបញ្ចប់ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្រ្តីនគរបាលយុត្តិធម៌ ត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា។[40]អំណាច និងកាតព្វកិច្ចរបស់មន្រ្តីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមមានលក្ខណៈប្រហាក់ប្រហែល អំណាច និងកាតព្វកិច្ចរបស់មន្រ្តីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ដោយគ្រាន់តែបទបញ្ញត្តិយោងមានភាពខុសគ្នា។ វិធានទាក់ទងនឹងការស៊ើបអង្កេតបឋមរបស់មន្រ្តីនគរបាលយុត្តិធម៌មានដូចជា៖

អនុលោមដោយមានការចែងអំពីការឆែកឆេរ ត្រូវធ្វើឡើងដោយមន្រ្តីនគរបាលយុត្តិធម៌៖[41]

- កាលណាការស៊ើបអង្កេតជាបឋមនោះ ទាក់ទងនិងបទឧក្រិដ្ឋ ឬបទមជ្ឈឹម មន្រ្តីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។
- មន្រ្តីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។
- ការយល់ព្រមនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរនោះ ត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុង កំណត់ហេតុថាយល់ យល់ព្រមឱ្យឆែកឆេរ។
- ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ការឆែកឆេរនេះ ត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែងប្រសិនគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី ០២នាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា និងសាក្សីមិនអាចជាមន្រ្តីនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។
- ការឆែកឆេរ មិនអាចចាប់ផ្តើមមុនម៉ោង ០៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ។ ខាងលើនេះគឺជាសមត្ថកិច្ចរបស់មន្រ្តីនគរបាលយុត្តិធម៌ ដែលអនុលោមតាមការឆែកឆេរក្នុងការចាប់យកវត្ថុតាង ពីជនប្រព្រឹត្តនៅក្នុងរឿងហេតុ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។

[40] មាត្រា ១០៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[41] មាត្រា ១១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ក្នុងករណីនេះជនសង្ស័យអាចណាត់សុំជួបមេធាវីតំណាងរបស់ខ្លួនដើម្បីពិភាក្សា មុននិងយល់ព្រមក៏ដូចជាសួរនាំពីរបៀបឆ្លើយតបទៅនឹងមន្រ្តីនគរបាលយុត្តិធម៌ ជៀសវាងមន្រ្តីនគរបាលយុត្តិធម៌ បំពានទៅលើសិទ្ធិរបស់ខ្លួន។ ម៉្យាងវិញទៀតមន្រ្តីនគរបាលយុត្តិធម៌ ពុំអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីនោះទេ ដោយមានការបំពានសិទ្ធិទៅលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលទោស។

មេធាវីក្នុងករណីនេះពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការអមជនសង្ស័យ(កូនក្តី) នៅក្នុងដំណាក់ចូលឆ្លើយបំភ្លឺនៅមុខមន្រ្តីនគរបាលយុត្តិធម៌ ជនសង្ស័យត្រូវផ្តល់ចម្លើយ តាមការសាកសួររបស់ មន្រ្តីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីដែលជនជាប់សង្ស័យគ្មានមេធាវី ហើយត្រូវបានឃាត់ខ្លួន ឬជនល្មើសត្រូវបានឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង ជនសង្ស័យអាចជួបជាមួយមេធាវីបាន ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោងបានកន្លងផុតទៅនៃការឃាត់ខ្លួនមកនោះ។ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ។ ជននេះ ត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយជាបន្ទាន់។ ជននេះ អាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទីក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ។ ក្រោយសន្ទនាជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។ [42] ប្រសិនបើមន្រ្តីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា បានធ្វើទារុណកម្មប្រព្រឹត្តអំពើហិង្សា ដើម្បីឱ្យជនសង្ស័យផ្តល់ចម្លើយតាមការបង្ខំ ឬឱ្យឆ្លើយសារភាពមេធាវី អាចប្តឹងលើកំណត់ហេតុនោះទុកជាមោឃៈ ដើម្បីដកចេញពីសំណុំរឿង។ កំណត់ហេតុនៅដំណាក់កាលស៊ើបអង្កេតជាឯកសារដើម ដែលត្រូវបានរក្សាទុកក្នុងសំណុំរឿង។ ហេតុនេះកាលណាគ្មានភស្តុតាងផ្ទុយទេ តុលាការនិងសម្រេចដោយយោងលើកំណត់ហេតុដែលជាភស្តុតាងដាក់បន្ទុក។

### ៣.១.៣.សិទ្ធិទទួលបានមេធាវីរបស់ជនសង្ស័យ

មេធាវី មានតួនាទីយ៉ាងសំខាន់ណាស់ក្នុងការការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់ ដើម្បីឱ្យដំណើរការកាត់ក្តីមួយប្រកបដោយយុត្តិធម៌។ ជនសង្ស័យមានសិទ្ធិក្នុងការមិននិយាយស្តី ឬឆ្លើយតាមការសាកសួរអ្វីទាំងអស់ដែលខ្លួនគិតថាមានការគៀបសង្កត់ឱ្យខ្លួនទទួលសារភាពនូវកំហុស ឬអ្វីដែលខ្លួនមិនបានប្រព្រឹត្ត។ មេធាវីអាចអមកូនក្តីរបស់ខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី។ មេធាវីអាចដំណើរការកិច្ចនីតិវិធីបានតាមរយៈពាក្យសុំការពារក្តី ដែលកូនក្តីរបស់ខ្លួនបានប្រគល់សិទ្ធិជូនឱ្យតំណាងឱ្យខ្លួន ដើម្បីការពារនូវផលប្រយោជន៍ស្របច្បាប់។ វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈ ឯករាជ្យ និងសេរី ដែលចូលរួមបម្រើវិស័យយុត្តិធម៌ដែលមិនអាចជៀតជ្រែកបានក្នុងការការពារកូនក្តីរបស់ខ្លួន។ ប្រសិនបើគ្មានមេធាវីការពារសិទ្ធិនោះទេនោះ ដំណើរការនីតិវិធីមិនអាចប្រព្រឹត្តទៅដោយតម្លាភាពនោះទេ។

[42] មាត្រា ៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ជនសង្ស័យ ដែលត្រូវបានឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិរក្សាភាពស្ងៀមស្ងាត់ មិនឆ្លើយនូវសំណួររបស់មន្ត្រីនគរបាលយុត្តិធម៌ រហូតចាំដល់ជំនួយរបស់មេធាវី បានមកដល់ហើយ គ្មាននរណាម្នាក់អាចបង្ខំឱ្យឆ្លើយសារភាពបានឡើយ។ សិទ្ធិមិនឆ្លើយសារភាពជនល្មើស ដែលត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួនមិនត្រូវឆ្លើយអ្វីដែលខ្លួនមិនបានប្រព្រឹត្តនោះទេ ឬអាចឆ្លើយសារភាពរហូតខ្លួនមានមេធាវីការពារសិទ្ធិ ដោយគ្មាននរណាម្នាក់អាចបង្ខំឱ្យសារភាពថាបានប្រព្រឹត្តបទល្មើសណាមួយ ដោយការគម្រាមកំហែង ការវាយដំធ្វើទារុណកម្មណាមួយនោះទេ។ រាល់ការសារភាពដែលកើតចេញពីការបង្ខំតាមផ្លូវកាយក្តី ការគម្រាមកំហែងក្តី ការវាយដំការធ្វើទារុណកម្មឱ្យជនល្មើសសារភាព មិនត្រូវបានចាត់ទុកជាភស្តុតាងសម្រាប់ដាក់ពិរុទ្ធនោះទេ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ថាមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនគ្រប់ជនទាំងឡាយណាដែលមានការសង្ស័យ ឬមានការចង្អុលបង្ហាញថាមានភាពសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ក្នុងករណីដែលបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។ [43] មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិឃាត់បុគ្គលដែលសង្ស័យ ថាបានចូលរួមប្រព្រឹត្តបទល្មើសក្រៅពីបុគ្គល ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសក្រៅពីបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើសបុគ្គលដែលអាចផ្តល់ពត៌មានពីបទល្មើស ឬដំណើររឿងហេតុបានផងដែរ។ លើសពីនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបុគ្គលទៅបានលុះត្រាតែបុគ្គលនោះប្រកែកមិនព្រមផ្តល់ពត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ [44] មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ។ ការឃាត់ខ្លួនមានចិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ចិរវេលាត្រូវគិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះបទឧក្រិដ្ឋកាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យាពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យាពេលនេះត្រូវសុំទៅ ព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ការអនុញ្ញាតឱ្យពន្យាពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសម្អាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យាពេលគឺជាវិធានការពិសេស ការពន្យាពេលមិនអាចលើសពី២៤ (ម្ភៃបួន) ម៉ោងទេ ដោយមិនគិតពីចិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។ ការពន្យាពេលមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។

រយៈពេលនៃការឃាត់ខ្លួនប្រែប្រួលទៅតាមប្រភេទបទល្មើសនីមួយៗដូចខាងក្រោម៖

---

[43] មាត្រា ៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[44] មេរៀននីតិវិធីព្រហ្មទណ្ឌរៀបរៀងដោយលោកស្រី ឌី លីឡា និង លោក ខាន់ សុខា។

**៣.១.៣.១. ចំពោះបទឧក្រិដ្ឋ**

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ (សាមសិបប្រាំមួយ) ម៉ោងឡើយ។ ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោងឡើយ។

**៣.១.៣.២. ចំពោះបទមជ្ឈិម**

អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ (ម្ភៃបួន) ម៉ោងឡើយ។ អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ (សាបសិបប្រាំមួយ) ម៉ោងឡើយ។

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។[45]កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជនមន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនពត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជនទេ។[46] ក្នុងរយៈពេលនៃការឃាត់ខ្លួននេះ មេធាវីទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយកូនក្តីដែលជាអនីតិជនបានដោយមានលក្ខណៈឯកជន និងសម្ងាត់។ ប្រសិនបើមានការស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) នាទី ដែលត្រូវធ្វើមុនពេលស្តាប់ចម្លើយជាមួយគ្នានេះផងដែរ បច្ចុប្បន្នដើម្បីសម្រួលដល់ការប្រឹក្សាយោបល់រវាងមេធាវី និងកូនក្តីនៅតាមតុលាការ ឬមន្ទីរឃុំឃាំងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានសាងសង់បន្ទប់ ដើម្បីរក្សានូវការសម្ងាត់ជូនជនសង្ស័យ។ ករណីគ្មានវត្តមានមេធាវីអនីតិជន អាចមានសិទ្ធិមិនផ្តល់ចម្លើយបាន ដោយការស្តាប់ចម្លើយត្រូវបានប្រព្រឹត្តដោយមានវត្តមានមេធាវី។ ករណីអវត្តមានមេធាវីរបស់អនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាន ហើយបញ្ចូលក្នុងសំណុំរឿង។ នៅពេលបញ្ចប់ការស្តាប់ចម្លើយ ហើយមេធាវីអាចអានកំណត់ហេតុស្តាប់ចម្លើយបាន។ លើសពីនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ ដែលធ្វើឡើងដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹង ទៅអ្នកតំណាងដែលច្បាប់បានកំណត់មេធាវីរបស់អនីតិជន ទោះបីការជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី។ មេធាវីក៏អាចស្នើសុំច្បាប់ចម្លងនៃកំណត់ហេតុ ស្តីពីការចាប់ខ្លួននិងកំណត់ហេតុសរុប នៃការឃាត់ខ្លួនអនីតិជនបានផងដែរ។

## ៣.២. ដំណាក់កាលចោទប្រកាន់ដោយព្រះរាជអាជ្ញា

នៅពេលបញ្ចប់ការឃាត់ខ្លួនបុគ្គលដែលឃាត់ខ្លួន ត្រូវបញ្ជូនមកដើម្បីចូលរួមបង្ហាញនៅចំពោះមុខព្រះរាជអាជ្ញា។ បន្ទាប់មកព្រះរាជអាជ្ញា ត្រូវប្រាប់ឱ្យដឹងពីសិទ្ធិទទួលបានមេធាវីតាមការជ្រើសរើស ឬតាមរយៈការ

[45] មាត្រា ៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[46] មាត្រា ១០០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ចាត់តាំងរបស់គណៈមេធាវី។ នៅក្នុងដំណាក់កាលចោទប្រកាន់នេះ មេធាវីក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងអំឡុងពេលស្តាប់ចម្លើយជនសង្ស័យបានដែរ។ ការអនុវត្តតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ព្រះរាជអាជ្ញាមានជម្រើសមធ្យោបាយនៃការចោទប្រកាន់អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង នីតិវិធីដែលធ្វើរួចរាល់អាចបញ្ជូនទៅតុលាការជំនុំជម្រះ ឬផ្អុយទៅវិញ តម្រូវឱ្យមានការស៊ើបសួរទូលំទូលាយពោល គឺអាចប្តឹងទៅយុត្តាធិការជំនុំជម្រះ ឬប្តឹងទៅយុត្តាធិការស៊ើបសួរ។

### ៣.២.១.ការប្តឹងទៅយុត្តាធិការស៊ើបសួរតាមរយៈ(ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)

នៅក្នុងដំណាក់កាលនេះ មេធាវីមានតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបអង្កេត ឬស្វែងរកនូវភស្តុតាងដោះបន្ទុក ឬភស្តុតាងដាក់បន្ទុក ដែលខ្លួនយល់ឃើញថាជាផលប្រយោជន៍ចំពោះកូនក្តីរបស់ខ្លួន។ ចំពោះការស្វែងរកភស្តុតាងនេះទៀតសោត ត្រូវធ្វើឡើងជាសម្ងាត់ ដើម្បីធានានូវផលប្រយោជន៍ជូនកូនក្តីរបស់ខ្លួន។ ម៉្យាងវិញទៀត មេធាវីអាចស្វែងរក នឹងសម្ភាសន៍កូនក្តីរបស់ខ្លួនដើម្បីស្វែងរកនូវ តម្រុយដែលជាផលប្រយោជន៍ភស្តុតាងនានា ដែលទាក់ទងទៅនឹងអង្គហេតុដែលជាមធ្យោបាយសម្រាប់ខ្លួនស្វែងរកឱ្យឃើញនូវការពិតអំពីរឿងក្តី។ ក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន សេចក្តីសង្ខេបនៃអង្គហេតុការកំណត់ឈ្មោះបទល្មើសការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស នឹងឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទនិងចុះហត្ថលេខា។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។ [47]

### ៣.២.២. វត្តមានមេធាវីក្នុងពេលស្តាប់ចម្លើយ

ប្រសិនព្រះរាជអាជ្ញាបានធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើហិង្សាដើម្បីឱ្យជនល្មើស ឬជនជាប់សង្ស័យផ្តល់ចម្លើយតាមការបង្ខំ ឬឱ្យឆ្លើយសារភាពមេធាវី អាចប្តឹងលើកំណត់ហេតុនោះទុកជាមោឃៈ ដើម្បីដកចេញពីសំណុំរឿង។ ព្រះរាជអាជ្ញា ត្រូវធ្វើការចាត់តាំងមេធាវីដោយមិនយកកម្រៃឱ្យអនីតិជន។ ករណីជាអនីតិជនការស្តាប់ចម្លើយត្រូវធ្វើឡើងជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារារាត្រី។ ការស្តាប់ចម្លើយត្រូវមានវត្តមានមេធាវីបន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយ ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឱ្យមេធាវីអានកំណត់ហេតុស្តាប់ចម្លើយ និងត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។ ករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ។ ការចោទប្រកាន់

[47] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

របស់ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជន និងត្រូវជូនដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន។

## ៣.៣. ដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក។[48] ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ គឺសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ដែលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គល ពោលគឺចៅក្រមស៊ើបសួរតែប៉ុណ្ណោះទេ តួនាទីស្វែងរកភស្តុតាងផងដែរ។ ការស៊ើបសួរត្រូវតែធ្វើខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈឹម ការស៊ើបសួរអាចធ្វើ ឬមិនធ្វើក៏បាន។[49] ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ច គឺចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។ យ៉ាងណាមិញក្នុងដំណាក់កាលចៅក្រមស៊ើបសួរនេះ មេធាវីក៏នៅតែបន្តតួនាទីរបស់ខ្លួន ដើម្បីការពារដល់ជនត្រូវចោទ គ្រប់ដំណាក់កាលនៃកិច្ចនីតិវិធីជាពិសេសនៅក្នុងដំណាក់កាលស៊ើបសួរនេះផ្ទាល់។

មេធាវី ក៏មានតួនាទីក្នុងការត្រួតពិនិត្យអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការការពារសិទ្ធិរបស់ជនត្រូវចោទដែលជាកូនក្ដីរបស់ខ្លួន ជៀងវាងមានការបំពានទៅលើសិទ្ធិរបស់កូនក្ដី។ មេធាវីមានសិទ្ធិដឹង រាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរលើជនត្រូវចោទតាមរយៈការជូនដំណឹង។ មេធាវីមានតួនាទី ត្រួតពិនិត្យអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការការពារសិទ្ធិ របស់ជនត្រូវចោទដែលជាកូនក្ដីរបស់ខ្លួន ជៀសវាងមានការបំពានសិទ្ធិរបស់ជនត្រូវចោទ។ មេធាវីមានសិទ្ធិដឹងរាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរលើជនត្រូវចោទតាមរយៈការជូនដំណឹង។ នៅក្នុងដំណាក់កាលស៊ើបសួរមេធាវីអាចធ្វើការស្នើសុំបំពេញកិច្ចនានា ដែលខ្លួនយល់ថាចាំបាច់ដើម្បីបំភ្លឺការពិតតាមរយៈការប្រគល់សិទ្ធិពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។

ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។[50] ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។[51] ដូចនេះ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ មេធាវីត្រូវជួយលើកយកភស្តុតាង ជូនកូនក្ដីរបស់ខ្លួន។

[48] មាត្រា ១២៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[49] មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[50] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[51] មាត្រា ១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

### ៣.៣.១. កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ

#### ៣.៣.១.១. វត្តមានមេធាវីក្នុងពេលសួរចម្លើយរបស់ជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ គឺដើម្បីទទួលបានពត៌មានពាក់ព័ន្ធទៅនឹងបទល្មើសហើយ ជាដំណាក់កាលមួយក្នុងការបំភ្លឺឱ្យកាន់តែច្បាស់នូវអង្គហេតុណាមួយ។ មុននឹងសួរចម្លើយជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ជនត្រូវចោទមកសួរចម្លើយ មុនរយៈពេលយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃ។ មុនពេលសួរចម្លើយជនត្រូវចោទ ចៅក្រមស៊ើបសួរមិនអាចសួរចម្លើយដោយគ្មានមេធាវីការពារជនត្រូវចោទបានឡើយ។ ក្នុងករណីដែលចៅក្រមស៊ើបសួរ បានកោះហៅមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទ ប៉ុន្តែមេធាវីមិនបានបង្ហាញខ្លួនតាមការកំណត់ ចៅក្រមស៊ើបសួរអាចសួរចម្លើយដោយពុំមានវត្តមានមេធាវីការពារសិទ្ធិបាន ហើយចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសទៅលើកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទ ដោយសារមូលហេតុអវត្តមានមេធាវីការពារសិទ្ធិជនត្រូវចោទ។ នៅពេលសួរចម្លើយជនត្រូវចោទមានសំណួរមួយចំនួន មិនអាចធ្វើការសួរលើជនត្រូវចោទបាននោះឡើយហើយសំណួរដែលមិនត្រឹមត្រូវអនុញ្ញាតឱ្យសួរនោះត្រូវចុះកំណត់ហេតុសួរចម្លើយ។ មេធាវីអាចលើកសំណួរមកសួរជនត្រូវចោទបាន នៅពេលដែលចៅក្រមស៊ើបសួរបានសួរចម្លើយចប់។ ករណីជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយចំពោះមុខចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវបានចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌ។ [52] ចៅក្រមស៊ើបសួរ ត្រូវអនុញ្ញាតឱ្យមេធាវីអានកំណត់ហេតុស្តាប់ចម្លើយបានប្រសិនមានការស្នើសុំ។ ក្នុងករណីអនីតិជនមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុសួរចម្លើយ។ បើមេធាវីអវត្តមានចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ លើកលែងតែករណីដែលអាចបាត់បង់តម្រុយនៃភស្តុតាង។ មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំក៏អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលអប់រំកែប្រែ។ ការសន្ទនារបស់មេធាវី និងជនត្រូវចោទមិនអាចត្រូវបានគេស្តាប់ ឬថតបាននោះទេ។ មេធាវីអាចអានលិខិតសំណុំរឿងឱ្យកូនក្តីស្តាប់បាន ប៉ុន្តែមិនអាចឱ្យលិខិតថតចម្លងពីលិខិតសំណុំរឿងដល់កូនក្តីឡើយ។[53]ដូចនេះនៅក្នុងដំណាក់នេះដែរ ក្នុងការសួរចម្លើយជនត្រូវចោទ ត្រូវមានការបកស្រាយឱ្យបានច្បាស់លាស់នូវរឿងហេតុដែលបានកើតឡើង ចៅក្រមស៊ើបសួរបានសួរពីជនត្រូវចោទ មានមេធាវីក្នុងការការពារសិទ្ធិជនត្រូវចោទ។

#### ៣.៣.១.២. វត្តមានមេធាវីពេលស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងបានក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួន។ កាលណាជនរងគ្រោះជាអនីតិជន ឬជានីតិជនដែលស្ថិតនៅក្រោមរបបច្បាប់ការពារជាដើម។ មេធាវីរបស់

[52] មាត្រា ៣២ ច្បាប់ស្តីពីយុត្តិធម៌អនីតិជននស/រកម/០៧១៦/០០៩ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។

[53] មាត្រា ១៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលបានការកោះហៅពីចៅក្រមស៊ើបសួរ និងពេលវេលានៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរៀបចំត្រួតពិនិត្យមើលនូវសំណុំរឿងនៃនីតិវិធី។ មេធាវីត្រូវត្រៀមនិងរៀបចំនូវឯកសារឬភស្តុតាងទាំងឡាយណាដែលខ្លួនប្រមូលបាន ដើម្បីបង្ហាញជូនចៅក្រមស៊ើបសួរ សម្រាប់ជាផលប្រយោជន៍ដល់កូនក្តីរបស់ខ្លួន។ មេធាវីក៏ត្រូវមានវត្តមានក្នុងពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដោយចៅក្រមស៊ើបសួរ។ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខមេធាវី ដោយមានការចូលរួមពីព្រះរាជអាជ្ញា។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវអមបានដោយមេធាវី។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ [54] មេធាវីការពាររបស់ជនត្រូវចោទ អាចស្នើសុំចៅក្រមស៊ើបសួរដើម្បីចូលរួមនៅក្នុងពេលស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន។ ប្រសិនបើមេធាវីការពាររបស់ជនត្រូវចោទយល់ឃើញថាវាជាផលប្រយោជន៍ដល់កូនក្តីរបស់ខ្លួន មេធាវីនោះអាចលើកជាសំណួរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរជាមុនសិន។

### ៣.៣.១.៣. ការស្តាប់ចម្លើយសាក្សី

មេធាវីជនត្រូវចោទអាចស្វែងរកនូវ សាក្សីដោះបន្ទុក និងសាក្សីដាក់បន្ទុក ដែលខ្លួនយល់ឃើញថាវាអាចជាផលប្រយោជន៍សម្រាប់កូនក្តីរបស់ខ្លួន។ សាក្សីដែលបានដឹង បានលឺ បានឃើញនូវហេតុការណ៍ បានស្តាប់នូវហេតុការណ៍ដោយផ្ទាល់ឬដោយប្រយោល។ បុគ្គលណាម្នាក់ដែលបានដឹងនូវហេតុការណ៍ពិត វាជាករណីដែលចាំបាច់ដែលមេធាវីត្រូវតែធ្វើការសាកសួរចម្លើយជននោះដោយមិនអាចខានបាន ព្រោះវាអាចជាមូលដ្ឋានគ្រឹះមួយសម្រាប់ដោះបន្ទុកឱ្យកូនក្តីរបស់ខ្លួនបាន។ មិនតែប៉ុណ្ណោះមេធាវីមានសិទ្ធិអញ្ជើញ ឬហៅសាក្សីរបស់ខ្លួន ដែលមេធាវីយល់ឃើញថានឹងផ្តល់ភស្តុតាងដែលជាផលប្រយោជន៍ដល់កូនក្តីខ្លួន មកបំភ្លឺនៅតុលាការបាន។ ចៅក្រមស៊ើបសួរអាច ស្តាប់ចម្លើយ បុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានផលប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញនូវការពិត។ ចៅក្រមស៊ើបសួរអាចសួរចម្លើយសាក្សីដាច់ដោយឡែកពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ហើយចៅក្រមស៊ើបសួរក៏មានសិទ្ធិអាចសួរ តទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានផងដែរ។ ដូចនេះសាក្សីមានសារៈសំខាន់ក្នុងការស្វែងរកការពិតនូវរឿងហេតុ មេធាវីត្រូវរកភស្តុតាង ដោយធ្វើការសាកសួរទៅសាក្សី ដើម្បីបង្ហាញឱ្យឃើញនូវការពិត ដែលបានកើតឡើងនៅក្នុងរឿងហេតុ។ ដូចនេះសាក្សី គឺជាបុគ្គលម្នាក់ដែលសំខាន់នៅក្នុងរឿងក្តី មេធាវីត្រូវមានឆន្ទៈក្នុងការសាកសួរសាក្សី ដែលបានជួបប្រទះក្នុងការជួយទៅដល់រឿងក្តីរបស់ខ្លួន។ សាក្សី ដែលបានដឹងនូវហេតុការណ៍ និងបានឮនូវរឿងហេតុការណ៍ទាំងនោះ ដែលជាប្រយោជន៍ទៅដល់កូនក្តីរបស់ខ្លួន ដែលមានក្នុងការដោះបន្ទុកជូនកូនក្តីរបស់ខ្លួន។

[54] មាត្រា ១៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

### ៣.៣.១.៤. ការធ្វើកោសលវិច័យ

នៅក្នុងដំណាក់កាលស៊ើបសួរ ពេលដែលចៅក្រមស៊ើបសួរប្រមូលបាននូវភស្តុតាង ដែលមានការពាក់ព័ន្ធអំពីបទល្មើសហើយពុំអាចវាយតម្លៃដោយខ្លួនឯងបាន នោះចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯងបាន ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីបាន។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវចាត់តាំង អ្នកជំនាញឱ្យមកពិនិត្យវិនិច្ឆ័យ និងវាយតម្លៃទៅលើភស្តុតាងនោះ។[55] មេធាវីការពារត្រូវចូលរួមជាមួយកូនក្តីរបស់ខ្លួន ក្នុងកំឡុងពេលដែលអ្នកជំនាញត្រូវការស្តាប់ចម្លើយជនត្រូវចោទ ប៉ុន្តែបើចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រ ដើម្បីពិនិត្យជនត្រូវចោទ នោះការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ គឺមិនតម្រូវឱ្យមានការចូលរួមពីមេធាវីទេ។[56] ប៉ុន្តែមេធាវីត្រូវតាមដានមើលនូវដំណើរការនៃការស្តាប់ចម្លើយនេះអ្នកជំនាញបានអនុវត្តទៅតាមនីតិវិធី។ ប្រសិនបើមេធាវីយល់ឃើញថាខុសនីតិវិធី ឬក៏អ្នកជំនាញបង្ខំឱ្យជនត្រូវចោទនិយាយបង្ហាញឱ្យឃើញនូវការពិត ឬបង្ខំឱ្យជនត្រូវចោទសារភាពនូវកំហុសដែលខ្លួនបានប្រព្រឹត្តនោះ មេធាវីនឹងធ្វើការជំទាស់ទៅនឹងការស្តាប់ចម្លើយនោះ។ កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានដល់ព្រះរាជអាជ្ញា ត្រូវដាក់ចូលក្នុងសំណុំរឿង។ ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារសិទ្ធិជូនជនត្រូវចោទ ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យនេះ។ មេធាវីត្រូវពិនិត្យមើលសំណុំរឿងនៃរបាយការណ៍កោសលវិច័យ។ ប្រសិនបើមេធាវីមានការយល់ឃើញថាការធ្វើកោសលវិច័យនេះត្រឹមត្រូវ ឬ មិនគ្រប់គ្រាន់តាមលក្ខណៈបច្ចេកទេស មេធាវីត្រូវស្នើសុំទៅចៅក្រមស៊ើបសួរដើម្បីប្រតិកោសលវិច័យ ឬកោសលវិច័យបន្ថែមបាន ប្រសិនបើខ្លួនយល់ឃើញថា វាមានផលប្រយោជន៍ ដល់ជនត្រូវចោទដែលជាកូនក្តីរបស់ខ្លួន។ ចំណែកឯរយៈពេលនៃការដាក់ពាក្យធ្វើប្រតិកោសលវិច័យនេះត្រូវបានកំណត់រយៈពេលដោយចៅក្រមស៊ើបសួរ ក្នុងរយៈពេលនេះដែលមិនអាចតិចជាង ១០ (ដប់) ថ្ងៃទេ។[57]

### ៣.៣.១.៥. ការស៊ើបជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលជាផ្លូវការរបស់ចៅក្រមស៊ើបសួរ ដែលសរសេររៀបរាប់ប្រាប់អំពីការចោទប្រកាន់ជនណាម្នាក់ ដែលបានប្រព្រឹត្តបទល្មើសនៅកន្លែងណាមួយដោយមានកាលបរិច្ឆេទ ហើយថែមទាំងប្រាប់ឈ្មោះបទល្មើស ដល់មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។[58] ចំពោះដីកាចាត់ចែងឱ្យស៊ើបសួរជំនួសនេះ ផ្តល់សិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការប្រើប្រាស់

---

[55] មាត្រា ១៦៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[56] មាត្រា ១៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[57] មាត្រា ១៧០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[58] មាត្រា ១៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

អំណាចក្នុងការធ្វើកំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យដូចជា នៅពេលដែលមានការស្ដាប់ចម្លើយរបស់សាក្សី ការឆែកឆេរ ការចាប់យកវត្ថុតាង និងការឃាត់ខ្លួនជាដើម។[59]

### ៣.៣.២. វិធានការនិរន្តរាយ

នៅក្នុងវិធានការនិរន្តរាយ គឺជាដំណាក់កាលមួយ ដែលដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់ត្រូវបានអនុវត្តដោយអំណាចចាប់បង្ខំរបស់រដ្ឋគឺ តាមរយៈស្ថាប័ននៃអំណាចតុលាការ។ ទោះបីជាវិធានការនេះបានរំលោភលើសិទ្ធិ និងសេរីភាពនៃជនជាប់ចោទ ដែលមានការឃុំខ្លួនបណ្ដោះអាសន្នក្នុងគោលបំណងដើម្បីរក្សានូវតុល្យភាព និងសណ្ដាប់ធ្នាប់ក្នុងសង្គមក្នុងនោះ មានសិទ្ធិសេរីភាពរបស់ជនជាប់ចោទក៏ត្រូវបានធានាតាមច្បាប់ផងដែរតាមរយៈការទទួលបានសិទ្ធិការពារក្ដីដែលខ្លួនបានជ្រើសរើស។ ដោយក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្ដល់សិទ្ធិជូនមេធាវីក្នុងវិធានការនិរន្តរាយនេះតាមរយៈ ការធានាសិទ្ធិពេលឃុំខ្លួនបណ្ដោះអាសន្ន ការធានាឱ្យជនត្រូវចោទនៅក្រៅឃុំការកោះហៅឬជូនដំណឹង បណ្ដឹងសុំកែប្រែ និងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។

#### ៣.៣.២.១. ការឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព។[60] ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើស ០១ (មួយ) ឆ្នាំ។[61] ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួន។[62] ការឃុំខ្លួនបណ្ដោះអាសន្ន អាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។
- ដើម្បីរារាំងកុំឱ្យមានការគៀបសង្កត់លើសាក្សី ជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីរក្សាការពារសន្តិសុខឱ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។[63] ចិរវេលានេះប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទ៖

[59] មាត្រា ១៨១ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[60] មាត្រា ២០៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[61] មាត្រា ២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[62] មាត្រា ២១៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[63] មាត្រា ២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

- **បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋកម្មសង្គ្រាម**

ការឃុំខ្លួនមិនលើសពី ០១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលឃុំខ្លួនបណ្តោះអាសន្នម្តងបាន ០១ (មួយ) ឆ្នាំ ដោយមានដីកាសំអាងហេតុច្បាស់លាស់ហើយការពន្យានេះធ្វើបានតែ០២ដងប៉ុណ្ណោះ។[64]

- **បទឧក្រិដ្ឋ**

ជនត្រូវចោទជានីតិជន មានរយៈពេលឃុំខ្លួនជាបណ្តោះអាសន្ន ០៦ (ប្រាំមួយ) ខែអាចពន្យាបាន ០៦ (ប្រាំមួយ) ខែបានចំនួន០២ (ពីរ) ដងដោយមានដីកា និងសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។[65]

ជនត្រូវចោទជាអនីតិជន មានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលាឃុំខ្លួនបណ្តោះអាសន្ន មានដូចតទៅ៖

កាលណាអនីតិជនមានអាយុតិចជាង ១៦ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ០៤ (បួន) ខែបានទេ។ កាលណាអនីតិជនមានអាយុចាប់ពី ១៦ឆ្នាំ ក្រោម ១៨ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ០៦ (ប្រាំមួយ) ខែបានទេ។[66]

- **បទមជ្ឈឹម**

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈឹម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០៤ (បួន) ខែបានទេ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្តោះអាសន្នបានតែម្តងគត់មិនឱ្យលើសពី ០២ (ពីរ) ខែនោះទេ។[67]

ជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់អាយុក្រោម ១៨ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០២ (ពីរ) ខែបានទេ។

ជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០៤ (បួន) ខែបានទេ។ ហើយរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់នោះទេ។[68] មេធាវី ត្រូវបានជូនដំណឹងភ្លាមបន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន តាមរយៈដីកាដោយមានសំអាងហេតុ។[69]

---

[64] មាត្រា ២១០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[65] មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[66] មាត្រា ២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[67] មាត្រា ២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[68] មាត្រា ២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[69] មាត្រា ២០៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

កាលណាជនត្រូវចោទមានមេធាវីអមមេធាវីត្រូវបង្ហាញពីមធ្យោបាយការពារខ្លួនដល់កូនក្តីរបស់ខ្លួន។ បើចៅក្រមស៊ើបសួរ សម្រេចថាពន្យាពេលឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីជនត្រូវចោទមានតួនាទីត្រូវបង្ហាញពីមធ្យោបាយការពារខ្លួនដល់កូនក្តី អ្នកដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ អ្នកជាប់ពន្ធនាគារទាំងអស់ត្រូវបានផ្តល់ឱកាស ពេលវេលា និងមធ្យោបាយដើម្បីជួបប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់ជាមួយមេធាវីរបស់ខ្លួន ដោយគ្មានការពន្យាពេល ការរាំងស្ទះ ឬការត្រួតពិនិត្យត្រូវរក្សាការសម្ងាត់ទាំងស្រុង។

### ៣.៣.២.២. ជំនួយមេធាវីក្នុងការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

ក្នុងករណី ជនត្រូវចោទជាប់ឃុំខ្លួនបណ្តោះអាសន្ន ក្រោយពីមានដីកាសម្រេចរបស់ចៅក្រមស៊ើបសួររួចហើយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងដោយអនុញ្ញាតឱ្យជនត្រូវចោទអាចស្ថិតនៅក្រៅឃុំបាន តាមរយៈពាក្យសុំឱ្យដោះលែងនៅក្រៅឃុំរបស់ជនត្រូវចោទ ឬមេធាវីជនត្រូវចោទមេធាវីអាចដាក់ពាក្យសុំឱ្យកូនក្តីនៅក្រៅឃុំតាមរយៈពាក្យសុំនេះទៅកាន់ចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរនឹងបញ្ជូនពាក្យសុំនេះ ទៅកាន់ព្រះរាជអាជ្ញាភ្លាមដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរត្រូវសម្រេចថា ដោះលែង ឬ មិនដោះលែងក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាភ្លាម។ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនេះជនត្រូវចោទអាចប្តឹងសភាស៊ើបសួរឱ្យសម្រេចជំនួសបាន។ ចៅក្រមស៊ើបសួរអាចចេញ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុ។ ករណីចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំម្តងហើយនេះ ជនត្រូវចោទអាចដាក់ពាក្យសុំម្តងទៀតបានក្នុងរយៈពេល ០១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចលើកមុន។[70] ករណីអនីតិជន ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលាដោយគំនិតផ្តួចផ្តើមរបស់ខ្លួន។ ដោយមេធាវីអាចសុំដោះលែងអនីតិជនឱ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ប៉ុន្តែចៅក្រមស៊ើបសួរត្រូវតែសម្រេចនៅក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ។

### ៣.៣.២.៣. ការកោះហៅ និងជូនដំណឹងដល់មេធាវី

ដីកាកោះ គឺជាលិខិតបង្គាប់របស់អង្គការតុលាការដែលតម្រូវឱ្យជនណាម្នាក់ ដែលមានការពាក់ព័ន្ធនឹងសំណុំរឿងត្រូវបង្ហាញខ្លួននៅតុលាការតាមកាលបរិច្ឆេទដែលបានកំណត់យ៉ាងច្បាស់។ ចំពោះមេធាវីតុលាការបានចេញលិខិតអញ្ជើញដែលបញ្ជូនមកតាមភ្នាក់ងារ ដែលនៅជិត ឬតាមប្រៃសនីយ។ នៅរាល់ពេលដែលដីកាត្រូវជូនដំណឹងដល់ជនត្រូវចោទនោះ ចៅក្រមស៊ើបសួរក៏ត្រូវតែមានការជូនដំណឹងដល់មេធាវីផងដែរ

[70] មាត្រា ២១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ប្រសិនបើជនត្រូវចោទមានមេធាវីអម។ នៅរាល់ពេលដែលដីកា ត្រូវតែឱ្យដំណឹងដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងដល់មេធាវីផងដែរ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីមានមេធាវីអម។[71]គ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬកងរាជអាវុធហត្ថ ដែលចៅក្រមស៊ើបសួរសុំឱ្យប្រគល់ដីកាកោះហៅ ឬដីកាផ្សេងទៀត ត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ។ បុគ្គលអង្គភាព ឬអាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកដល់សាមីខ្លួន ដោយមានអ្នកទទួលបញ្ជាក់ថាបានទទួលទុកជាសម្គាល់។ ដីកាដែលមានចំណារទទួលនេះត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត។[72]

### ៣.៣.២.៤. បណ្ដឹងសុំកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ហើយបញ្ជូនជននោះមកតុលាការ បន្ទាប់មកចៅក្រមស៊ើបសួរ បានសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរអាចដាក់ជននោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវឱ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើន។ [73] ករណីនេះចៅក្រមស៊ើបសួរចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬដីកាសម្រេចបដិសេធការសុំឱ្យដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

ក្រោយពីចៅក្រមស៊ើបសួរ បានចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួចហើយអាចនឹងមានការកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ តាមរយៈមេធាវី ឬជនត្រូវចោទអាចធ្វើបណ្ដឹងសុំកែប្រែ ឬការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ។ មេធាវីការពារជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ចៅក្រមស៊ើបសួរ និងធ្វើការបញ្ជូនពាក្យសុំលើកលែងនេះទៅកាន់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ នឹងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីត្រួតពិនិត្យ។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទ ឬមេធាវីអាចប្ដឹងសុំទៅសភាស៊ើបសួរ ឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ករណីដីកាសម្រេចមិនបានធ្វើការសម្រេចតាមពាក្យសុំត្រូវមានសម្អាងហេតុ។ ដូចនេះបណ្ដឹងសុំកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការដែលចៅក្រមស៊ើបសួរ មានសមត្ថកិច្ចក្នុងការដោះលែងជនត្រូវចោទ ឱ្យនូវក្រៅឃុំជាបណ្ដោះអាសន្ន ប៉ុន្តែជននៅក្រៅឃុំ ត្រូវមានការស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ មេធាវីត្រូវស្វែងរកភស្តុតាងបន្ថែម។

---

[71] មាត្រា ២៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[72] មាត្រា ២៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[73] មាត្រា ២២៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

### ៣.៣.២.៥. ការស្នើសុំឱ្យបំពេញកិច្ចដោយមេធាវី ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី

នៅគ្រប់ពេលវេលានៃស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសម្អាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងចិរវេលា ០១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ០១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរបាន។[74]

នៅគ្រប់ពេលវេលានៃស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងចិរវេលា ០១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសម្អាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ០១ (មួយ) ខែទេដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[75]

### ៣.៣.៣. ការបិទការស៊ើបសួរ

ប្រសិនការស៊ើបសួរមួយ ត្រូវបានបញ្ចប់ដោយគ្មានភស្តុតាងដាក់បន្ទុក ចៅក្រមស៊ើបសួរត្រូវលើកលែងបទចោទ។ ប្រសិនបើចៅក្រមស៊ើបសួរ រកឃើញនូវភស្តុតាងដាក់បន្ទុក ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬជាដីកាលើកលែងចោទប្រកាន់។ ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅៈ

- អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុ។
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់។
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

---

[74] មាត្រា ១៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[75] មាត្រា ១៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសម្អាងហេតុ។ ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចតាមកាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។[76] កាលណាចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនពត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ រយៈពេល ០២ (ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះព្រះរាជអាជ្ញាត្រូវធ្វើ (ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា)នៃក្រមនេះ។[77]ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និងមានរយៈពេល ០១ (មួយ) ខែក្នុងករណីដែលជនត្រូវចោទស្ថិតនៅក្រៅឃុំព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងសំអាងហេតុ។ ព្រះរាជអាជ្ញា អាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់។[78]

### ៣.៣.៤. ការប្តឹងអំពីសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ

ក្រោយពីបញ្ចប់ការស៊ើបសួរ ឬការបិទការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការបិទការស៊ើបសួរដល់គ្រប់បណ្តាគូភាគីទាំងអស់ដែលជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ ចំពោះការប្តឹងនេះអាចប្តឹងសុំមោឃភាពកិច្ចនីតិវិធី ការប្តឹងឧទ្ធរណ៍ ឬការប្តឹងទៅសភាស៊ើបសួរប៉ុណ្ណោះឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរ។ មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ចដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី។ ប្រសិនបើជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាពសាមីជនធ្វើពាក្យសុំដោយមានសំអាងហេតុជូនសភាស៊ើបសួរ និងជូនដំណឹងដល់ចៅក្រមស៊ើបសួរ។ ពាក្យសុំអាចធ្វើដោយមេធាវីរបស់ជនត្រូវចោទ ឬរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាដែលអាចត្រូវប្តឹងឧទ្ធរណ៍បានមិនអាចជាកម្មវត្ថុនៃបណ្តឹងសុំមោឃភាពបានឡើយ។ [79] ដូចនេះនៅក្នុងការប្តឹងអំពីសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ក្នុងការត្រួតពិនិត្យទៅលើមោឃភាពនៃនីតិវិធីរបស់សមាសភាពតុលាការ។

[76] មាត្រា ២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[77] មាត្រា ១៣២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[78] មាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[79] មាត្រា ២៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

### ៣.៣.៤.១. មោឃភាពនៃការស៊ើបសួរ

វិធាន និងទម្រង់ការដែលចែងដូចនៅខាងក្រោម ស្តីអំពីបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នោះទេនាំឱ្យមានមោឃភាពនៃនីតិវិធី៖

- ការបើកការស៊ើបសួរ គឺជាការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។[80]
- សមត្ថកិច្ចដែនដី គឺចៅក្រមដែលមានសមត្ថកិច្ច មានដូចជាចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស និង ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលសង្ស័យថា ប្រព្រឹត្តបទល្មើស។[81]
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញានោះទេ។[82]
- វិសាលភាពនៃការប្តឹង គឺចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរអំពីអង្គហេតុនោះប៉ុណ្ណោះ។ ប្រសិនបើមានលេចអង្គហេតុថ្មី ដែលជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មី តាមដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម បើគ្មានដីកាបញ្ជូនឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះទេ។ [83]
- ជំនួយរបស់ក្រឡាបញ្ជី គឺចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច។ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ច ដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។ [84]

ទាំងនេះនាំឱ្យមានមោឃភាពនៃនីតិវិធីផងដែរ កាលណាមានការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយណាដែលស្តីអំពីនីតិវិធីព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន។[85] ប៉ុន្តែការធ្វើមោឃភាពចំពោះកិច្ច ឬនីតិវិធីណាមួយចំពោះនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម និងនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជា

[80] មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[81] មាត្រា ១២៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[82] មាត្រា ១២៤ កថាខណ្ឌទី៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[83] មាត្រា១២៥ កថាខណ្ឌទី១ និងទីកថាខណ្ឌ២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[84] មាត្រា ១២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[85] មាត្រា ២៥២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

សមត្ថកិច្ចរបស់តុលាការជាន់ដំបូង។ ការស្នើសុំធ្វើមោឃកម្មចំពោះកិច្ចនីតិវិធីស៊ើបសួរ អាចធ្វើបានមុនយុត្តាធិការជំនុំជម្រះប៉ុណ្ណោះ។ ដីកាដំណោះស្រាយដែលចូលជាស្ថាពរ ត្រូវលុបលាងមោឃភាពនៃនីតិវិធីមុនប្រសិនបើមាន ដោយគ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតបានឡើយ។ [86] ដីកាដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បាន មិនអាចជាកម្មវត្ថុនៃបណ្តឹងសុំធ្វើមោឃភាពបានឡើយ។ ដីកាដែលអាចត្រូវប្តឹងឧទ្ធរណ៍បាន មិនអាចជាកម្មវត្ថុនៃបណ្តឹងសុំមោឃភាពបានឡើយ។

### ៣.៣.៤.២. បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ

ប្រសិនបើជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា នៅក្នុងលិខិតណាមួយនៃនីតិវិធីមានមោឃភាពសាមីខ្លួនធ្វើពាក្យសុំដោយមានសំអាងហេតុ ជូនទៅសភាស៊ើបសួរ និងជូនដំណឹងដល់ចៅក្រមស៊ើបសួរ។ មានតែសភាស៊ើបសួរតែមួយគត់ ដែលមានសមត្ថកិច្ចដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី។[87] អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។[88] ពាក្យសុំឱ្យពិនិត្យមោឃភាពនៃកិច្ចនីតិវិធីនេះ មេធាវីជនត្រូវចោទ ឬមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុហើយត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជី នៅតុលាការជាន់ទាបជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួររៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង។ សេចក្តីចម្លងនេះ ត្រូវធ្វើឡើងដោយក្រឡាបញ្ជីនៃតុលាការជាន់ទាបក្រោយពីបានឃើញនិទ្ទេសដែលចុះក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍។ នៅក្នុងសំណុំរឿងនេះត្រូវបញ្ជូនទៅកាន់ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ នៅក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចជំនុំជម្រះបាន។ [89] បណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។[90] បន្ទាប់ពីសភាស៊ើបសួរបានពិនិត្យពីមោឃភាពនៃលិខិតនៃនីតិវិធីរួចហើយ សេចក្តីសម្រេចរបស់សភាស៊ើបសួរមាន ០២ គឺ សភាស៊ើបសួរសម្រេចមិនទទួលពាក្យបណ្តឹងសុំមោឃកម្ម និងសម្រេចទទួលពាក្យសុំមោឃកម្ម។ មានតែដីកាសម្រេចប៉ុណ្ណោះដែលអាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍បាន ប៉ុន្តែដីកាបង្គាប់ចេញដោយចៅក្រមស៊ើបសួរពុំអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បានឡើយ។ ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេច បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ តែប៉ុណ្ណោះ។ បណ្តឹង

[86] មាត្រា ២៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[87] មាត្រា ២៣២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[88] មាត្រា ២៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[89] មាត្រា ២៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[90] មាត្រា ២៧១ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល ០១ (មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។[91] បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ។ បណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទដើមបណ្ដឹងរដ្ឋប្បវេណី និងរបស់បុគ្គលដែលមាន។[92] (បណ្ដឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ) ត្រូវធ្វើឡើងក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃគិតចាប់ពីការជូនដំណឹងពីដីកា។

## ៣.៤.១. ដំណាក់កាលជំនុំជម្រះ

ការសម្រេចសេចក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើឡើងដោយតាំងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។[93] សាលក្រម គឺជាសេចក្តីសម្រេចចុងក្រោយរបស់សាលាដំបូងរាជធានី-ខេត្ត។ សាលដីកា គឺជាសេចក្តីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ នឹងតុលាការកំពូល។ សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ០៣ រូបចំពោះបទឧក្រិដ្ឋ និងបទមជ្ឈឹមស្មុគស្មាញ។ ចៅក្រមទោល ០១ រូប ជំនុំជម្រះបទមជ្ឈឹម នឹងបទលហុ។ ចំពោះសាលាឧទ្ធរណ៍ជាទូទៅជំនុំជម្រះ ០៣ រូប និងចៅក្រម ០៥ រូប ជំនុំជម្រះទៅលើបទឧក្រិដ្ឋ។ តុលាការដែលមានសមត្ថកិច្ចខាងដែនដីគឺ តុលាការនាទីកន្លែងប្រព្រឹត្តបទល្មើស តុលាការនាទីលំនៅឋានរបស់ជនជាប់ចោទ តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ។ ករណីដែលមានតុលាការ ០២ ឬច្រើន ដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យប្តឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកសំណុំរឿង។ តុលាការជំនុំជម្រះអាចទទួលបណ្ដឹងតាមរបៀប ៣ ដែលខុសគ្នាដោយសារបែបបទនៃការតាក់តែងសំណុំរឿងនីតិវិធី។

តុលាការជំនុំជម្រះអាចទទួលបណ្ដឹងដោយមានដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ។ តែបើអង្គហេតុមិនអនុញ្ញាតឱ្យមានវិធានការស៊ើបសួរនោះទេ ព្រះរាជអាជ្ញាមានជម្រើសប្តឹងតាមរយៈដីកាបញ្ជូន ទៅតុលាការជំនុំជម្រះផ្ទាល់ ឬតាមកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម។[94] នៅដំណាក់កាលជំនុំជម្រះមេធាវីទទួលបានសិទ្ធិពីជនជាប់ចោទតាមរយៈពាក់សុំពឹងពាក់មេធាវី និងពាក្យសុំការពារក្តីនៅមុនពេលជំនុំជម្រះ។ ក្នុងដំណាក់កាលនេះផងដែរ មេធាវីក៏មានតួនាទីក្នុងការជជែកដេញដោល ដើម្បីជួយសម្រាលទោសប្រសិនបើជនជាប់ចោទដែលជាកូនក្តីទទួលស្គាល់នូវកំហុសរបស់ខ្លួន ឬសុំឱ្យរួចពីបទចោទប្រសិនបើជនជាប់ចោទមិនបានប្រព្រឹត្តបទល្មើស។ មេធាវីដែលមានសិទ្ធិការពារសិទ្ធិជូនជនជាប់ចោទ សម្រាប់ការពិនិត្យមើលអំពីដំណើរការកិច្ចនីតិវិធី នៅក្នុងការដឹកនាំអង្គសវនាការរបស់ប្រធាន

[91] មាត្រា ២៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[92] មាត្រា ២៦៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[93] មាត្រា ១២៩ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[94] មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកស្រី ឌី លីឡា និងលោក ខាន់ សុខា។

ក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ និងធ្វើការតវ៉ាភ្លាមៗសម្រាប់ការដឹកនាំមិនត្រឹមត្រូវតាមច្បាប់ដែលបានកំណត់។

មេធាវីក៏អាចតំណាងជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីបាន។ ជនជាប់ចោទអាចទទួលបានសេវាមេធាវីដោយអស់កម្រៃ ឬតាមការចាត់តាំងមេធាវីជូនដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌ត្រូវតែមានវត្តមានមេធាវីជាចាំបាច់ដែលមិនអាចខានបាននោះទេ។

### ៣.៤.១. នីតិវិធីមុនពេលសវនាការ

#### ៣.៤.១.១. នីតិវិធីនៃការសម្រេចមុនអង្គសេចក្តី

បន្ទាប់ពីបានការជំនុំជម្រះដល់អង្គសេចក្តី ជនជាប់ចោទដែលត្រូវបានឃុំខ្លួន អាចសុំតុលាការឱ្យដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយផ្ទាល់មាត់នៅពេលសវនាការ ឬតាមលិខិតដែលធ្វើជូនក្រឡាបញ្ជី។ ពាក្យសុំនេះអាចធ្វើដោយមេធាវីរបស់ជនជាប់ចោទដែលត្រូវបានឃុំខ្លួន។ កាលណាពាក្យសុំបានធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃសវនាការ។ តុលាការសម្រេចក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវី ព្រះរាជអាជ្ញា។ តុលាការត្រូវសម្រេចនៅក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១០ (ដប់) ថ្ងៃក្រោយការសុំដោយផ្ទាល់មាត់ ឬក្រោយពីទទួលពាក្យសុំដែលធ្វើជាលាយលក្ខណ៍អក្សរ។[95]

#### ៣.៤.១.២. ជំនួយរបស់មេធាវី

ជំនួយរបស់មេធាវីត្រូវតែមានដាច់ខាតនៅក្នុងករណីដូចតទៅ៖

១. ករណីបទឧក្រិដ្ឋ

២. កាលណាជនជាប់ចោទជាអនីតិជន។

បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[96]

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈសេរីឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌។ វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅតែក្នុងក្របខណ្ឌនៃគណៈមេធាវី។ [97] មេធាវីអាចជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី។ នៅក្នុងរឿងព្រហ្មទណ្ឌ មេធាវីជួយការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន។ មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ។[98] កូនក្តីអាចមាន

[95] មាត្រា ៣០៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[96] មាត្រា ៣០១ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[97] មាត្រា ១ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥។

[98] មាត្រា ២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥។

ពឹងពាក់មេធាវីតាមរយៈពាក្យសុំពឹងពាក់មេធាវី ចំណែកឯមេធាវីការពារកូនក្តីតាមរយៈ ពាក្យសុំការពារក្តី ទៅដាក់នៅរដ្ឋបាលគ្រប់បណ្តាតុលាការដែលពាក់ព័ន្ធ។

**៣.៤.១.៣. សមាសភាពក្នុងអង្គសវនាការ**

សមាសភាពនៅក្នុងសវនាការមានដូចតទៅ៖ ចៅក្រមជំនុំជម្រះ តំណាងអយ្យការ ក្រឡាបញ្ជី ជនជាប់ចោទ ជនរងគ្រោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណីសាក្សីដាក់បន្ទុក សាក្សីដោះបន្ទុក សាក្សីតាមឆន្ទានុសិទ្ធិ មន្ត្រីនគរបាលយុត្តិធម៌ ភ្ញៀវចូលរួមស្តាប់សវនាការ។

**៣.៤.១.៤.វាក្យស័ព្ទដែលត្រូវប្រើចំពោះជនប្រព្រឹត្តបទល្មើសតាមដំណាក់កាលនីតិវិធី**

- **ជនល្មើស ឬជនសង្ស័យ** គឺជាជនដែលស្ថិតនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលព្រះរាជអាជ្ញា និងមុនពេលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់។
- **ជនត្រូវចោទ** គឺជាជនដែលត្រូវបានព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ ហើយបញ្ជូនជននោះទៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ រហូតដល់ចៅក្រមស៊ើបសួរធ្វើការបិទការស៊ើបសួរ។
- **ជនជាប់ចោទ** គឺជាជនដែលស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះ រហូតដល់មុនពេលប្រកាសសាលក្រម ចាប់ពីពេលមានការចោទប្រកាន់ដោយព្រះរាជអាជ្ញាតាមកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ឬតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។
- **ពិរុទ្ធជន** គឺជាជនដែលគិតចាប់ពីចេញសាលក្រមផ្តន្ទាទោសរហូតដល់មុនសាលក្រមចូលជាស្ថាពរ។
- **ទណ្ឌិត** គឺជាជនគិតចាប់ពីសាលក្រមចូលជាស្ថាពរ រហូតដល់ពេលអនុវត្តទោសរួច។

**៣.៤.១.៥.. ដំណើរការកិច្ចនីតិវិធីក្នុងពេលសវនាការ**

នៅពេលដំណើរការសវនាការក្រឡាបញ្ជីសវនាការបាន ស្រង់វត្តមានរបស់ ជនជាប់ចោទ ជនរងគ្រោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីផ្ទៀងផ្ទាត់វត្តមានជូនតុលាការ។ តុលាការដែលមានយុត្តាធិការជំនុំជម្រះដែលអាចបើកសវនាការដើម្បីជំនុំជម្រះបាន ចំពោះជនណាដែលជាជនជាប់ចោទតែប៉ុណ្ណោះ។ ចំពោះការផ្តន្ទាទោសដែលគឺត្រូវធ្វើឡើងដោយអំណាចសាលក្រម ទាំងទោសដាក់ពន្ធនាគារ និងទោសដែលពិន័យជាប្រាក់។ នៅដំណាក់កាលជំនុំជម្រះនេះមេធាវីមានតួនាទីយ៉ាងសំខាន់ដើម្បីឱ្យដំណើរការកិច្ចនីតិវិធីក្នុងពេលសវនាការក្នុងសំណុំរឿងព្រហ្មទណ្ឌមួយប្រកបដោយយុត្តិធម៌ ពោលគឺមេធាវីជនជាប់ចោទដើរតួយ៉ាងសំខាន់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជូនជនជាប់ចោទ មានតួនាទីក្នុងការពិភាក្សាដេញដោលវែកញែក ដើម្បីដោះបន្ទុកកូនក្តីរបស់ខ្លួន ឱ្យរួចផុតពីការចោទប្រកាន់ ឬសុំនូវស្ថានសម្រាលទោសតាមរយៈអំណាចសាលក្រម ដែលត្រូវធ្វើនៅពេលសវនាការ និងនៅពេលប្រកាសសាលក្រម។ ក្រោយពីទទួលដំណឹងអំពី

កាលបរិច្ឆេទនៃការចូលបង្ហាញខ្លួន ជនជាប់ចោទត្រូវបង្ហាញខ្លួននៅពេលសវនាការដោយផ្ទាល់។ មេធាវី ត្រូវនៅអមជនជាប់ចោទបន្ទាប់ពីទទួលបានជ្រើសរើស ដោយជនជាប់ចោទឬមេធាវីត្រូវបានតែងតាំងដោយប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះករណីបទឧក្រិដ្ឋជនជាប់ចោទត្រូវមានមេធាវីជាចាំបាច់ ករណីបទឧក្រិដ្ឋជនជាប់ចោទដែលជាអនីតិជន ត្រូវមានមេធាវីការពារសិទ្ធិជាចាំបាច់ ដែលមិនអាចខានបាន។ មេធាវីការពារសិទ្ធិជនជាប់ចោទត្រូវតែមានវត្តមានជាចាំបាច់នៅពេលដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការសាកសួរចម្លើយនៅចំពោះមុខអង្គសវនាការទាំងមូល។ លើសពីនេះការសួរចម្លើយត្រូវធ្វើកំណត់ហេតុ។មួយវិញទៀត ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចមានមេធាវីការពារសិទ្ធិផងដែរ។

### ៣.៤.២. ការពិភាក្សាដេញដោល

នៅពេលចាប់ផ្តើមសវនាការក្រឡាបញ្ជីត្រូវត្រួតពិនិត្យហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី មេធាវី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។ កាលណាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់ ក្រឡាបញ្ជីពិនិត្យមើលអត្តសញ្ញាណអ្នកតំណាង និងសុពលភាពនៃការប្រគល់សិទ្ធិ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ត្រូវធ្វើដូច្នេះដែរ។ ក្រឡាបញ្ជីត្រូវសុំយោបល់ប្រធានសវនាការក្នុងករណីចាំបាច់។ ភាគីនីមួយៗអង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឱ្យខ្លួន នៅក្នុងបន្ទប់សវនាការ។ ជនជាប់ចោទមិនត្រូវទាក់ទងនឹងគ្នាទេ។[99] ក្រឡាបញ្ជីត្រូវកត់កំណត់ហេតុសវនាការជាចាំបាច់ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការ ក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។ នៅពេលសវនាការប្រធានក្រុមប្រឹក្សាជំនុំជម្រះ ប្រាប់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលខ្លួនប្រព្រឹត្ត និងបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់។ សិទ្ធិមានមេធាវីត្រូវបានអនុញ្ញាតដោយចៅក្រមត្រូវបញ្ជាក់ប្រាប់ជនរងគ្រោះ ពីសិទ្ធិរបស់គេដើម្បីបង្ហាញភស្តុតាងសិទ្ធិធ្វើសំណូមពរ។ តួនាទីរបស់មេធាវីនៅក្នុងការពិភាក្សាដេញដោល គឺមានលក្ខណៈដូចគ្នានឹងព្រះរាជអាជ្ញាដែរ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវីសំណួរផ្សេងទៀតត្រូវបានសួរតាមរយៈប្រធានសវនាការ។ មេធាវីអាចសួរសំណួរទៅលើជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាត។ មេធាវីក៏មានសិទ្ធិក្នុងការសាកសួរចម្លើយពីសាក្សីដែលពាក់ព័ន្ធ ក្រៅពីសំណួរមេធាវីសំណួរផ្សេងទៀតត្រូវបានសួរដោយប្រធានសវនាការ ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយសាក្សី ប៉ុន្តែត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ប្រធានសវនាការធ្វើការសាកសួរជនជាប់ចោទទាំងសំណួរដាក់បន្ទុក និងសំណួរដោះបន្ទុកដែលខ្លួនយល់ថាសម្តែងឱ្យឃើញនូវការពិត។ ព្រះរាជអាជ្ញា មេធាវី ភាគីអាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរផ្សេងៗទៀតសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការ

---

[99] មាត្រា ៣២២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

សម្រេចដោយខ្លួនឯងថា តើសំណួរនេះត្រូវសួរដែរឬទេ។[100] ការសួរចម្លើយរបស់ភាគី ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញទៅតាមលំដាប់លំដោយដោយខ្លួនយល់ឃើញថាមានប្រយោជន៏។ ប្រធានសវនាការអាចស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ដែលបានចូលរួមស៊ើបអង្កេតក្នុងឋានៈជាសាក្សីព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរ។ រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោលជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយត្រូវភ្ជាប់ទៅក្នុងសំណុំរឿង។[101]

### ៣.៤.៣. ការបង្ហាញភស្តុតាង

#### ៣.៤.៣.១. ចំពោះមេធាវីការពារជនជាប់ចោទ

មេធាវី ការពារសិទ្ធិជូនជនជាប់ចោទមានតួនាទីយ៉ាងសំខាន់ ដើម្បីបង្ហាញនូវភស្តុតាងដែលជាផលប្រយោជន៍សម្រាប់កូនក្តីរបស់ខ្លួននោះគឺភស្តុតាងដោះបន្ទុក ដែលខ្លួនបានប្រមូលភស្តុតាងទាំងនោះដាក់ជូនចៅក្រមជំនុំជម្រះសម្រេចពិចារណា ដែលជាមេធាវីការពារសិទ្ធិនេះទៀតសោតត្រូវបកស្រាយ និងលើកយកភស្តុតាងនោះមកបកស្រាយឱ្យបានក្បោះក្បាយ និងគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យចៅក្រមជំនុំជម្រះផ្តល់សេចក្តីទុកចិត្តទៅលើភស្តុតាង ដែលយើងត្រូវដាក់ជូនទៅចៅក្រមពិនិត្យ។ ម៉្យាងវិញទៀតប្រសិនបើនៅពេលសវនាការភស្តុតាងណាដែលមិនស៊ីចង្វាក់គ្នា ឬមានភាពផ្ទុយស្រឡះ មេធាវីជនជាប់ចោទអាចបដិសេធច្រានចោលនូវភស្តុតាងនោះទុកជាមិនបានការ។ មេធាវីមានតួនាទីច្រានចោលរាល់ភស្តុតាងណាដែលខ្លួនយល់ឃើញថាវាមានភាពមិនប្រក្រតី ឬដោះបន្ទុកកូនក្តីខ្លួន។

#### ៣.៤.៣.២. ការសន្និដ្ឋានការពារក្តីរបស់មេធាវី

នៅពេលការពិភាក្សាដេញដោលទល់នឹងការបិទបញ្ចប់ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសម្តែងឱ្យឃើញនូវការពិត។ មេធាវីជនជាប់ចោទ មានកាតព្វកិច្ចធ្វើសេចក្តីសន្និដ្ឋានការពារជំនួសកូនក្តីរបស់ខ្លួន ប្រសិនបើកូនក្តីរបស់ខ្លួនបានប្រព្រឹត្ត មេធាវីជនជាប់ចោទត្រូវសុំស្ថានសម្រាលទោស ប្រសិនបើកូនក្តីខ្លួនមិនបានប្រព្រឹត្ត មេធាវីជនជាប់ចោទត្រូវសុំឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់។ ការសន្និដ្ឋានការពារក្តីរបស់មេធាវី មានសារៈសំខាន់ក្នុងការជួយកូនក្តីរបស់ខ្លួន។

---

[100] មាត្រា ៣២៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[101] មាត្រា ៣៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

- **ករណីយកិច្ចរបស់មេធាវី៖** នៅពេលធ្វើសេចក្តីសន្និដ្ឋានការពារ មេធាវីជនជាប់ចោទត្រូវរៀបចំទ្រឹស្តីការពាររបស់ខ្លួនដោយយោងតាមអង្គហេតុ និងភស្តុតាង ដោយផ្អែកទៅលើអង្គច្បាប់ និងឯកសារនានានៅចំពោះមុខចៅក្រមជំនុំជម្រះ។ មេធាវីជនជាប់ចោទត្រូវមានវិធីសាស្ត្រក្នុងការតតាំងក្តី និងការពាររាល់ភស្តុតាងនានារបស់ខ្លួនឱ្យយកជាបានការនឹងមានការទុកចិត្តពីក្រុមប្រឹក្សាជំនុំជម្រះ។ មេធាវីជនជាប់ចោទមានកាតព្វកិច្ច ច្រានចោលរាល់ភស្តុតាងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី នឹងព្រះរាជអាជ្ញាបាន ប្រសិនបើខ្លួនយល់ឃើញថាវាប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ដល់កូនក្តីរបស់ខ្លួន។
- **ការដោះសារ និងឆ្លើយតបរវាងគូភាគី៖** ម្យ៉ាងវិញទៀតក្រោយពេលស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីភាគីម្ខាងទៀត បានរកឃើញនូវចំណុចចោទប្រកាន់សំខាន់ៗផ្សេងទៀត មេធាវីជនជាប់ចោទត្រូវប្រតិកម្មរហ័សទៅនឹងការលើកហេតុផលផ្ទុយទៅលើចំណុចដែលបានលើកឡើងនោះ។
- **សំណូមពរ៖** មេធាវីត្រូវលើកសំណូមពរជាដាច់ខាត មេធាវីជនជាប់ចោទត្រូវសំណូមពរទៅចៅក្រមជំនុំជម្រះទៅតាមអ្វីដែលកូនក្តីរបស់ខ្លួនចង់បាន។

### ៣.៤.៣.៣. សិទ្ធិ និងឧន្ទានុសិទ្ធិក្នុងការបញ្ចេញមតិក្នុងសវនាការ

ក្រោយពីបានធ្វើដំណើរការកិច្ចពិភាក្សាដេញដោល ប្រធានសវនាការ ឬចៅក្រមជំនុំជម្រះបានបើកឱ្យដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ជនជាប់ចោទ ដើម្បីធ្វើកំណត់សម្គាល់ខ្លីៗ។

១. ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ

២. ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ

៣. មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ។

៤. ដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចឆ្លើយតបវិញបាន។

ប៉ុន្តែជនជាប់ចោទខ្លួនឯង និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច។[102] ព្រះរាជអាជ្ញាធ្វើការប្តឹងសុំដោយផ្ទាល់មាត់ដែលខ្លួនយល់ឃើញថា សមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌។[103] មុនពេលចៅក្រមធ្វើការពិចារណានិងសម្រេចសេចក្តី មេធាវីត្រូវធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តី ដែលមេធាវីនឹងធ្វើការប្តឹងសុំទៅកាន់តុលាការមានដូចជា សុំឱ្យមានសំណងរដ្ឋប្បវេណី ឬសំណងជម្ងឺចិត្ត និងអាចធ្វើការច្រានចោល ឬធ្វើការបដិសេធចំពោះរាល់ការចោទប្រកាន់របស់ភាគីម្ខាងទៀត។ ការធ្វើសេចក្តីសន្និដ្ឋានការពាររបស់មេធាវីអាចត្រូវធ្វើឡើងដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ ចំពោះសេចក្តីសន្និដ្ឋានការពារជាលាយលក្ខណ៍អក្សរមេធាវីអាចធ្វើនៅពេលសវនាការ ឬក្រោយពេលសវនាការក៏បាន។ ការប្រកាសសាលក្រម ត្រូវធ្វើឡើងនៅពេល

[102] មាត្រា ៣៣៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[103] មាត្រា ៣៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

សវនាការដែលធ្វើការពិភាក្សាដេញដោល ឬក៏នៅពេលសវនាការលើកក្រោយ កាលបរិច្ឆេទត្រូវកំណត់ដោយចៅក្រម [104] ការប្រកាសសាលក្រមលើអង្គសេចក្តីអាចធ្វើតាមរយៈសាលក្រមចំពោះមុខ សាលក្រមចាត់ទុកចំពោះមុខនិងសាលក្រមកំបាំងមុខ។ សាលក្រមជាសេចក្តីសម្រេចចុងក្រោយបង្អស់ នៃដំណើរការនីតិវិធីតាំងពីពេលចាប់ផ្តើមរហូតត្រូវបានបញ្ចប់។ បន្ទាប់ពីសាលក្រមបានចូលជាស្ថាពរហើយពិរុទ្ធជនអាចប្តឹងទាស់ទៅនឹងសាលក្រម ដែលប្រកាសដោយកំបាំងមុខមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។[105] ប្រសិនបើការពិភាក្សាដេញដោលមិនបានបញ្ចប់តុលាការអាចបន្តសវនាការនាពេលក្រោយបាន។

### ៣.៤.៣.៤. ការសុំបន្ធូរបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ

វិធីសាស្ត្រ ឬអំពើដែលជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ ប្រើដើម្បីទទួលបាននូវការបន្ធូរបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ ឬឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ការសុំបន្ធូរបន្ថយទោសមេធាវីជនជាប់ចោទត្រូវបានប្រើក្នុងករណីកូនក្តី(ជនជាប់ចោទ)ទទួលសារភាពថា ពិតជាបានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់មែន។ កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស។ ស្ថានសម្រាលទោសអាចតម្រូវជនជាប់ចោទបានដែរ ទោះបីជាជននោះ ត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចោលក៏ដោយ។[106] ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ក្រោម ១៨ឆ្នាំ កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅៈ

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដែលដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកពន្ធនាគារត្រឹម ២០ឆ្នាំ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះដែលលើសពី ០១ (មួយ) ថ្ងៃ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះ មានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំនោះបទល្មើសដែលចោទប្រកាន់នៅតែជាបទល្មើសឧក្រិដ្ឋដដែល។[107] មេធាវី

---

[104] មាត្រា ៣៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[105] មាត្រា ៣៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[106] មាត្រា ៩៣ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[107] មាត្រា ៩៣ និងមាត្រា ១៦៤ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ជនជាប់ចោទអាច សុំព្យួរទោសធម្មតា[108] ។ ការព្យួរទោសសាកល្បង[109] ការសុំប្រកាសទោសជំនួស ទោសការងារសហគមន៍។[110]

### ៣.៤.៣.៥. ការសុំឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

ការឱ្យសុំរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺធ្វើឡើងនៅដំណាក់កាលជំនុំជម្រះ មានន័យថា មេធាវីជនជាប់ចោទ ឬជនជាប់ចោទសុំឱ្យរួចខ្លួនពីបទចោទ។ ប្រសិនបើពិនិត្យឃើញថាអំពើនោះមិនមែនជាបទល្មើស ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ។[111] ប្រសិនបើកូនក្តីមិនបានប្រព្រឹត្តបទល្មើសដែលចោទប្រកាន់ ឬបានប្រព្រឹត្តតែមានមូលហេតុផ្លូវច្បាប់ដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌៈ
នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ។[112]

- **អនីតិជន**

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ វិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្ម ព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។[113]

- **ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារមូលហេតុវិបល្លាសស្មារតី**[114]

ការមិនទទួលខុសព្រហ្មទណ្ឌដោយសារជននោះបានប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសដឹងត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ឧទាហរណ៍ ជនវិកលចរិតពីកំណើតបានប្រព្រឹត្តបទល្មើស។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួនជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែតុលាការអាចត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

[108] មាត្រា ១០៤ និងមាត្រា ១១៦ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[109] មាត្រា ១១៧ និងមាត្រា ១២៣ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[110] មាត្រា ៧២ មាត្រា ៧៥ និងមាត្រា ១៦២ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[111] មាត្រា ៣៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។
[112] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[113] មាត្រា ៣៩ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[114] មាត្រា ៣១ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- **ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**[115]

កាលណាបើប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។

- **ការការពារស្របច្បាប់**[116]

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។

បទល្មើស និងជាការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា នេះគឺជាការប្រព្រឹត្តមួយ និងព្រមទាំងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

- **សច្ចធារណ៍នៃការការពារស្របច្បាប់**[117]

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ៖

១. បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយសារកាប់គាស់ទម្លុះទម្លាយ ដោយហឹង្សា ឬដោយល្បិចកលនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។

២. បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំង និងការលួច ឬប្លន់ដែលអនុវត្តដោយហិង្សា។ សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ។

- **ស្ថានភាពចាំបាច់**[118]

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែបានប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវតែមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

១. បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួនការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។

២. គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់។

ដូចនេះទាំង២ចំណុចខាងលើនៃស្ថានភាពចាំចាច់ ជនប្រព្រឹត្តមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

[115] មាត្រា ៣២ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[116] មាត្រា ៣៣ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[117] មាត្រា ៣៤ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[118] មាត្រា ៣៥ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- **អានុភាពនៃកម្លាំង ឬការបង្ខំ**[119]

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។

## ៣.៥. ដំណាក់កាល និងនីតិវិធីក្រោយពេលជំនុំជម្រះ

### ៣.៥.១. សេចក្តីសម្រេច ឬសាលក្រម

#### ៣.៥.១.១. ការប្រកាសសាលក្រម

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមានអំពីថ្ងៃដែលត្រូវប្រកាសសាលក្រម។[120] ចំពោះការប្រកាសពិរុទ្ធភាព តុលាការត្រូវពិនិត្យមើលថាៈ អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ ថាតើជនជាប់ចោទបានប្រព្រឹត្តអំពើដែលត្រូវបានចោទប្រកាន់លើខ្លួនឬទេ។ ប្រសិនបើតុលាការបានពិនិត្យឃើញថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទ តុលាការនឹងសម្រេចប្រកាសផ្តន្ទាទោសទៅតាមបញ្ញត្តិនៃច្បាប់។ ប្រសិនបើតុលាការយល់ឃើញថាអំពើនោះមិនមែនជាបទល្មើសនោះទេ ឬក៏ជនជាប់ចោទគ្មានកំហុសជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទនោះ។[121] ចំពោះវិមតិសង្ស័យ ត្រូវបានជាផលប្រយោជន៍ដល់ជនជាប់ចោទ។

បន្ទាប់ពីតុលាការបានប្រកាសសាលក្រមរួចមក មេធាវីមានតួនាទីសំខាន់ក្នុងការណែនាំកូនក្តីរបស់ខ្លួនទាក់ទងអំពីសិទ្ធិ ក្នុងការធ្វើបណ្តឹងតវ៉ាដល់កូនក្តីរបស់ខ្លួន ក្នុងករណីដែលកូនក្តីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការ។ បណ្តឹងតវ៉ាបន្ទាប់ពីមិនសុខចិត្តពីសាលាដំបូងមាន បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ។ មេធាវីត្រូវតែពន្យល់ណែនាំបន្ថែមអំពីនីតិវិធីនៃការធ្វើបណ្តឹងតវ៉ាដើម្បីឱ្យកូនក្តីបានយល់អំពីនីតិវិធីក្នុងការដាក់បណ្តឹងតវ៉ា ប្រសិនបើជាកូនក្តីមិនមានការសុខចិត្តក្នុងការទទួលយកសាលក្រមរបស់សាលាដំបូងដែលបានចេញរួចហើយនោះ។

#### ៣.៥.១.២. បណ្តឹងទាស់

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប្រសិនបើគ្មានភស្តុតាងបង្ហាញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំង

---

[119] មាត្រា ៣៦ ក្រមព្រហ្មទណ្ឌ, លេខ នស/ រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[120] មាត្រា ៣៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[121] មាត្រា ៣៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

មុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវជំណឹងដល់ជនជាប់ចោទនេះ។ សាលក្រមនេះ អាចប្ដឹងទាស់បាន។ ពិរុទ្ធជន អាចធ្វើបណ្ដឹងទាស់នឹងសាលក្រមដែលប្រកាសកំបាំងមុខខ្លួនបាន។[122]

បណ្ដឹងទាស់ត្រូវធ្វើដោយពាក្យប្ដឹងជាលាយលក្ខណ៍អក្សរៈ[123]

- នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម
- នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្ដឹងទាស់។ ប៉ុន្តែពិរុទ្ធជនជា អនីតិជនអាចត្រូវបានតំណាងដោយអាណាព្យាបាល ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មាន លិខិតប្រគល់សិទ្ធទេ។ បណ្ដឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្ដើមគិតពីថ្ងៃជំណឹងអំពី សាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ និងគិតចាប់ពីថ្ងៃដែល ពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ដៃពិរុទ្ធជន ដោយផ្ទាល់ដៃទេ។[124]

### ៣.៥.១.៣. បណ្ដឹងឧទ្ធរណ៍

សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មានសមត្ថកិច្ច ដើម្បីសម្រេចអំពីបណ្ដឹងឧទ្ធរណ៍ដែលធ្វើប្រឆាំង នឹងសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូង ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនក្នុងរឿងព្រហ្មទណ្ឌ។[125]មេធាវី ដែលតំណាងឱ្យពិរុទ្ធជន បន្ទាប់ពីមានលិខិតប្រគល់ធ្វើជាអ្នកការពារក្ដីជូនពិរុទ្ធជនក្នុងការប្ដឹងឧទ្ធរណ៍។ បុគ្គល ដែលអាចប្ដឹងឧទ្ធរណ៍បានមានដូចជា ព្រះរាជអាជ្ញានៃតុលាការជាន់ទាប និងអគ្គព្រះរាជអាជ្ញាអមសាលា ឧទ្ធរណ៍ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាផលប្រយោជន៍រដ្ឋប្បវេណី ដែលអ្នកទទួលខុសត្រូវ រដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ ការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល ០១ (មួយ) ខែ។ ការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ០៣ (បី) ខែ។ រយៈពេលប្ដឹង ឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម។[126] ការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នក ទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល០១ (មួយ) ខែ។ កាលណាសាលក្រមនោះជា សាលក្រមចំពោះ មុខរយៈពេលប្ដឹងឧទ្ធរណ៍គិតពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកជា

[122] មាត្រា ៤០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[123] មាត្រា ៣៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[124] មាត្រា ៣៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[125] មាត្រា ៣៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[126] មាត្រា ៣៨១ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឱ្យដំណឹងនេះធ្វើទៅតាមវិធីណាក៏ដោយ។[127]

### ៣.៥.១.៤. បណ្ដឹងសារទុក្ខ

បណ្ដឹងសារទុក្ខ គឺជាបណ្ដឹងដែលប្រឆាំង និងមិនពេញចិត្តចំពោះសាលដីការបស់សាលាឧទ្ធរណ៍។ សាលដីកានៃសភាស៊ើបសួរ ដោយគិតបញ្ចូលទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចត្រូវប្ដឹងសាទុក្ខបាន។[128] បុគ្គលដែលអាចធ្វើបណ្ដឹងសារទុក្ខបានមានដូចជា អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជនជាប់ចោទ ឬពិរុទ្ធជន បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី បណ្ដឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល។[129] រយៈពេលដើម្បីធ្វើបណ្ដឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចជា រយៈពេល ០១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍។ រយៈពេល ០៥ (ប្រាំ) ថ្ងៃចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។ កាលណាសាលដីកាដែលប្ដឹងសាទុក្ខជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្ដើមគិតពីការប្រកាសសាលដីកា។ កាលណាសាលដីកាកំបាំងមុខរយៈពេលត្រូវផ្ដើមគិតពីការផុតរយៈពេលប្ដឹងទាស់។[130] ភាគីអាចតាំងមេធាវីបានចាប់តាំងពីពេលចុះបញ្ជីសំណុំរឿង ហើយយ៉ាងយូរបំផុតរហូតដល់មុនថ្ងៃបើកសវនាការ ០១ (មួយ) ថ្ងៃ។ ភាគីត្រូវបញ្ជូនឈ្មោះមេធាវីរបស់ខ្លួនជាលាយលក្ខណ៍អក្សរឱ្យដល់ក្រឡាបញ្ជីតុលាការកំពូល។[131]

### ៣.៥.១.៥. បណ្ដឹងសើរើ

បណ្ដឹងសើរើ ជាបណ្ដឹងតវ៉ាមួយប្រឆាំងទៅនឹងសាលក្រម ឬសាលដីការបស់តុលាការដែលចូលជាស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ។ សភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្ដឹងសើរើ។[132] បណ្ដឹងសើរើត្រូវបានធ្វើក្នុងរឿងព្រហ្មទណ្ឌ ទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណា ឬទោសបីជាទោសនោះបានប្រកាសក៏ដោយ។[133] អ្នកដែលធ្វើបណ្ដឹងសើរើបានគឺ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទណ្ឌិត អ្នកតំណាងស្របច្បាប់សហព័ទ្ធ ឪពុកម្ដាយកូន នឹងជាទូទៅជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬខាងផ្លូវចិត្ត

[127] មាត្រា ៣៨២ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[128] មាត្រា ៤១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[129] មាត្រា ៤១៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[130] មាត្រា ៤២០ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[131] មាត្រា ៤២៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[132] មាត្រា ៤៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

[133] មាត្រា ៤៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

ក្នុងការលុបបំបាត់ទណ្ឌកម្មនេះក្នុងករណីដែលទណ្ឌិតបានទទួលមរណភាព ឬបានបាត់ខ្លួន។[134] អ្នកដែលមានសិទ្ធិប្តឹង ឬប្តឹងជំនួសបានគឺទណ្ឌិតខ្លួនឯង មេធាវី ឪពុកម្តាយ អាណាព្យាបាល បើទណ្ឌិតជានីតិជនមានអាយុចាប់ពី ១៨ឆ្នាំឡើង អាចប្តឹងបានដោយខ្លួនឯង ឬពឹងអ្នកតំណាងឱ្យប្តឹងជំនួស អ្នកតំណាងស្របច្បាប់គឺមេធាវីការពារសិទ្ធិ។ បើទណ្ឌិតជាអនីតិជនមានអាយុលើ ១៤(ដប់បួន) ឆ្នាំ ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំអ្នកដែលអាចប្តឹងជំទាស់មានមេធាវីឪពុកម្តាយ អាណាព្យាបាល។ កាលណាបណ្តឹងជំទាស់ត្រូវបានធ្វើឡើងនោះ សាលក្រម ឬសាលដីកា ដែលបានសម្រេចត្រូវចាត់ទុកជាមិនបានការ ហើយតុលាការដដែលនោះនឹងបើកសវនាការជំនុំជម្រះសាជាថ្មីឡើងវិញ។

[134] មាត្រា ៤៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/ រកម/០៨០៧/០២៤,១០ សីហា ២០០៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងមានការយកចិត្តទុកដាក់ទៅក្នុងប្រធានបទនេះ នៅក្នុងការសរសេរ ស្រាវជ្រាវ ពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ វិជ្ជាជីវៈមេធាវីគឺជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌ ដែលវិជ្ជាជីវៈនេះទៀតសោតបានចូលរួមយ៉ាងសកម្ម ដើម្បីឱ្យដំណើរការនីតិវិធីជំនុំជម្រះមួយប្រកបដោយយុត្តិធម៌។ មេធាវីជាបុគ្គលមួយដែលមានសមត្ថភាពក្នុងការពន្យល់បកស្រាយនឹងប្រឹក្សាយោបល់ជូនកូនក្តីក្នុងរឿងព្រហ្មទណ្ឌ។ មួយវិញទៀតមេធាវីអាចការសិទ្ធិ និងការពារផលប្រយោជន៍ជូនកូនក្តីបានតាមរយៈ ពាក្យពឹងពាក់មេធាវី ពាក្យសុំការពារក្តីក្នុងរឿងក្តីព្រហ្មទណ្ឌ មេធាវីមានសិទ្ធិ និងកាតព្វកិច្ចយ៉ាងធំធេងក្នុងការចូលរួមស្វែងរកឱ្យឃើញនូវការពិត។ មេធាវីមានតួនាទីយ៉ាងសំខាន់ទៅតាមដំណាក់កាលនីតិវិធី មិនថាដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់ការអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ ដំណាក់កាលជំនុំជម្រះ ដំណាក់កាលក្រោយជំនុំជម្រះ នឹងការធ្វើបណ្តឹងទាស់ទៅតុលាការជាន់ខ្ពស់។

ជាមួយគ្នានេះដែរ មេធាវីមានតួនាទីយ៉ាងសំខាន់ ដែលជាបុគ្គលផ្នែកច្បាប់ ក្នុងការប្រឹក្សាយោប់ និងមានការពន្យល់ទៅដល់ប្រជាពលរដ្ឋ និងជាបុគ្គលដែលមានចំណេះដឹងនៅក្នុងប្រទេសជាតិ។ មេធាវីមានសារៈសំខាន់ចំពោះ ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទពិរុទ្ធជនទៅតាមដំណាក់កាលនីមួយៗជាចាំបាច់ ដើម្បីឱ្យដំណើរការកិច្ចនីតិវិធីមួយប្រកបដោយតម្លាភាព ឯករាជ្យភាព និងយុត្តិធម៌។ មេធាវីអាចតំណាងជូនកូនក្តីជាច្រើនដូចជា ការស្វែងរកភស្តុតាងដោះបន្ទុកភស្តុតាងដាក់បន្ទុក សាក្សីដោះបន្ទុកដែលខ្លួនយល់ឃើញថា មានផលប្រយោជន៍សម្រាប់កូនក្តីរបស់ខ្លួន។ មេធាវីអាចអមកូនក្តីចូលឆ្លើយបំភ្លឺនៅគ្រប់ដំណាក់កាលទាំងអស់។ មេធាវីមានសិទ្ធិឱ្យកូនក្តីរបស់មិនឆ្លើយសំណួរបានប្រសិនបើខ្លួនយល់ឃើញថាវាមានផលប៉ះពាល់ដល់សិទ្ធិផលប្រយោជន៏របស់កូនក្តី។ មេធាវីមានសិទ្ធិប្តឹងជំទាស់ ចំពោះអ្វីដែលខ្លួនយល់ឃើញថាប៉ះពាល់សិទ្ធិរបស់កូនក្តីខ្លួនដូចជាការសួរជម្រិតឱ្យកូនក្តីខ្លួនសារភាពទទួលស្គាល់នូវកំហុស សាក្សីបានផ្តល់សក្ខីកម្មក្លែងក្លាយ ឬការសួរសំណួរណាដែលគ្មានវត្តមានមេធាវីចូលរួម ឬមានការបង្ខិតបង្ខំ។ មេធាវីអាចស្នើសុំជូនកូនក្តីរបស់ខ្លួន នូវស្ថានសម្រាលទោសឬសុំរួចផុតពីបទចោទប្រកាន់បានប្រសិនបើកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តនូវបទល្មើស។ ដើម្បីក្លាយជាអ្នកប្រកបវិជ្ជាជីវៈ មេធាវីគឺត្រូវតែគោរពឱ្យបានត្រឹមត្រូវទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ទើបអាចប្រកបវិជ្ជាជីវៈបាន។ មេធាវីមានតួនាទី និងភារកិច្ច ក្នុងការពារផលប្រយោជន៍កូនក្តី ដែលមេធាវីមានសិទ្ធិក្នុងការធានាសិទ្ធិក្នុងវិជ្ជាជីវៈមិនគ្មានការជ្រៀតជ្រែក សិទ្ធិក្នុងការទទួលបានការការពារ។ មេធាវីក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ ត្រូវមានវត្តមានរបស់មេធាវី ក្នុងការពារសិទ្ធិសម្រាប់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទពិរុទ្ធជន ក្នុងការរួមចំណែកធានាថា ដំណើរការរឿងក្តីនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលទៅប្រកបដោយភាព

ត្រឹមត្រូវ និងមានភាពយុត្តិធម៌។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ មេធាវីមានតួនាទី និងភារកិច្ចយ៉ាងសំខាន់នៅក្នុងការការពារសិទ្ធិ និងភារកិច្ចផ្សេងៗ ដែលមានការអនុវត្តបានក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។ មេធាវី អាចការពារសិទ្ធិរបស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ តាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដែលមេធាវីអាចជាអ្នកការពារសិទ្ធិ រហូតដល់មានការចេញសេចក្តីសម្រេចរបស់តុលាការ ដែលជាសាលក្រម ឬសាលដីកា ដែលជនត្រូវចោទមានជាប់ទោស ឬមិនមានជាប់ទោសនៅក្នុងរឿងព្រហ្មទណ្ឌ។ នៅក្នុងរឿងព្រហ្មទណ្ឌ មេធាវីមិនជាអ្នកការពារសិទ្ធិឱ្យជនល្មើស។ នៅក្នុងដំណាក់កាលស៊ើបអង្កេត មេធាវីត្រូវធ្វើការអមជាមួយជនសង្ស័យ ដែលជននោះ ត្រូវតែមានការផ្តល់នូវចម្លើយតាមការសាកសួររបស់ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ និងមានព្រះរាជអាជ្ញា។ ចំពោះក្នុងករណី ជនស្ស័យគ្មានមេធាវីដោយមានការឃាត់ខ្លួននៅក្នុងដំណាក់កាលនគរបាលយុត្តធម៌ ជននោះអាចមានសិទ្ធិមានមេធាវីបន្ទាប់ពីការឃាត់ខ្លួន។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តធម៌ និងព្រះរាជអាជ្ញាមានការធ្វើទារុណកម្ម ឬបានប្រើប្រាស់នូវអំពើហិង្សា ក្នុងការឱ្យជនល្មើស ឬជនសង្ស័យមានការឆ្លើយតបទៅនឹងតម្រូវការទាំងនេះ ក្នុងការចាប់បង្ខំ ឬឱ្យឆ្លើយសារភាព មេធាវីអាចធ្វើការប្តឹងទៅនឹងកំណត់ហេតុនោះទុកជាមោឃៈ។ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ មេធាវីមានតួនាទីយ៉ាងសំខាន់ក្នុងការចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការការពារសិទ្ធិរបស់ជនត្រូវចោទ។ នៅក្នុងដំណាក់កាលជំនុំជម្រះ មេធាវីមានសិទ្ធិនៅក្នុងការអមកូនក្តីរបស់ខ្លួន ដោយមិនមានសិទ្ធិនៅក្នុងការឆ្លើយជំនួសកូនក្តីបានទេ។ មេធាវីមានតួនាទី និង ភារកិច្ច មានសិទ្ធិក្នុការកាពារ ប្រឹក្សាយោបល់ និងមានសិទ្ធិដឹងនៅដឹងរាល់គ្រប់ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលព្រះរាជាអាជ្ញា ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ មេធាវីមានកិច្ចការពារកូនក្តីឱ្យជនជាប់ចោទ។ ប្រសិនបើមិនសុទ្ធចិត្ត អាចមានសិទ្ធិប្តឹងឧបាស្រ័យទៅតុលាការឧទ្ធរណ៍ និងតុលាការកំពូល តាមរយៈចេញសាលក្រម និងសាលដីកា។

ជាចុងបញ្ចប់មេធាវី ជាវិជ្ជាជីវៈមួយដ៏សំខាន់ដែលមិនអាចខ្វះបាន ព្រោះមេធាវីជាបុគ្គលដែលប្រកបដោយចំណេះដឹង និងដើរតួនាទីយ៉ាងសំខាន់សម្រាប់ការបំពេញសេវាកម្មជូនកូនក្តីប្រកបដោយប្រសិទ្ធិភាពខ្ពស់។ មួយវិញទៀតវិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈដែលឯករាជ្យ មិនស្ថិតនៅក្រោមឱវាទស្ថាប័ន ឬក្រសួងណាមួយនោះទេ។ ប៉ុន្តែសមាជិកមេធាវីទាំងអស់ស្ថិតនៅក្រោមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយប្រធានគណៈមេធាវីមួយរូប និងក្រុមប្រឹក្សាគណៈមេធាវីជាច្រើនរូប។ គណៈមេធាវីមានសមត្ថកិច្ចក្នុងការដាក់ទោសមេធាវីណាដែលប្រព្រឹត្តខុស ដូចជាការព្យួរ ឬដេញចេញពីក្រមខណ្ឌផងដែរ។ ដោយបច្ចុប្បន្ននេះគណៈមេធាវីមានគោលនយោបាយក្នុងការបម្រើសេវាកម្មដោយមិនទទួលប្រាក់កម្រៃ ចំពោះជនក្រីក្រ។ មេធាវីជាបុគ្គលយ៉ាងសំខាន់នៅក្នុងសង្គម ក្នុងការជួយទៅដល់ប្រទេសជាតិ។ មេធាវីបំពេញតួនាទីយ៉ាងជិតស្និទ្ធិ

ជាមួយស្ថាប័នតុលាការក្នុងការស្វែងរកភស្តុតាងបន្ថែម ផ្តល់ជាមូលដ្ឋានក្នុងការត្រិះរិះពិចារណាចៅក្រមសម្រេចក្នុងការដាក់ទណ្ឌកម្មចំពោះបុគ្គលដែលប្រើប្រាស់សិទ្ធិរបស់ខ្លួនបំពាននឹងបទប្បញ្ញត្តិច្បាប់ប្រកបដោយតម្លាភាព គណនេយ្យភាព និងយុត្តិធម៌។ ដូចនេះ មេធាវីមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការចូលរួមលើកស្ទួយវិស័យយុត្តិធម៌ នីតិរដ្ឋ និងប្រជាធិបតេយ្យ ដើម្បីធ្វើអោយប្រទេសជាតិឱ្យបានកើនឡើងជាអតិបរមានូវការរៀបសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិភាព និងមានការរីកចម្រើនទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលមានដូចជាវិស័យនយោបាយ វិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច វិស័យវប្បធម៌ និងមានវិស័យយុត្តិធម៌ផងដែរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ អំពីតួនាទី និងភារកិច្ចមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌរួចមកក្រុមយើងខ្ញុំបានសង្កេតឃើញថាមេធាវីវិជ្ជាជីវៈមេធាវីពិតជាមានគុណសម្បត្តិជាច្រើន។ នៅក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌមួយប្រកបដោយយុត្តិធម៌ និងធានាបាននូវតម្លាភាព ការពារផលប្រយោជន៍ស្របច្បាប់ជនចំពោះជនជាប់ចោទ និងជនរងគ្រោះ។ ជាមួយគ្នានេះផងដែរខ្ញុំបានសង្កេតឃើញថាមេធាវីមានតួនាទីយ៉ាងសំខាន់នៅគ្រប់ដំណាក់កាលនីតិវិធីដូចជា ដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបន្តបន្ទាប់ទៀតផងដែរ។ ម្យ៉ាងវិញទៀតខ្ញុំបានយល់ឃើញថាចំណុចសំខាន់ៗជាច្រើនដែលជម្រុញធ្វើឱ្យវិជ្ជាជីវៈនេះបានដំណើរការនីតិវិធីបានល្អ នៅក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចជូនកូនក្តីប្រកបដោយទំនុកចិត្ត និងប្រសិទ្ធិភាពខ្ពស់មានដូចជា៖

- មេធាវីជាវិជ្ជាជីវៈសេរី ឯករាជ្យ តម្លាភាព ជាវិជ្ជាជីវៈមួយកើតចេញពីការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវដោយមេធាវីអាចប្រកបវិជ្ជាជីវៈនេះបាន២របៀបគឺ ការប្រលងប្រជែង និងការធ្វើសច្ចាប្រណិធានប្រកបវិជ្ជាជីវៈ។
- មេធាវីទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ ល្អិតល្អន់ប្រកបដោយគុណភាព ចំណេះដឹង សីលធម៌ គុណធម៌ សច្ចធម៌ តាមរយការសិក្សារៀនសូត្រ និងអនុវត្តតាមច្បាប់ដែលគណៈមេធាវីបានកំណត់ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី ជាដើម។
- មេធាវីត្រូវយល់ច្បាស់អំពីនីតិវិធីជាច្រើននៅតុលាការ ជាពិសេសរឿងក្តីព្រហ្មទណ្ឌ ដែលមេធាវីមានកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់ជូនកូនក្តី និងការពារសិទ្ធិនិងផលប្រយោជន៍ជូនកូនក្តីដែលមិនអាចឱ្យជនណារំលោភបំពានបាន។
- មេធាវីមានកាតព្វកិច្ចជួយផ្សះផ្សា និងជួយដោះស្រាយបញ្ហាជូនកូនក្តីដែលមេធាវីនេះបានទទួលពាក្យសុំពឹងពាក់មេធាវីពីកូនក្តី និងមានតួនាទី ធ្វើពាក្យបណ្តឹងនានាទៅតាមដំណាក់កាលនីតិវិធីដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់កូនក្តី។

មេធាវីត្រូវស្វែងរកនូវភស្តុតាងដែលអាចគាំទ្រអំណះអំណាងរបស់ខ្លួន និងកូនក្តីរបស់ខ្លួន។ មេធាវីត្រូវបំពេញកាតព្វកិច្ចយ៉ាងត្រឹមត្រូវ ជូនក្តីរបស់ខ្លួនដោយមិនប្រើមធ្យោបាយទុច្ចរិតណាមួយ ដើម្បីឱ្យទទួលបានឈ្នះក្តីបាននោះឡើយ។មិនតែប៉ុណ្ណោះក៏យើងខ្ញុំសង្កេតឃើញមាននូវគុណវិបត្តិជាច្រើនផងដែរដូចជា៖

- ការងារមួយចំនួនមានភាពអសកម្មរបស់មេធាវីមួយចំនួនដែលធ្វើឱ្យខូចប្រយោជន៍ដល់កូនក្តីដូចជាការយឺតយ៉ាវនៃនីតិវិធី។
- ការមិនយកចិត្តទុកដាក់លើកិច្ចការសំណុំរឿងជាដើមផងដែរ។

- មេធាវីមិនគួរញុះញង់កូនក្តីរបស់ខ្លួនឱ្យធ្វើតាមខ្លួននោះទេ។ មេធាវីមានសិទ្ធិត្រឹមតែការពារសិទ្ធិជូនកូនក្តីតែប៉ុណ្ណោះ មិនអាចធានាកូនក្តីរបស់ខ្លួនថាឈ្នះក្តីនោះទេ។
- ម៉្យាងវិញទៀតបុគ្គលមួយចំនួនតូចមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានល្អនោះទេ ដែលធ្វើឱ្យប្រាសចាកពីក្រមសីលធម៌របស់មេធាវីផងដែរ ដូចជាការកែប្រែសំណុំរឿង ឬការប្តូរបទចោទពីស្រាលទៅចោទប្រកាន់ធ្ងន់ដែលវាធ្វើឱ្យបាត់បង់នូវតម្លៃវិជ្ជាជីវៈផងដែរ។
- បញ្ហាសង្គមដែលមានការជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់មេធាវី ដែលជាអំពើពុករលួយមួយ ដែលធ្វើឱ្យបាត់បង់នូវគុណធម៌ ឆន្ទៈ និងការទទួលខុសត្រូវរបស់មេធាវី។
- នៅក្នុងសំណុំរឿង មេធាវីពុំបានធ្វើការយកចិត្តទុកដាក់នៅក្នុងរឿងក្តីរបស់ខ្លួន ដោយពុំបានយល់ច្បាស់នូវអង្គហេតុរបស់កូនក្តីរបស់ខ្លួន ដែលជាហេតុមួយធ្វើឱ្យមានការបាត់បង់នូវសមត្ថភាពក្នុងការពារក្តីនៅពេលសវនាការ។
- ការសន្និដ្ឋានរបស់មេធាវី ដូចជាមានការកង្វះខាត ដែលពុំអាចធ្វើការជួយកូនក្តីរបស់ខ្លួននៅក្នុងការពាររួចផុតពីបទចោទ។ ចំណែកការសំណូមពរជូនកូនក្តី មិនបានគិតពិចារណានូវអ្វីដែលជាហេតុក្នុងការសំណូមពរពីតុលាការ ។

ជាមួយគ្នានេះផងដែរ មេធាវីត្រូវបំពេញនូវកាតព្វកិច្ចរបស់ខ្លួនដោយឈរលើគោលការណ៍សមភាពយុត្តិធម៌ ជាចំបង។ ចំពោះការប្រលងប្រកបវិជ្ជាជីវៈប្រកបវិជ្ជាជីវៈគួរតែមានការរឹតបន្តឹងជាចាំបាច់បំផុត ដើម្បីធានាឱ្យបាននូវគុណភាពជាសំខាន់។ មិនតែប៉ុណ្ណោះមេធាវីគួរតែមានចំណេះដឹងខ្ពង់ខ្ពស់ និងមានសមត្ថភាពខ្ពស់ដើម្បីធានាបាននូវទំនុកចិត្តសម្រាប់អតិថិជនរបស់ខ្លួនផងដែរ។ ប្រសិនបើមេធាវីមានកំហុសត្រូវតែទទួលខុសត្រូវចំពោះមុខគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងចំពោះមុខតុលាការផងដែរ។ មេធាវីអាចទទួលខុសត្រូវព្រហ្មទណ្ឌ និងទទួលខុសត្រូវរដ្ឋប្បវេណីចំពោះកូនក្តីខ្លួនប្រសិនបើរកឃើញថាកំហុសនោះជាកំហុសរបស់មេធាវី។

សរុបសេចក្តីមកគុណសម្បត្តិ និងគុណវិបត្តិរបស់មេធាវីជាចំណុចមួយដែលយើងគួរយកចិត្តទុកដាក់ជាទីបំផុត។ ហេតុដូច្នេះហើយមេធាវីត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីធានាឱ្យបានល្អត្រឹមត្រូវជៀសវាងការមានកំហុសកើតឡើងដោយថាហេតុ។ មេធាវីត្រូវមានក្រមសីលធម៌ខ្ពស់នៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន នៅក្នុងការជួយសង្គម មិនដោយសារតែប្រាក់ចំណូល អំណាចអ្វីមួយ ដែលធ្វើឱ្យបាត់បង់នូវគុណធម៌ សីលធម៌ជាអ្នកប្រកបវិជ្ជាជីវៈមេធាវីឡើយ ដែលធ្វើអោយមេធាវីមានការអន់ថយយ៉ាងខ្លាំងនៅក្នុងសង្គម។ ចំណែកនៅក្នុងតុលាការ មេធាវីពុំអាចធ្វើការគោរពហួសតុលាការ ដោយសារមេធាវីគឺជាស្ថាប័នដាច់ដោយឡែកពីប្រព័ន្ធតុលាការ ការគោរពខ្លាំងអាចជាបញ្ហាមួយ ដែលធ្វើឱ្យមានការអន់ថយនៅក្នុងការប្រកបវិជ្ជាជីវៈមេធាវី។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយរដ្ឋសភាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧។
- ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបរៀងដោយគណៈមេធាវី ថ្ងៃទីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥។
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ប្រកាសឱ្យប្រើដោយរដ្ឋសភា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥។
- បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបរៀងដោយគណៈមេធាវីនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានអនុម័តនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។
- ច្បាប់ស្តីពីសញ្ជាតិ នស/រកម/១០៩៦/៣០ ប្រកាសឱ្យប្រើថ្ងៃទី២០ខែសីហាឆ្នាំ១៩៩៦។
- ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

## ២. អនុក្រឹត្យ

- អនុក្រឹត្យស្តីអំពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

## ៣. សេចក្តីសម្រេច

- សេចក្តីសម្រេចពីនីតិវិធីនៃការត្រួតពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈមាត្រា៣២នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។

## ៤. អត្ថបទស្រាវជ្រាវ

- សិក្ខាសាលាស្តីពី "ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌៖ ការផ្សព្វផ្សាយពីតួនាទី និងការទទួលខុសត្រូវរបស់មេធាវី ដឹកនាំដោយគណៈមេធាវី ឯកឧត្តម **លី ច័ន្ទតុលា**។
- វគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះនៃដំណើរការសវនាការក្នុងរឿងក្តីព្រហ្មទណ្ឌ រៀបរៀងនិងបណ្តុះបណ្តាលដោយលោកមេធាវី **សួន វីរៈបញ្ញា** និង កញ្ញាមេធាវី **ហេង ឆព្វណ្ណរង្សី**។
- ឯកសារបច្ចេកទេសការពារក្តីក្នុងរឿងព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្តម **សួន វិសាល**។
- ឯកសារជំនាញនៃការជំនុំជម្រះរឿងក្តី រៀបរៀងដោយ ឯកឧត្តម **សួន វិសាល**។

- ការទទួលខុសត្រូវលើមុខវិជ្ជាជីវៈមេធាវី ដែលមានការរៀបរៀងដោយ **និក វីណា** និង **លី អ៊ុយម៉េង** នៅមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ សាលាច្បាប់នៃសាកលវិទ្យាល័យសាន់ហ្វ្រាន់ស៊ីស្កូ កម្មវិធីច្បាប់និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។
- មេរៀននីតិវិធីព្រហ្មទណ្ឌរៀបរៀងដោយលោកស្រី **ឌី លីឡា** និងលោក **ខាន់ សុខា**។
- តួនាទីរបស់មេធាវីទាក់ទងតុលាការរៀបរៀងដោយ ឯកឧត្តម **សួន វិសាល** នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៦។
- តួនាទី កិច្ចការស្រាវជ្រាវពីក្លឹបបណ្តុះបណ្តាលពង្រឹងសមត្ថភាពវិជ្ជាជីវៈច្បាប់។
- តួនាទី និងភារកិច្ចរបស់មេធាវីនៅប្រទេសកម្ពុជា ជាឯកសារស្រាវជ្រាវសង្ខេបពីគណៈកម្មការទី៦ នៃព្រឹទ្ធសភា នៃវិទ្យាស្ថានសភាកម្ពុជា នៅខែកុម្ភៈ ឆ្នាំ២០១៧។
- ការទទួលខុសត្រូវលើមុខវិជ្ជាជីវៈមេធាវី ដោយលោកគ្រូ **ម៉ាស់ផ្សូរ វិនដល** និង **ស្មិនហ្វឹន ម្សូដុច**។

**៥. វចនានុក្រម និងសន្ទានុក្រម**

- វចនានុក្រម ដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលបានបោះពុម្ពដោយសាសនាបណ្ឌិតភ្នំពេញ ឆ្នាំ១៩៦៧។
- សន្ទានុក្រមពាក្យច្បាប់ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១២ សម្ព័ន្ធបញ្ញាវន្តដើម្បីអភិវឌ្ឍន៍ឆ្នាំ២០១២។
- វាក្យស័ព្ទច្បាប់របស់សាលាត្រាជូ។

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖ បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**ឧបសម្ព័ន្ធទី២ ៖ ឯកសារបទដ្ឋានគតិយុត្តិរបស់មេធាវី**

- ឧបសម្ព័ន្ធទី១ ៖ ពាក្យសុំការពារក្តី
- ឧបសម្ព័ន្ធទី២ ៖ ពាក្យសុំពឹងពាក់មេធាវី
- ឧបសម្ព័ន្ធទី៣ ៖ ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង
- ឧបសម្ព័ន្ធទី៤ ៖ ពាក្យសុំពន្យាពេល
- ឧបសម្ព័ន្ធទី៥ ៖ ពាក្យសុំអនុញ្ញាតជូនកូនក្តី
- ឧបសម្ព័ន្ធទី៦ ៖ ពាក្យសុំបញ្ចូលភស្តុតាង
- ឧបសម្ព័ន្ធទី៧ ៖ ពាក្យសុំពន្យាពេលចូលឆ្លើយបំភ្លឺ
- ឧបសម្ព័ន្ធទី៨ ៖ ពាក្យស្នើសុំឱ្យមោឃភាពនីតិវិធី
- ឧបសម្ព័ន្ធទី៩ ៖ ពាក្យសុំឱ្យកូនក្តីនៅក្រៅឃុំ
- ឧបសម្ព័ន្ធទី១០ ៖ ពាក្យស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ
- ឧបសម្ព័ន្ធទី១១ ៖ សេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវី
- ឧបសម្ព័ន្ធទី១២ ៖ ពាក្យសុំពន្លឿននីតិវិធី
- ឧបសម្ព័ន្ធទី១៣ ៖ លិខិតប្រល់សិទ្ធិប្តឹងទាស់
- ឧបសម្ព័ន្ធទី១៤ ៖ ពាក្យបណ្តឹងទាស់
- ឧបសម្ព័ន្ធទី១៥ ៖ លិខិតប្រល់សិទ្ធិប្តឹងឧទ្ធរណ៍
- ឧបសម្ព័ន្ធទី១៦ ៖ ពាក្យបណ្តឹងឧទ្ធរណ៍
- ឧបសម្ព័ន្ធទី១៧ ៖ លិខិតប្រគល់សិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណី
- ឧបសម្ព័ន្ធទី១៨ ៖ ពាក្យបណ្តឹងទាមទារសំណងរដ្ឋប្បវេណី
- ឧបសម្ព័ន្ធទី១៩ ៖ ពាក្យសុំពន្យាពេលដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ
- ឧបសម្ព័ន្ធទី២០ ៖ ពាក្យបណ្តឹងសាទុក្ខ
- ឧបសម្ព័ន្ធទី២១ ៖ ពាក្យសុំឈប់ការពារក្តី

**ឧបសម្ព័ន្ធទី៣ ៖ សាលក្រម**

- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ ៖ បទធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្រង់ទោស។

- សាលក្រមសាលាដំបូងខេត្តកំពង់ធំ ៖ បទបើកបរធ្វើប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្ដាលឱ្យរបួសអ្នកដទៃ។
- សាលក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ៖ បទសម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ ៖ បទឃាតកម្មគិតទុកជាមុន។

**ឧបសម្ព័ន្ធទី៤ ៖ សាលដីកា**

- សាលដីកាសាលាឧទ្ធរណ៍ភ្នំពេញ ៖ បទផ្ដល់សក្ខីភាពខ្លែង និងក្លែងលិខិតឯកជន។
- សាលដីកាសាលាឧទ្ធរណ៍ ៖ បទប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អលនវត្ថុដោយសុចរិត និងធ្វើឱ្យប៉ះពាល់ដោយចេតនា។
- សាលដីកាសាលាឧទ្ធរណ៍ភ្នំពេញ ៖ បទឆបោក។

# ឧបសម្ព័ន្ធទី១
# បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# បទបញ្ជាផ្ទៃក្នុង

# នៃ គណៈមេធាវី

# នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១

## វិធានវិជ្ជាជីវៈមេធាវី

ប្រការ១ - វិធានវិជ្ជាជីវៈមេធាវី

## ជំពូកទី ២

## មហាសន្និបាតគណៈមេធាវី

ប្រការ២ - ការរៀបចំ មហាសន្និបាតគណៈមេធាវី

ប្រការ៣ - ការរៀបចំការបោះឆ្នោត

## ជំពូកទី ៣

## ក្រុមប្រឹក្សាគណៈមេធាវី

ប្រការ៤ - ការប្រជុំ និងការពិភាក្សា នៃក្រុមប្រឹក្សាគណៈមេធាវី

ប្រការ៥ - ការចាត់តាំង ដោយក្រុមប្រឹក្សាគណៈមេធាវី

## ជំពូកទី៤

## ជំនួយសង្គ្រោះ តាមផ្លូវតុលាការ

ប្រការ៦ - ការចាត់តាំង មេធាវីស្ម័គ្រចិត្ត ដោយប្រធានគណៈមេធាវី

ប្រការ៧ - ប្រាក់បំណាច់ផ្តាច់ឲ្យមេធាវីស្ម័គ្រចិត្ត

## ជំពូកទី ៥

## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

## ការចូលបំពេញវិជ្ជាជីវៈ

ប្រការ៨ - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

ប្រការ៩ - គណៈមេប្រយោគ

## ជំពូកទី ៦

## ការរៀបចំកម្មសិក្សា

ប្រការ១០ - ការរៀបចំកម្មសិក្សា

ប្រការ១១ - គ្រូកម្មសិក្សា និងកម្មសិក្សាការី

ប្រការ១២ - ការព្យួរ និងការបញ្ចប់កម្មសិក្សា

## ជំពូកទី ៧

## ការគ្រប់គ្រងមូលនិធិ និងប្រាក់ដំកល់ទុក

ប្រការ១៣ - បេឡាទូទាត់របស់គណៈមេធាវី

ប្រការ១៤ - ការប្រព្រឹត្តទៅនៃបេឡា

ប្រការ១៥ - ការកាត់យកប្រាក់កំរៃមេធាវី

ប្រការ១៦ - ការត្រួតពិនិត្យ របស់ប្រធានគណៈមេធាវី

## ជំពូកទី ៨

## កាតព្វកិច្ចគណនេយ្យ និងការត្រួតពិនិត្យ

ប្រការ១៧ - កាតព្វកិច្ចគណនេយ្យ

ប្រការ១៨ - ការត្រួតពិនិត្យ និងការពិនិត្យបញ្ជាក់

❖❖❖❖

**កំណត់សំគាល់**

ច្បាប់ដែលអត្ថបទនេះរំលឹកឡើងនោះ គឺច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដែលបានប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ ន.ស ០៤_៩៥_០៦ ចុះថ្ងៃទី២២/៨/៩៥ ។

## ជំពូកទី១

## វិធាន វិជ្ជាជីវៈមេធាវី

**ប្រការ១** - វិធាន វិជ្ជាជីវៈមេធាវី

មេធាវីដែលត្រូវបានចុះឈ្មោះ ក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រតិបត្តិ និង គោរព គ្រប់វិធានវិជ្ជាជីវៈ ដែលកំណត់ដោយ " ក្រមសីលធម៌ នៃមេធាវីដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា " ។

## ជំពូកទី២

## មហាសន្និបាត គណៈមេធាវី

**ប្រការ២** - ការរៀបចំ មហាសន្និបាតគណៈមេធាវី

មហាសន្និបាត ប្រមូលផ្ដុំមេធាវីទាំងអស់ដែលត្រូវបានចុះឈ្មោះ ក្នុងបញ្ជីគណៈមេធាវី និងចុះឈ្មោះក្នុងបញ្ជីមេធាវីកម្មសិក្សា ។

មហាសន្និបាតនេះ មានគោលដៅ ជូនពត៌មាន ឬ ពិគ្រោះយោបល់ ។ មហាសន្និបាត អាចលើកសំណូមពរ ឬ លើកញ្ញត្តិ ដែលក្រុមប្រឹក្សាគណៈមេធាវី ត្រូវសំរេចក្នុងថិរៈវេលា ៣ ខែ ។

មានតែមេធាវីដែលមានសិទ្ធិបោះឆ្នោត ទើបអាចចូលរួមក្នុងការពិភាក្សារបស់មហាសន្និបាត ។

ក្រៅពីការកោះប្រជុំសំរាប់ធ្វើការបោះឆ្នោត ការកោះប្រជុំមហាសន្និបាតត្រូវធ្វើ យ៉ាងហោចណាស់មួយឆ្នាំម្ដង តាមការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ ។

លើកលែងតែមានកិច្ចការប្រញាប់ របៀបវារៈនេះ ត្រូវឲ្យសហភាគីបានដឹងមួយខែមុនយ៉ាងតិច តាមគ្រប់មធ្យោបាយសមស្រប ។

មេធាវីមួយរូបៗ អាចសុំចុះបញ្ហារបស់ខ្លួនក្នុងរបៀបវារៈបាន ដោយធ្វើពាក្យសុំ ផ្ញើទៅក្រុមប្រឹក្សាគណៈមេធាវី ១៥ ថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំ តាមរយៈនៃលិខិតអនុសិដ្ឋ ដែលមានចុះថាបានទទួល ឬ តាមលិខិត ដាក់ជូនអគ្គលេខាធិការដ្ឋាន ដោយមានបង្កាន់ដៃទទួល ។

មហាសន្និបាត ប្រព្រឹត្តទៅ ក្រោមអធិបតីភាពរបស់ប្រធានគណៈមេធាវី ។

បើប្រសិនជាត្រូវធ្វើការបោះឆ្នោត ត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែក្នុងករណីជ្រើសរើសប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ។

ការបោះឆ្នោត តាមព្រឹតិបត្តិសំងាត់ អាចសំរេចដោយប្រធានគណៈមេធាវី ឬ ដោយសំណើរបស់សមាជិក ដែលមានចំនួន ១/៥ នៃសមាជិកវត្តមាន ។

**ប្រការ៣** _ ការរៀបចំការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសសមាជិក ក្រុមប្រឹក្សាគណៈមេធាវី ត្រូវធ្វើឡើង ៣ ឆ្នាំម្តង ។ ការបោះ_ឆ្នោតជ្រើសរើសប្រធានគណៈមេធាវី ត្រូវធ្វើឡើង២ ឆ្នាំម្តង ។

ការបោះឆ្នោតប្រព្រឹត្តទៅនៅថ្ងៃទី ១៦ តុលា នៃឆ្នាំដែលត្រូវបោះឆ្នោត ក្នុងសម័យប្រជុំជាសាធារណៈ។

មេធាវីអ្នកបោះឆ្នោត ត្រូវកោះអញ្ជើញ មួយខែ មុនថ្ងៃបោះឆ្នោត តាមគ្រប់មធ្យោបាយសមស្រប ( លិខិតមានលក្ខណៈជាសារាចរ ឬ ផ្សាយតាមវិទ្យុ ទូរទស្សន៍ សារពត៌មាន និងប្រកាសបិទផ្សាយនៅមន្ទីរគណៈមេធាវី ) ។

បេក្ខភាព ត្រូវធ្វើឡើងជាលាយលក្ខ័អក្សរ ដាក់ជូនទៅប្រធានគណៈមេធាវី យ៉ាងតិច ១ ខែមុនការបោះឆ្នោត បើមិនដូច្នោះ និងមិនត្រូវបានទទួលឡើយ ។ ឈ្មោះនៃបេក្ខជនទាំងអស់ ត្រូវផ្សព្វផ្សាយតាមគ្រប់វិធី សមស្របហើយត្រូវបិទនៅការិយាល័យបោះឆ្នោត ។

ការបោះឆ្នោត និងអាចប្រព្រឹត្តទៅ លុះត្រាវត្តមានសមាជិកនៃគណៈមេធាវី មានចំនួនលើសពីពាក់កណ្តាល ។

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលមានវ័យចំណាស់ជាងគេ ។

ប្រធានគណៈមេធាវី ឬ តំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬ នៅពេលរាប់សន្លឹកឆ្នោត ។

មេធាវី នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត ត្រូវបង្ហាញប័ណ្ណវិជ្ជាជីវៈ ដើម្បីបញ្ជាក់អំពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត ។

ការបោះឆ្នោត តាមរយៈការប្រគល់សិទ្ធិ អាចទទួលយកបាន ។ មេធាវីម្នាក់ៗ អាចទទួលការប្រគល់សិទ្ធិបានតែមួយប៉ុណ្ណោះ ។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ ត្រូវចាត់ទុកជាមោឃៈ ។ ការបោះឆ្នោតដោយក្រដាស សលាត ឬ មោឃៈ ត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកភាគច្រើនឡើយ ។

លទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោត ហើយលទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខ័អក្សរ ទៅលោកអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ ។ ក្រុមប្រឹក្សាគណៈមេធាវី ត្រូវទទួលដឹងឮលទ្ធផលនេះ នៅសម័យប្រជុំរបស់ខ្លួនជាបន្ទាប់ ។

## ជំពូកទី ៣

## ក្រុមប្រឹក្សា គណៈមេធាវី

**ប្រការ៤** - **ការប្រជុំនិងការពិភាក្សា នៃក្រុមប្រឹក្សាគណៈមេធាវី**

ក្រុមប្រឹក្សាគណៈមេធាវី រួមប្រជុំតាមការផ្ដើមគំនិតរបស់ប្រធានគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ ។

ការប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវី គឺជាការប្រជុំមិនសាធារណៈ លើកលែងតែក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិពាក់ព័ន្ធផ្ទាល់ និងនីតិវិធីដាក់វិន័យ ។

ក្រុមប្រឹក្សាគណៈមេធាវី និងអាចបើកប្រជុំបាន ប្រសិនបើមានវត្តមានសមាជិកជាងពាក់កណ្ដាល ។ ការសំរេចរបស់ក្រុមប្រឹក្សា ផ្អែកលើសំឡេងបញ្ចេញមតិភាគច្រើន ។ ប្រធានគណៈមេធាវីត្រូវបោះឆ្នោតជាមួយសមាជិកក្រុមប្រឹក្សាគណៈមេធាវី តែសំឡេងរបស់ប្រធាន ពុំមានឧត្តមានុភាពឡើយ ។

កំណត់ហេតុប្រជុំ ត្រូវធ្វើឡើងដោយលេខាធិការរបស់ក្រុមប្រឹក្សា ។ កំណត់ហេតុនេះ និងទុកជាស្ថាពរបាន លុះត្រាមានការយល់ព្រមពីក្រុមប្រឹក្សា ។

សមាជិកគ្រប់រូប នៃគណៈមេធាវីអាចសុំមើល និងដឹងបាននូវកំណត់ហេតុប្រជុំនោះ នៅលេខាធិការដ្ឋាន របស់ក្រុមប្រឹក្សា ។ សមាជិកម្នាក់ៗ អាចសុំយកទៅថតចម្លងបាន លើកលែងតែមានការជំទាស់ពីប្រធានគណៈមេធាវី ។

**ប្រការ៥** - **ការចាត់តាំង ដោយក្រុមប្រឹក្សាគណៈមេធាវី**

គ្រប់ការប្រជុំដំបូង របស់គណៈមេធាវីជាប់ឆ្នោតថ្មី គណៈមេធាវីនេះ ត្រូវចាត់តាំងអគ្គលេខាធិការម្នាក់ និងអគ្គលេខាធិការរងម្នាក់ អគ្គហិរញ្ញិកម្នាក់ និង អគ្គហិរញ្ញិករងម្នាក់ ។ អ្នកទាំងនេះ ទទួលសិទ្ធិអំណាចពី ប្រធានគណៈមេធាវី ក្នុងការចុះហត្ថលេខា ចំពោះមុខធនាគារបាន ។

## ជំពូកទី ៤

## ជំនួយសង្គ្រោះ តាមផ្លូវតុលាការ

**ប្រការ៦** - **ការចាត់តាំងមេធាវីស្ម័គ្រចិត្ត ដោយប្រធានគណៈមេធាវី**

. ស្របតាមមាត្រា២៨នៃច្បាប់ បេឡាពិសេសមួយបានត្រូវបើកឡើង និងត្រៀមបំរុងសំរាប់ជួយសង្គ្រោះតាមផ្លូវតុលាការ ដល់ជនក្រីក្រ ។

ជនដែលត្រូវបានទទួលនូវជំនួយសង្គ្រោះ តាមផ្លូវតុលាការ ត្រូវធ្វើពាក្យសុំជំនួយ ជូនទៅប្រធានគណៈមេធាវី (គំរូលេខ១) ដោយមានចុះទិដ្ឋាការពីលើពាក្យនោះ អំពីភាពខ្វះខាតធនធានរបស់ជននេះ ពីសំណាក់ប្រធានតុលាការ ឬ ក្រឡាបញ្ជីនាយក ជាមុន ។

ក្នុងកំឡុងពេល១៥ថ្ងៃយ៉ាងយូរបំផុត ប្រធានគណៈមេធាវី ត្រូវចាត់តាំងសហភាតារបស់ខ្លួនម្នាក់ ដែលត្រូវបំពេញ ដោយស្ម័គ្រចិត្ត នូវបទអន្តរាគម ក្នុងក្របខ័ណ្ឌ នៃជំនួយសង្គ្រោះតាមផ្លូវតុលាការ ។

មេធាវីស្ម័គ្រចិត្ត ត្រូវបង្ហាញខ្លួនចំពោះមុខប្រធានគណៈមេធាវី ។

ក្រុមប្រឹក្សាគណៈមេធាវី ត្រូវកំណត់ឲ្យបានច្បាស់ អំពីចំនួនមេធាវីចាំបាច់ សំរាប់ធានានូវការប្រព្រឹត្តទៅឲ្យបានល្អ នៃជំនួយសង្គ្រោះតាមតាមផ្លូវតុលាការនេះ ។

## ប្រការ៧ - អំពីប្រាក់បំណាច់ផ្តាច់ឲ្យមេធាវីស្ម័គ្រចិត្ត

មេធាវីស្ម័គ្រចិត្ត ដែលមកធ្វើការក្នុងរឿងជំនួយសង្គ្រោះតាមផ្លូវតុលាការ នឹងត្រូវបានទទួលប្រាក់បំណាច់ផ្តាច់ប្រចាំខែ ( គិតចូលទាំងសោហ៊ុយផ្សេងៗទាំងឡាយផង ) តាមចំនួនដែលនិងត្រូវកំណត់រៀង-រាល់ឆ្នាំ ដោយក្រុមប្រឹក្សាគណៈមេធាវី ។

មេធាវីចាត់តាំង ត្រូវទទួលបន្ទុកលើសំណុំរឿង ដែលខ្លួនគេត្រូវចាត់តាំងឲ្យបំពេញ ។

ចំនួនទឹកប្រាក់នៃប្រាក់បំណាច់ផ្តាច់នេះ មិនបានគិតទៅតាមចំនួនសំណុំរឿងដែលត្រូវធ្វើឡើយ ។

ដើម្បីបើកប្រាក់បំណាច់ដែលខ្លួនត្រូវបាន មេធាវីសាមីត្រូវប្រគល់របាយការណ៍ការងារ នៅរៀងរាល់ថ្ងៃទី១៥ នៃខែ នីមួយ ៗ ( គំរូលេខ២ ) ដែលបញ្ជាក់អំពីស្ថានភាពជឿនលឿន នៃសំណុំរឿងដែលបានដាក់ចុះឲ្យបំពេញ។

ប្រសិនបើមេធាវីស្ម័គ្រចិត្ត ពុំបានបំពេញកិច្ចការចាំបាច់ តាមដំណើរនីតិវិធីដែលត្រូវប្រព្រឹត្តទៅទេ ប្រធានគណៈមេធាវីអាចនឹងដកឈ្មោះចេញពីបញ្ជីមេធាវីស្ម័គ្រចិត្ត ហើយអាចនឹងចោទប្រកាន់ខាងបទវិន័យដល់មេធាវីនោះផង ។

ក្នុងករណីនេះមេធាវី ត្រូវសងប្រាក់ដែលខ្លួនបានបើកហើយ ដោយមិនត្រឹមត្រូវនោះមកវិញ ។

## ជំពូកទី ៥

## មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## ការចូលបំពេញវិជ្ជាជីវៈ

**ប្រការ៨** - បណ្ឌុមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ទូរស័ព្ទទំនាក់ទំនងលេខៈ..........................................................................................................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានតុលាការកំពូល**

កម្មវត្ថុៈ ស្នើសុំពន្យាពេលដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ។

យោងៈ សំណុំព្រហ្មទណ្ឌលេខ............................ ចុះថ្ងៃទី......... ខែ............ របស់សាលាឧទ្ធរណ៍។

សាលដីកាព្រហ្មទណ្ឌលេខៈ.................... ចុះថ្ងៃទី......... ខែ............ របស់សាលាឧទ្ធរណ៍។

ពាក្យសុំការពារក្តី ចុះថ្ងៃទី........ ខែ............. ឆ្នាំ...........

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន ........................................................................................................................................................................................................................................................................................................................................................................................................................................................................................។

អាស្រ័យហេតុដូចបានជម្រាបខាងលើ សូម............................................................ មេត្តាពិនិត្យ និងសម្រេចតាមពិនិត្យដោយក្តីអនុគ្រោះ។

សូម................................................ ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ............... ខែ...........ឆ្នាំ..............ស័ក ព.ស.២៥........

..........................,ថ្ងៃទី............ ខែ............ឆ្នាំ............

**ហត្ថលេខា និងត្រា**

**ស្នាមមេដៃស្តាំ**

**ឧបសម្ព័ន្ធទី២០**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងសាទុក្ខ

ខ្ញុំបាទឈ្មោះ.................................... ភេទ............ ជនជាតិ............. សញ្ជាតិ............កើតថ្ងៃទី......... ខែ........... ឆ្នាំ............. មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ ផ្លូវលេខ........... ភូមិ............ ឃុំ/សង្កាត់............ ស្រុក/ខណ្ឌ.................. រាជធានី/ខេត្ត.................................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានតុលាការកំពូល**

**កម្មវត្ថុ៖** សុំប្តឹងសាទុក្ខនឹងសាលដីកាលេខ...............................................ចុះថ្ងៃទី.......... ខែ........... ឆ្នាំ.......... របស់សាលាឧទ្ធរណ៍.......................... លើសេចក្តីសម្រេចសាលដីកាទាំងមូល។

**យោង៖** សំណុំរឿងព្រហ្មទណ្ឌលេខៈ..........................................ចុះថ្ងៃទី.......... ខែ............. ឆ្នាំ...........របស់សាលាឧទ្ធរណ៍........................................។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពី..................................................................................................................................................................................................................................................................................................................................................................................................................................................................................។

ហេតុដូចច្នេះហើយ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍................................ បានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ និងមិនមានយុត្តិធម៌ចំពោះរូបខ្ញុំ ដូចនេះខ្ញុំបាទមិនសុខចិត្ត សូមប្តឹងសារទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ.......................... ចុះថ្ងៃទី........... ខែ............ ឆ្នាំ............. របស់សាលាឧទ្ធរណ៍...................... លើសេចក្តីសម្រេចនៃសាលដីកាទាំងមូល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចទទួលពាក្យបណ្តឹងសារទុក្ខរបស់ខ្ញុំបាទ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**បានឃើញ និងបញ្ជាក់ថា** **ស្នាមមេដៃស្តាំ**

ពិតជាស្នាមមេដៃរបស់ឈ្មោះ............. ពិតប្រាកដមែន។

ថ្ងៃ............... ខែ........ ឆ្នាំ...... ....ស័ក ព.ស.២៥.........

....................,ថ្ងៃ........... ខែ.............. ឆ្នាំ.................

**ហត្ថលេខា និង ត្រា**

**មេធាវី** ........................................................

**ឧបសម្ព័ន្ធទី២១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំឈប់ការពារក្តី

ខ្ញុំបាទមេធាវី ....................................... ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខៈ .................... ដែលមានការិយាល័យនៅអាគារលេខ..................ផ្លូវលេខ................ ភូមិ.................. សង្កាត់ .................. ខណ្ឌ................. រាជធានីភ្នំពេញ និងជាមេធាវីការពារសិទ្ធិឈ្មោះ.........................ក្នុងសំណុំរឿងព្រហ្មទណ្ឌ.............ចុះថ្ងៃទី........... ខែ............ ឆ្នាំ............ របស់សាលាដំបូង..............................................។

ទូរស័ព្ទទំនាក់ទំនង...............................................................................................................។

**សូមគោរពជូន**

**ឯកឧត្តមប្រធាន នៃសាលាដំបូង**..........................................................

**កម្មវត្ថុៈ**សុំឈប់ការពារក្តីឲ្យឈ្មោះ.........................................................................................។

សំណុំរឿង......................................................... ចុះថ្ងៃទី............ ខែ............. ឆ្នាំ.............. របស់សាលាដំបូង.....................................................................................................។

**យោងៈ**លិខិតសុំពឹងពាក់មេធាវី ចុះថ្ងៃទី.......... ខែ........... ឆ្នាំ......... របស់ឈ្មោះ.......................................។

ពាក្យសុំការពារក្តីចុះថ្ងៃទី............. ខែ................. ឆ្នាំ..................

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថាខ្ញុំបាទសុំឈប់តំណាងដោយអាណត្តិឲ្យឈ្មោះ................................នៅក្នុងសំណុំរឿង.........................................ចុះថ្ងៃទី......... ខែ........... ឆ្នាំ............... របស់សាលា..........................................................................................។

សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង អនុញ្ញាតដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ............... ខែ...........ឆ្នាំ.............ស័ក ព.ស.២៥........

...........................,ថ្ងៃទី............ ខែ............ឆ្នាំ............

**ហត្ថលេខា និងត្រា**

# ឧបសម្ព័ន្ធទី៣

# សាលក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ
ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០
-សំណុំរឿងជំនុំជំរះលេខ
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៨ និង០០ នាទី ព្រឹក នៅសាលសវនាការទី៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

### ចៅក្រមជំនុំជម្រះ

-លោក ជាចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខលេខ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

ឈ្មោះ ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ លេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ៖ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

មេធាវីលោក អត្តលេខ និងមេធាវី អត្តលេខ ជាមេធាវីការពារក្តីឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ខ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ )(ង)ដ.ដ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ "យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលវិនិច្ឆ័យសេចក្តីដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២ឆ្នាំ (ពីរឆ្នាំ) តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន៤.០០០.០០០(បួនលាន)រៀល បង់ចូលថវិការរដ្ឋ ពីបទ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា១០៧ និងមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ សងសំណងការខូចខាត និងជម្ងឺចិត្តសរុបចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងឈ្មោះ ។ ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

-បានឃើញ សេចក្តីចម្លងបណ្តឹងទាស់លេខ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ដោយសុំប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំណុចផ្ទះដែលមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណីគប់ និងវាយបំផ្លាញកាំម៉ារ៉ាសុវត្ថិភាពរបស់ជនរងគ្រោះឈ្មោះ និងឈ្មោះ ដែលបំពាក់ជាប់នឹងផ្ទះ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ បណ្តាលឱ្យខូចខាតទាំងស្រុង ដែលករណីនេះផ្តើមចេញពីទំនាស់ នៃការសាងសង់ផ្ទះ ដែលមានព្រំជាប់គ្នា។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្ញុំបាទប្តឹងទាស់នឹងសាលក្រមកំបាំងមុខ ដោយហេតុថា ខ្ញុំបាទពុំបានដឹងពីការកោះហៅរបស់តុលាការនោះទេ ទើបខ្ញុំបាទប្តឹងទាស់ ហើយរឿងហេតុនេះកើតឡើងដោយសាការឈ្លោះគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីរឿងធ្វើផ្ទះ ហើយខ្ញុំបាទមិនឱ្យដើមបណ្តឹងដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្ញុំបាទ ដោយខ្ញុំបាទបានធ្វើកិច្ចសន្យាជាមួយដើមបណ្តឹងទៀត ប៉ុន្តែដើមបណ្តឹងនៅតែដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះខ្ញុំដដែល ធ្វើឱ្យមានជម្លោះនឹងគ្នា ហើយខ្ញុំក៏ទៅកាច់កាំម៉ារ៉ាសុវត្ថិភាពនោះចោលតែម្តង។

## សេចក្តីសន្និដ្ឋានបួងសួងរបស់តំណាងអយ្យការ

តំណាងអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការសម្រេចតាមច្បាប់។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ខ្ញុំបាទសូមឱ្យតុលាការបន្ធូបន្ថយទោស ខ្ញុំបាទដឹងកំហុសហើយ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-ពាក្យបណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ ប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនប្តឹងទាស់នឹងសាលក្រមកំបាំងមុខនេះ ដោយហេតុថា ខ្លួនពុំបានដឹងពីការកោះហៅរបស់តុលាការនោះទេ ទើបខ្លួនប្តឹងទាស់ ហើយរឿងហេតុនេះកើតឡើងដោយសាការឈ្លោះគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីរឿងធ្វើផ្ទះ ហើយខ្លួនមិនឲ្យដើមបណ្តឹងដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្លួន ដោយខ្លួនបានធ្វើកិច្ចសន្យាជាមួយដើមបណ្តឹងទៀត ប៉ុន្តែដើមបណ្តឹងនៅតែដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្លួនដដែល ធ្វើឲ្យមានជម្លោះនឹងគ្នា ហើយខ្លួនក៏ទៅកាច់កាំម៉ារ៉ាសុវត្ថិភាពនោះចោលតែម្តង។ ហេតុដូច្នេះតាមចម្លើយរបស់ជនជាប់ចោទ និងតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឲ្យតុលាការជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៣.អំពើរបស់ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ **ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ទៅលើជនរងគ្រោះឈ្មោះ និងឈ្មោះ ប្រាកដមែន ដោយជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពចូលក្នុងរបងផ្ទះជនរងគ្រោះ យកដុំថ្ម និងឈើជ្រុងទៅវាយកម្ទេចកាំម៉ារ៉ាសុវត្ថិភាពបណ្តាលឲ្យខូចខាត។ ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ បានរំលោភទៅលើមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ តំណាងអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកដដែល និងសុំឲ្យតុលាការសម្រេចតាមច្បាប់ គប្បីតុលាការពិចារណាតាមច្បាប់។

៥-សំដីចុងក្រោយរបស់ជនជាប់ចោទ សុំឲ្យតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៦-ជនជាប់ចោទមានស្មារតី និងសមត្ថភាពទទួលខុសត្រូវអំពីទង្វើរបស់ខ្លួន ដែលខ្លួនបានប្រព្រឹត្ត រួមទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ។

៧-តាមភស្តុតាងជាសត្យានុម័ត បញ្ជាក់ថា: ជនជាប់ចោទពិតជា មានចេតនាពិតប្រាកដ ក្នុងការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃមែន ។

៨-អំពើល្មើសពិតជាធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូ ទ្រព្យសម្បត្តិរបស់អ្នកដទៃ និងរបៀបរៀបរយសង្គម ហើយអំពើនេះវាផ្ទុយនឹងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ ដែលគប្បីតុលាការសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

**ហេតុដូច្នេះសម្រេច**

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

- សាលក្រមព្រហ្មទណ្ឌ លេខ៖ "៣" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២
- សំណុំរឿងព្រហ្មទណ្ឌ លេខ៖ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨
- សំណុំរឿងជំនុំជម្រះ លេខ៖ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ធំ

នាថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក ជាចៅក្រមនៃសាលាដំបូងខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ដែលមាន៖

<u>ជនជាប់ចោទ៖</u>

-ឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ៣ម ឃុំកោះកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល និងមានទីលំនៅបច្ចុប្បន្នរស់នៅភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ មានកូន ០១ នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

- ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៖ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ។

ត្រូវបានបញ្ជូនមកសាលាដំបូងខេត្តកំពង់ធំ តាមដីកាដំណោះស្រាយលេខ៖ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ធំ ដើម្បីជំនុំជម្រះពីបទ៖ **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ ... ចន្លោះគីឡូម៉ែត្រ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

<u>មេធាវី៖</u>

-លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ។

## ១. អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ

យោងតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បានបង្ហាញនូវអង្គហេតុ ដូចតទៅ៖ កាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង១៤ និង៣៤នាទី នៅលើកំណាត់ផ្លូវជាតិលេខ៦ ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ស្ថិតត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានករណី គ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង រវាងរថយន្តដឹកអ្នកដំណើរធុនធំ ម៉ាក ហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ផ្លាកលេខ ភ្នំពេញ របស់ក្រុមហ៊ុន និងរថយន្តម៉ាក BONGO III ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ ។ មុនពេលកើតហេតុមានរថយន្តដឹកអ្នកដំណើរធុនធំ ម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ផ្លាកលេខ ភ្នំពេញ របស់ក្រុមហ៊ុន ពិភសរស្មី បើកបរដោយឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ រស់នៅភូមិអំពិលលើ ឃុំអំពិលក្រោម ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានដឹកអ្នកដំណើរជនជាតិចិនច្រើននាក់ ធ្វើដំណើរពីភ្នំពេញ ទៅសៀមរាប លុះមកដល់ចំណតឈប់សម្រាកព្រៃប្រស់ ហើយរថយន្តបានស៊ីញ៉ូភ្លើង ដោយបត់ឆ្លងកាត់ទ្រូងផ្លូវពីស្ដាំទៅឆ្វេង ដើម្បីចូលហាងអាហារស្រាប់តែមានរថយន្តមួយគ្រឿង ម៉ាក Bongo III ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ បើកបរដោយឈ្មោះ រស់នៅភូមិថ្មគោល ឃុំព្រៃតី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង និងមានអ្នករួមដំណើរជាមួយឈ្មោះ បានបើកបរក្នុងល្បឿនលឿន (ទិសដៅពីខេត្តសៀមរាបទៅភ្នំពេញ) មកបុករថយន្តដឹកអ្នកដំណើរធុនធំ ម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ចំចំហៀងខាងស្ដាំពេញទំហឹង បណ្ដាលឱ្យរថយន្តខ្ទាតចេញពីគ្នា នៅក្នុងរថយន្តដឹកអ្នកដំណើរមានជនជាតិចិន របួសស្រាល ០៦នាក់ ឈ្មោះ និងព្រូឡានឈ្មោះ ក៏មានរបួសទាំងពីរអ្នកផងដែរ ។ ពេលនោះរថយន្តសង្គ្រោះពេទ្យដឹកអ្នករបួសទៅគ្លីនិច ហើយសមត្ថកិច្ចបានធ្វើការឃាត់ដកហូតវត្ថុតាងលើមករក្សាទុកនៅស្នាក់ការអធិការដ្ឋាននគរបាលស្រុកកំពង់ស្វាយជាបណ្ដោះអាសន្ន ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ៖ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាដំណោះស្រាយ លេខ៖ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះ លេខ៖ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ ។

-បានឃើញ ដីកាសម្រេចប្រគល់វត្ថុចាប់យក លេខ៖ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ។

## ២. ពេលសវនាការ

**- តាមអំណានចម្លើយជនជាប់ចោទឈ្មោះ** ក្នុងដំណាក់កាលអយ្យការ នៅពេលសវនាការថា៖ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ ខ្លួនបានបើករថយន្តជាមួយព្រូ ចេញពីខេត្តសៀមរាបទៅភ្នំពេញ ដើម្បីទៅដឹកឥវ៉ាន់ក្នុងល្បឿនពី ៧០-៨០ គីឡូម៉ែត្រក្នុង០១ម៉ោង មកដល់ចំណុចគីឡូម៉ែត្រ១៨៣-១៨៤ ភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ម៉ោង ១៤៖៣៤នាទី ក៏ឃើញមានរថយន្តក្រុងម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ស្លាកលេខភ្នំពេញ បានឈប់ត្រឹងនៅកណ្ដាលថ្នល់ផ្នែកខាងស្ដាំដៃរបស់គាត់មិន បើកភ្លើងសញ្ញាបត់ឆ្វេង ពេលនោះខ្លួនរក្សាល្បឿនពី៧០-៨០ គីឡូម៉ែត្រដដែល រំពេចនោះរថយន្តនោះក៏បានបត់ឆ្វេង ទើបធ្វើឱ្យខ្លួនមិនអាចគេចផុតក៏បុកត្រូវពាក់កណ្ដាលរថយន្តក្រុងតែម្ដង ហើយខ្លួន និងព្រូឡាន ត្រូវ

របួសធ្ងន់ ។ មូលហេតុដែលខ្លួនឃើញឡានក្រុងបើកភ្លើងសញ្ញាហើយ ខ្លួនមិនបានបន្ថយល្បឿន ដោយសារតែខ្លួនមើលមិនឃើញឡានរបស់គាត់អែបក្បាលឡានមកខាងឆ្វេងនោះទេ ហើយគាត់បត់ឡានមុខឡានរបស់ខ្លួនគឺមានចំងាយប្រហែល២០ទៅ៣០ ម៉ែត្រតែប៉ុណ្ណោះ ទើបខ្លួនស្មានថាគាត់មិនបត់ឡានទេ ដូច្នេះហើយទើបខ្លួនជាន់ឡានបន្ថែមល្បឿនទៅ សូមបញ្ជាក់ថាខ្លួនមានប័ណ្ណបើកបរត្រឹមត្រូវ គឺប័ណ្ណប្រភេទខ ហើយឡានរបស់ខ្លួនគឺស្តង់ដារ ១.៥តោន ហើយកន្លងមកខ្លួនធ្លាប់តែបើកឡានតូច តែក្រោយមកចូលធ្វើការនៅក្រុមហ៊ុនដឹងជញ្ជូនអស់រយៈពេលប្រហែលកន្លះឆ្នាំ គឺខ្លួនបើកឡានធំប្រភេទដឹកទំនិញនេះរហូត ។

- **តាមអំណានចម្លើយជនរងគ្រោះឈ្មោះ** **ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅពេលសវនាការថា៖** ខ្លួនជាតំណាងក្រុមហ៊ុនរថយន្តមួយគ្រឿងម៉ាក BONGO III បានប្តឹងសមត្ថកិច្ចអំពីរឿងគ្រោះថ្នាក់ចរាចរណ៍នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ លើផ្លូវជាតិលេខ៦ ចន្លោះគីឡូម៉ែត្រ១៨៣-១៨៤ ស្ថិតត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានរថយន្តដឹងអ្នកដំណើរធុនធំម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ស្លាកលេខភ្នំពេញ របស់ក្រុមហ៊ុនពិភពរស្មី បើកបររថយន្តដោយឈ្មោះ

បានបត់រថយន្តពីស្តាំទៅឆ្វេងឆ្លងកាត់ថ្នល់ខ្វះការប្រុងប្រយ័ត្នបណ្តាលឱ្យរថយន្តមួយគ្រឿងម៉ាក BONGO III គាត់បើកលើផ្លូវគេចមិនរួចបណ្តាលឱ្យបុកតែម្តង ។ ធ្វើឱ្យអ្នកបើកបរ និងព្រូឡាន រងរបួសធ្ងន់ធ្ងរទាំងពីរអ្នក និងរថយន្តខូចខាតទាំងស្រុង ខ្លួនសូមទាមទារសំណងជម្ងឺចិត្ត ១០.០០០ មួយម៉ឺនដុល្លារអាមេរិក ។

- **តាមអំណានចម្លើយជនរងគ្រោះឈ្មោះ** **ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅពេលសវនាការថា៖** ខ្លួនជាតំណាងក្រុមហ៊ុនពិភពរស្មី ។ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ លើផ្លូវជាតិលេខ៦ ចន្លោះគីឡូម៉ែត្រ១៨៣-១៨៤ ស្ថិតត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ រថយន្តមួយគ្រឿងម៉ាក BINGO III បើកបរដោយឈ្មោះ បានបុករថយន្តដឹកអ្នកដំណើរធុនធំម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ របស់ក្រុមហ៊ុនពិភពរស្មី បើកបរដោយឈ្មោះ បណ្តាលឱ្យខូចខាតរថយន្តផ្នែកខាងស្តាំមួយចំហៀង និងអ្នកធ្វើដំណើររងរបួស ខ្លួនសូមទាមទារសំណងជម្ងឺចិត្តចំនួន ៣.៥០០ ដុល្លារអាមេរិក ។

- **តាមអំណានចម្លើយសាក្សីឈ្មោះ** **ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅពេលសវនាការថា៖** កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ នៅភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ខ្លួនកំពុងច្រូតស្រូវដើម្បីយកទៅលក់ឡានក្រុងហាងចំណតស្ទឹងព្រៃប្រស់ក៏ឃើញមានរថយន្តក្រុងម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ស្លាកលេខ ភ្នំពេញ ធ្វើដំណើរពីភ្នំពេញទៅខេត្តសៀមរាប បានស៊ីញ៉ូភ្លើង ឡានដើម្បីបត់ចូលហូបអាហារចំណតព្រៃប្រស់ ស្រាប់តែមានរថយន្តមួយគ្រឿងម៉ាក BONGO III ពណ៌ស ពាក់ស្លាកលេខភ្នំពេញ បើកបរក្នុងល្បឿនលឿនជ្រុលទៅបុករថយន្តក្នុងនោះតែម្តង ។

- **មេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋាន ៖** ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងអំណាចម្លើយរបស់កូនក្តីរបស់ខ្លួន គឺនៅមានចំណុចសង្ស័យច្រើន ដោយភាគីទាំងសងខាងបានបើកខ្ចីខ្ចារ នឹងល្មើសបញ្ញត្តិច្បាប់ដូចគ្នា មួយវិញទៀតនៅក្នុងគ្រប់ដំណាក់កាល គឺអ្នកបើកបរពុំបានចូលឆ្លើយបំភ្លឺនោះទេ គឺមានតែចម្លើយតំណាងដោយក្រុមហ៊ុន ។ ចំពោះអង្គហេតុកើតឡើងនេះ គឺមានការបើកបរធ្វេសប្រហែសទាំងសងខាង ហើយកូនក្តីរបស់ខ្លួន បច្ចុប្បន្ននេះក៏ទទួលរងនៅពិការភាព ដោយសារតែគ្រោះថ្នាក់ចរាចរណ៍នេះផងដែរ ។ ដូច្នេះ ខ្លួនស្នើសុំតុលាការមេត្តា ពិចារណាពាក់ព័ន្ធនឹងសំណុំរឿងគ្រប់ដំណាក់កាល និងស្នើសុំតុលាការមេត្តា ឱ្យកូនក្តីរបស់ខ្លួនរួចផុតបទចោទ ។

- **តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយអំណានចម្លើយរបស់ជនជាប់ចោទ ,អំណានចម្លើយរបស់ជនរងគ្រោះ និងអំណាន

ចម្លើយរបស់សាក្សី ព្រមទាំងពិនិត្យ ភស្តុតាងនានា ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ដូចនេះតំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរ លេខ៖ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដដែល និងស្នើសុំឱ្យកំណត់ការផ្តន្ទាទោសត្រឹមកម្រិតព្យួរទោស ។

**- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ** ៖ មិនបានបង្ហាញខ្លួនក្នុងអង្គសវនាការទេ ដោយគ្មានមូលហេតុ ទោះបីជាតុលាការបានធ្វើការកោះហៅតាមនីតិវិធី។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងអយ្យការ
- ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

## ៣.សំអាងហេតុ

ក. យល់ឃើញថា៖ ផ្អែកតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បានបង្ហាញឲ្យឃើញថា កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង១៤ និង៣៨នាទី ពិតជាមានករណី **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ ពិតប្រាកដមែន ។

ខ. យល់ឃើញថា៖ តាមចម្លើយរបស់ជនជាប់ចោទ ,អំណានចម្លើយរបស់ជនរងគ្រោះ និងអំណានចម្លើយរបស់សាក្សី យល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងអង្គហេតុ ដែលបង្ហាញថាជនជាប់ចោទ ឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ពិតជាបានធ្វើសកម្មភាព **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

គ. យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ដែលធ្វើសកម្មភាពខាងលើ បានស្តែងចេញមកខាងក្រៅនូវជាតុអចេតនា និងជាសកម្មភាពដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយត្រូវបានច្បាប់កំណត់ថា ជាបទល្មើស៖ **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ឃ. យល់ឃើញថា៖ **ជនជាប់ចោទ** មិនបានបង្ហាញខ្លួនក្នុងអង្គសវនាការទេ ដោយគ្មានមូលហេតុ ទោះបីជាតុលាការបានធ្វើការកោះហៅតាមនីតិវិធី តុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

ង. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ គឺជានីតិជន ហើយពុំមានភស្តុតាង ណាមួយបញ្ជាក់ថា ជនជាប់ចោទនេះ មានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងខុសត្រូវ អំពីផលវិបាក តាមផ្លូវច្បាប់ ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន។

ច. យល់ឃើញថា៖ មានកស្តុតាងនានាគ្រប់គ្រាន់ ដើម្បីប្រកាសថា មានពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៤៣ឆ្នាំ ដែលបានប្រព្រឹត្តអំពើដែលជាបទមជ្ឈិម ហើយជនជាប់ចោទនេះ ពិតបានប្រព្រឹត្តអំពើ ដូចដែលបានចោទប្រកាន់ ពីបទ៖ បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ គ្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ឆ. យល់ឃើញថា៖ មេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋាន ដោយស្នើសុំតុលាការមេត្តាជួយឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទផង ។ ចំពោះសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវី គប្បី តុលាការយកមកពិចារណា លើការស្នើសុំនេះ ។

ជ. យល់ឃើញថា៖ តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ ដោយស្នើសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ ដោយកម្រិតត្រឹមព្យួរទោស ។ ចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានភាពជឿជាក់បានថា អំពើរបស់ជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ និងតុលាការ យល់ស្របតាមការប្តឹងសុំនេះ។

ឈ. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ មិនដែលមានប្រវត្តប្រព្រឹត្តបទល្មើសពីមុននោះទេ ហើយជននេះក៏ពុំមានចេតនាក្នុងការប្រព្រឹត្តបទល្មើសផងដែរ ព្រមទាំងស្ថានភាពគ្រួសារមានជីវភាពក្រីក្រ និងពុំមាននៅកាយសម្បទាគ្រប់គ្រាន់ទៀតនោះ ដោយស្របតាមបញ្ញត្តិមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិចារណាលើការព្យួរទោស តាមបញ្ញត្តិ មាត្រា១០៤ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

## ៤.សេចក្តីសម្រេច

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពង់ធំ សម្រេច ៖

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ (ដែលមានសវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ជាប់ចោទពីបទ៖ បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។ ប៉ុន្តែការអនុវត្តទោសនេះ គឺត្រូវព្យួរជម្មតា ។

២- បញ្ឈប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

សាលក្រមនេះ បានធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ និងបានប្រកាសជាសាធារណៈ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ ។

ភាគីដែលច្បាប់ផ្តល់សិទ្ធិឲ្យ អាចប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

បានឃើញ

**ចៅក្រមជំនុំជម្រះ**

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

កំពង់ធំ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ
ាលក្រមព្រហ្មទណ្ឌលេខៈ ២៩(ជ)
ះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៧
ំណុំរឿងព្រហ្មទណ្ឌលេខៈ ២៤១
ះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ
នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧

<u>សមាសភាពជំនុំជម្រះ</u>

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងអយ្យការ</u>

លោកស្រី [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្ត

<u>ក្រឡាបញ្ជីសវនាការ</u>

លោកស្រី [redacted]ាក្រឡាបញ្ជី

<u>មេធាវីការពារជនជាប់ចោទ</u>

លោក [redacted]ជាមេធាវី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ២៤១ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិនិមិត្ត៣ ឃុំនិមិត្ត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ មានទីលំនៅបច្ចុប្បន្ននៅភូមិ៣ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរ កម្មករ។ ឪពុកឈ្មោះ [redacted] រស់- ម្តាយឈ្មោះ [redacted] រស់- ប្រពន្ធឈ្មោះ [redacted] ទោសពីមុន គ្មាន (ក្នុងឃុំ) ។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទៈ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត នៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៤ កថាខណ្ឌ១ ក្រោមខណ្ឌ២ ចំណុច២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិក្រល់ ឃុំគោកបល័ង្ក ស្រុកបារាយ ខេត្តកំពង់ធំ មានទីលំនៅបច្ចុប្បន្ននៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរ កម្មករ។ ឪពុកឈ្មោះ [redacted]រស់ ម្តាយឈ្មោះ [redacted]រស់ នៅលីវ ទោសពីមុន គ្មាន (ក្នុងឃុំ)។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិរលា ឃុំក្រគាត ស្រុកពាក់ង ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្ននៅភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរ កម្មករ។ ឪពុកឈ្មោះ [redacted]រស់ ម្តាយឈ្មោះ [redacted]រស់ នៅលីវ ទោសពីមុន គ្មាន(ក្រៅឃុំ)។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>អង្គហេតុនៃរឿងក្តី:</u>

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១៤ និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារកណ្តាល បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននៅចំណុចមណ្ឌល២ ភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានចាប់យកវត្ថុតាងថ្នាំញៀន ប្រភេទមេតំហ្វេតាមីន(ម៉ាទឹកកក) ចំនួន០៤កូនថង់តូច ស្មើនឹងទម្ងន់ ០.២ក្រាម ទូរស័ព្ទដៃចំនួន០៤គ្រឿង ដបថ្នែសម្រាប់ ប្រើប្រាស់ថ្នាំញៀនចំនួន០១ ដែកកេះចំនួន០៤ និងបំពង់ជ័រមួយចំនួន ព្រមទាំងធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់ មានឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ។ ក្រោយមកបានបញ្ជូនជនសង្ស័យចំនួន០៣នាក់ ខាងលើមកស្នងការដ្ឋាននគរបាល ខេត្តបន្ទាយមានជ័យ ដើម្បីកសាងសំណុំរឿងមកអយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:២០៤ ដកសស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ។
-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៥៥៨ អក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ។
-បានឃើញ ដីកាដំណោះស្រាយលេខ: ៤៧៤៨ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ។
-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៥៧០ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ។

## <u>នាពេលសវនាការ:</u>

-បានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]
-បានស្តាប់អំណានចម្លើយសារភាពរបស់ឈ្មោះ [redacted]
-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ ។
-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារ [illegible]។
-ក្រោយពីបានស្តាប់ ជនជាប់ចោទធ្វើសំដីចុងក្រោយ។
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់សាលាដំបូងខេត្តបន្ទាយមានជ័យ

### យល់ឃើញថា:

១-កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ មានករណីជួញដូរ និងសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយឈ្មោះ [redacted] បានយកថ្នាំញៀនពីឈ្មោ[redacted]បកទៅលក់ឲ្យឈ្មោះ [redacted]និងយកទៅប្រើប្រាស់នៅផ្ទះរបស់ឈ្មោះ [redacted]ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

២-តាមការស្តាប់ចម្លើយរបស់ឈ្មោះ [redacted]ហៅ[redacted]នាពេលសវនាការបានបញ្ជាក់ថា: ខ្លួនប្រើប្រាស់ថ្នាំញៀនជិតកន្លះឆ្នាំហើយ ដោយទិញថ្នាំញៀននៅម្តុំផ្សារយប្រាំ ម្តងចំនួនបីម៉ឺនរៀល។ ខ្លួនមិនបានផ្តល់ទីកន្លែងឲ្យគេប្រើប្រាស់ថ្នាំញៀននោះទេ ព្រោះផ្ទះនោះ គឺខ្លួនបានជួលឲ្យឈ្មោះ[redacted]ក្នុងមួយ ខែ ចំនួនប្រាំរយបាត។ ខ្លួននៅផ្ទះនោះ ដោយខ្លួនទៅចាំយកលុយពីឈ្មោះ[redacted]តែប៉ុណ្ណោះ។ ដំបូងខ្លួនមិនដឹងថាឈ្មោះ [redacted] ជាអ្នកលក់ថ្នាំញៀននោះទេ តែក្រោយមកទើបខ្លួនដឹងថាឈ្មោះនេះ ជាអ្នកលក់ថ្នាំញៀន។

៣-តាមការស្តាប់ចម្លើយរបស់ឈ្មោះ[redacted]ហៅ[redacted]នាពេលសវនាការបានបញ្ជាក់ថា:ខ្លួនប្រើប្រាស់ថ្នាំញៀនបានជិតមួយឆ្នាំហើយ ថ្នាំញៀនដែលខ្លួនប្រើប្រាស់នោះ គឺខ្លួនទិញពីឈ្មោះ[redacted] ហើយគេឲ្យកន្លែងប្រើប្រាស់ថ្នាំញៀនតែម្តង។ ខ្លួនមិនបានលក់ថ្នាំញៀននោះទេ ប៉ុន្តែខ្លួនធ្លាប់កាន់ថ្នាំញៀនឲ្យឈ្មោះ[redacted]ដងដែរ។ ការកាន់ថ្នាំញៀនយកទៅឲ្យគេនេះ គឺខ្លួនមិន ដែលបានកម្រៃជាប្រាក់ឈ្នួលនោះទេ គឺបានតែថ្នាំញៀនសម្រាប់ជក់ប៉ុណ្ណោះ។ ខ្លួនមិនដែលលក់ថ្នាំញៀនឲ្យឈ្មោះ [redacted] ,ឈ្មោះ [redacted] នោះទេ។

៤-តាមការស្តាប់អំណានចម្លើយរបស់ឈ្មោះ [redacted]ានបញ្ជាក់ថា: សមត្ថកិច្ចឃាត់ខ្លួនពេល ខ្លួន និងឈ្មោះ[redacted]ពុងរៀបចំឧបករណ៍សម្រាប់ជក់គ្រឿងញៀន នៅផ្ទះរបស់ឈ្មោះ [redacted] ហៅ [redacted] សម្ភារៈដែលសមត្ថកិច្ចដកហូតបានជារបស់ឈ្មោះ[redacted]ដលជាអ្នកលក់ថ្នាំញៀន។ ឈ្មោះ[redacted]គឺ លក់ថ្នាំញៀននៅនឹងផ្ទះរបស់ឈ្មោះ[redacted]តែម្តង។ ខ្លួនមិនដែលកាន់ថ្នាំញៀនឲ្យអ្នកណានោះទេ។

៥-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៦៧៨៨/១៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ លើសំណាកជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ឈ្មោះមេតំហ្វេតាមីន( Methamphetamine) ដែលមានកម្រិតភាពសុទ្ធ ៧១,៩២% នៃទម្ងន់សរុប ស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

៦-បានឃើញកំណត់ហេតុឆែកឆេរលើខ្លួនបុគ្គលជនសង្ស័យ និងចាប់យកសំភារៈវត្ថុតាងប្រព្រឹត្តបទល្មើស លើឈ្មោះ [redacted] ដែលធ្វើនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារកណ្តាល ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦។

៧-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តអំពើសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននោះទេ។ ចម្លើយនេះតុលាការមិនអាចជឿជាក់បានទេ ព្រោះចម្លើយនេះផ្ទុយពីចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់ចៅក្រមស៊ើបសួរថា ខ្លួនពិតជាបានឲ្យឈ្មោះ [illegible] ប៉ក់ [illegible]

រស់នៅក្នុងផ្ទះរបស់ខ្លួនជាមួយគ្នា ហើយឈ្មោះ [redacted] ក៏ចាប់ផ្តើមលក់ថ្នាំញៀននៅនឹងផ្ទះរបស់ខ្លួនតែម្តងៗ បន្ទាប់មកក៏ឃើញមានអ្នកមកទិញថ្នាំញៀន ហើយជក់នៅនឹងផ្ទះរបស់ខ្លួនតែម្តងៗ ដែលចម្លើយទាំងអស់នេះ ក៏ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា ខ្លួនពិតជាបានប្រើប្រាស់ថ្នាំញៀននៅផ្ទះរបស់ឈ្មោះ [redacted] ពិតប្រាកដមែនៗ ហេតុនេះ ការឆ្លើយបដិសេធរបស់ឈ្មោះ [redacted] ក្នុងពេលសវនាការនេះ តុលាការមិនអាចជឿជាក់បាននោះទេ ព្រោះមិនមានសាក្សី ឬភស្តុតាងណាមួយមកដោះបន្ទុកលើរូបគេនោះទេ ហើយគ្រាន់តែជាការឆ្លើយដោះសារដើម្បី រួចផុតពីការទទួលខុសត្រូវលើអំពើល្មើសរបស់ខ្លួនតែប៉ុណ្ណោះៗ ដោយឡែកចំពោះបទល្មើសប្រើប្រាស់ដោយ ខុសច្បាប់នូវសារធាតុញៀន ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា រូបគេពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដែលចម្លើយនេះតុលាការអាចជឿជាក់បាន ហើយចម្លើយនេះដែរក៏ ស៊ីសង្វាក់ទៅនឹងកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន លើឈ្មោះ [redacted] ដែលបញ្ជាក់ថាមាន វត្តមាននូវសារធាតុញៀនៗ ដូចនេះ តាមអង្គហេតុ និងភស្តុតាងខាងលើ តុលាការជឿជាក់ថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែនៗក៏ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] ត្រូវបានចោទប្រកាន់ពីបទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៦ តែអង្គហេតុនេះដែលបានចោទប្រកាន់កាលនៃការប្រព្រឹត្តបទល្មើស នៅអំឡុង ឆ្នាំ២០១៦ គឺពុំអាចរកឲ្យភស្តុតាង អំពីវត្ថុតាង និងសកម្មភាពដែលស្តែងចេញឡើយ ដូច្នេះពុំមានពិរុទ្ធភាពគ្រប់គ្រាន់អំឡុងពេលប្រព្រឹត្តដូចកាលបរិច្ឆេទខាងលើឡើយ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] បទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៦ <u>ទៅជា</u> បទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៦ វិញៗ

៨-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការនេះ តុលាការអាចជឿជាក់បាន ព្រោះជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដោយខ្លួនធ្លាប់បានកាន់ថ្នាំញៀនឲ្យឈ្មោះ [redacted] ដើម្បីយកទៅលក់ឲ្យគេមែន ដោយបានកម្រៃជាថ្នាំញៀនសម្រាប់ជក់ ហើយខ្លួនក៏ចេះប្រើប្រាស់ថ្នាំញៀនផងដែរ។ ចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ រួមនឹងកំណត់ហេតុឆែកឆេរលើខ្លួនបុគ្គលជនសង្ស័យ និងចាប់យកសម្ភារៈវត្ថុតាងដែលជាវត្ថុបទល្មើស បញ្ជាក់ថាបានដកហូតថ្នាំញៀនប្រភេទម្សៅថ្លាស ចំនួន០៤(បួន)កញ្ចប់ ឈ្មោះ [redacted] វត្ថុតាង ដូចនេះ តាមអង្គហេតុ និងភស្តុតាងខាងលើតុលាការជឿជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស

ដូចការចោទប្រកាន់ប្រាកដមែន។ក៏ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] ត្រូវបានចោទប្រកាន់ពីបទ៖ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៨០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ តែអង្គហេតុនេះដែលបានចោទប្រកាន់ កាលនៃការប្រព្រឹត្តបទល្មើស នៅអំឡុង ឆ្នាំ២០១៦ គឺពុំអាចរកឲ្យភស្តុតាង អំពីវត្ថុតាង និងសកម្មភាពដែលស្តែងចេញឡើយ ដូច្នេះពុំមានពិរុទ្ធភាពគ្រប់គ្រាន់អំឡុងពេលប្រព្រឹត្តដូចកាលបរិច្ឆេទខាងលើឡើយ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទ៖ជួញដូយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៨០ កថាខណ្ឌ៥ កថាខណ្ឌ១ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ទៅជា បទ៖ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៨០ កថាខណ្ឌ៤ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត រ និងប្រើប្រាស់ដោ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ។

៩-តាមការស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted]ាពេលសវនាការនេះតុលាការអាចជឿជាក់បាន ព្រោះជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដោយខ្លួនប្រើប្រាស់ថ្នាំញៀនបានចំនួនពីរដង។ ចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ រួមនឹងកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន លើឈ្មោះ [redacted] បញ្ជាក់ថាមានវត្តមានសារធាតុញៀនដូចនេះ តាមអង្គហេតុ និងភស្តុតាងខាងលើតុលាការជឿជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

១០-អំពើរបស់ជនជាប់ចោទឈ្មោ[redacted]ឈ្មោះ [redacted] ហៅ[redacted]ងឈ្មោះ [redacted] ដែលបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ដែលអំពើនេះធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម ជាពិសេសប៉ះពាល់ដល់សុខភាពផ្លូវកាយផ្លូវចិត្ត ចំពោះយុវជនជាសសរទ្រូងប្រទេសជាតិមួយចំនួនដែលកំពុងតែភ្លើតភ្លើននឹងការញៀនថ្នាំញៀនបែបនេះក្នុងសង្គមបច្ចុប្បន្ន ដូច្នេះ អំពើនេះត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ។

១១-ជនជាប់ចោទឈ្មោះ [redacted] ហា[redacted]ឈ្មោះ [redacted] ហៅ[redacted]ងឈ្មោ[redacted] ឃាត់ ក្នុងនិងក្រោយពេលប្រព្រឹត្តបទល្មើសជននេះមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើល្មើស ដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១៣-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហៅ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ពីបទ៖ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

១៤-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

១៥-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៥-ជនជាប់ចោទឈ្មោះ [redacted] ត្រូវបានព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចោទប្រកាន់ពីបទ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២០៤ ដកសស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។ ដោយយោងតាមមាត្រា ១៣៧(ការចោទប្រកាន់តែមួយ) នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការប្រកាសទោសតែមួយចំពោះជនជាប់ចោទ។

១៦-ជនជាប់ចោទឈ្មោះ [redacted] ហៅ ពៅ ត្រូវបានព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចោទប្រកាន់ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២០៤ ដកសស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦របស់តំណាង អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។ ដោយយោងតាមមាត្រា ១៣៧(ការចោទប្រកាន់តែមួយ) នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការប្រកាសទោសតែមួយចំពោះជនជាប់ចោទ។

១៦-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានថា សុំតម្កល់បទចោទរបស់តំណាងអយ្យការទុកជាបានការទាំងស្រុង និងសុំឲ្យតុលាការតុលាការផ្តន្ទាទោសជនជាប់ចោទរូបនេះទៅតាមច្បាប់ គប្បីតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី ។

១៧-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោ [redacted] និងឈ្មោះ [redacted] ានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីរបស់ខ្លួនធ្លាប់បានប្រព្រឹត្តបទល្មើសតែម្តងប៉ុណ្ណោះ ហេតុនេះខ្លួនស្នើសុំឲ្យតុលាការធ្វើការកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted] ពីបទសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤២ កថាខណ្ឌ១ កថាខណ្ឌ២ និងមាត្រា ៤៥ ទៅបទ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤២ កថាខណ្ឌ១ និងមាត្រា ៤៥ ដោយឡែកឈ្មោ [redacted] ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ ទៅបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ និងសុំឲ្យតុលាការពិចារណាតាមច្បាប់។

១៨-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ហៅ [redacted] នាពេលសវនាការបានទទួលស្គាល់កំហុសដែលបានបានប្រព្រឹត្តសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន គប្បីតុលាការលើកយកការស្នើសុំនេះ មកពិចារណាក្នុងការសម្រេចសេចក្តី ។

## ហេតុដូច្នេះសាលាដំបូងខេត្តបន្ទាយមានជ័យ

## វិនិច្ឆ័យសេចក្តី

I-សម្រេចកែប្រែបទចោទលើឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ពីបទ៖សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ <u>ទៅជា</u> បទ៖ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ។

II-សម្រេចកែប្រែបទចោទលើឈ្មោះ [redacted] ទប្រុស អាយុ២៧ ឆ្នាំពីបទ៖ជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ <u>ទៅជា</u> បទ៖ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ ។

III-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ ពីបទ៖ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

IV-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣(បី)ឆ្នាំ និង០៦(ប្រាំមួយ)ខែ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

V-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣(បី)ខែ ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ តែទោសនេះត្រូវព្យួរធម្មតា ។

VI-រឹបអូសវត្ថុតាងមាន:

-ទូរស័ព្ទម៉ាក ណូគា (model 2690) គ្មានអាវក្រៅ ពណ៌ខ្មៅ ចំនួនមួយគ្រឿង ទូរស័ព្ទម៉ាក ណូគា (model 105) ពណ៌ខៀវ ចំនួនមួយគ្រឿង និងកាបូបលុយពណ៌ខ្មៅ(គ្មានលុយ) ចំនួនមួយ

សាលក្រមនេះប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ សម្រេចសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ឈ្មោះ [redacted] ហៅ ពៅ និងកំបាំងមុខឈ្មោះ [redacted] ផ្លូវប្តឹងឧទ្ធរណ៍ និងទាស់ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥២៤៧
ចុះថ្ងៃទី ៣១-១០-២០១៦
សំណុំរឿងជំនុំជម្រះ
លេខ ៦១២
ចុះថ្ងៃទី ១៦-០១-២០១៧
សាលក្រមព្រហ្មទណ្ឌ
លេខ ៩៦ ក្រ៣ "ឆ"
ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក ដោយមានសមាសភាព ៖

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ៥២៤៧ ចុះថ្ងៃទី ៣១-១០-២០១៦ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរជាងធ្វើពិដាន ទីកន្លែងកំណើត ភូមិអូរអង្រៃ ឃុំអូរអង្រៃ ស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ ទីលំនៅបច្ចុប្បន្ន មិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] រស់-ប្រពន្ធឈ្មោះ [redacted] លែងលះ) មានកូន ០២នាក់ ទោសពីមុនគ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៦៧៧ (ធ) ជ.ឃ.ជ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។ (ម១)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ(ចាត់តាំង)។

ជាប់ចោទពីបទៈ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ [redacted] មានទីលំនៅ ផ្ទះជួល ផ្លូវ២៧១ ក្រុម២ ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៣០នាទី បន្ទាប់ពីខឹងជនរងគ្រោះឈ្មោះ [redacted] អាយុ២២ឆ្នាំ ដែលជាសង្សារថាមានប្រុសច្រើន រួចមកជនសង្ស័យឈ្មោះ [redacted] បានទៅជួលបន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

និងបានណាត់ជនរងគ្រោះឲ្យមកដេកជាមួយ ហើយនៅយប់ថ្ងៃដដែលនោះជនរងគ្រោះក៏បានមកដេកជាមួយជនសង្ស័យ និងបានរួមរ័ក្នាចំនួន ០៣លើក។ បន្ទាប់ពីរួមរ័កគ្នារួចមកជនសង្ស័យបានឈ្លោះប្រកែកគ្នាជាមួយជនរងគ្រោះ ហើយជនសង្ស័យក៏បានធ្វើសកម្មភាពសម្លាប់ជនរងគ្រោះតែម្តង។ ក្រោយពេលសម្លាប់ជនរងគ្រោះរួចជនសង្ស័យឈ្មោះ [redacted] ហៅ ពៅ បានដោះយកខ្សែកប្លាកទីន ០១ខ្សែ កងដៃប្លាកទីនចំនួន ០៣កង និងទូរសព្ទដៃម៉ាក iphon ស៊ិចភ្លើស ចំនួន ០១គ្រឿង របស់ជនរងគ្រោះរួចគេចខ្លួនបាត់។ លុះដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ ជនសង្ស័យត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ក្រោយពេលឃាត់ខ្លួនសមត្ថកិច្ចបានយកទឹកនោមជនសង្ស័យទៅធ្វើតេស្រត៍រកសារធាតុញៀនជាលទ្ធផលបង្ហាញថាមានសារធាតុញៀន ប្រភេទមេតំហ្វេតាមីន។

បានឃើញរបាយការណ៍សំយោគលេខ ១២៣/១៦ រ.ប.ក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣០៧១ អ.យ.ត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាដំណោះស្រាយលេខ ៥៥៨៨ (ធ) ជ.ជ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃ សាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ានឆ្លើយថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរសព្ទណាត់ជាមួយឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៤ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានជួលបន្ទប់ផ្ទះសំណាក់លេខ២០C ដល់ម៉ោង ៥និង៣០នាទី ឈ្មោ[redacted] បានមកដល់ បន្ទាប់មកពួកខ្ញុំបានរួមភេទគ្នា ក្រោយពីរួមភេទគ្នារួច ម៉ោងប្រហែល ៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឲ្យគាត់ឈប់ធ្វើកាជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្អួតខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរសព្ទឆ្លើយឆ្លងនៅចំពោះមុខខ្លួន ដោយពេលនោះខ្លួនខឹងពេកក៏បានសង្រ្គប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែក ដោះខ្សែដៃ និងយកទូរសព្ទរបស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង បន្ទាប់មកដើរចេញពីផ្ទះសំណាក់ហើយហៅម៉ូតូឌុបជិះចេញទៅបាត់តែម្តង (នៅពេលខ្លួនដើរចេញពីផ្ទះសំណាក់មិនបានពាក់ម៉ាសទេ)។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១១ថ្ងៃត្រង់ ក៏មានសមត្ថកិច្ចមកធ្វើការឃាត់ខ្លួនសាកសួរ ហើយខ្លួនក៏ឆ្លើយសារភាពតាមសកម្មភាពដែលខ្ញុំបានប្រព្រឹត្តតែម្តង។ មូលហេតុដែលខ្លួនសម្លាប់ហើយយកខ្សែក និងកងដៃរបស់ជនរងគ្រោះ ព្រោះវាជារបស់ដែលខ្លួនបានធ្វើឲ្យនាង ចំណែកឯទូរសព្ទគឺជារបស់គាត់។ ខ្លួនមិនមែនណាត់ជួបគាត់ដើម្បីប្លន់យកទ្រព្យសម្បត្តិរបស់គាត់នោះទេ។ ខ្លួននិងជនរងគ្រោះស្គាល់គ្នានិងទាក់ទងគ្នាជាសង្សាប្រហែល១ឆ្នាំ ហើយពួកខ្លួនធ្លាប់ណាត់ជួបគ្នាជារឿយៗ ទើបតែលើកចុងក្រោយនេះគាត់ទើបធ្វើឲ្យខ្លួនដឹងថាគាត់មានសង្សាច្រើន ថែមទាំងទូរសព្ទនិយាយជាមួយប្រុសផ្សេងមុខខ្លួនទៀត ខ្លួនខឹងពេកដោយទ្រាំនឹងគាត់បញ្ឈឺមិនបានក៏សម្លាប់គាត់តែម្តង។ នៅមុនពេលសម្លាប់ជនរងគ្រោះខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ តែមុនពេលឃាត់ខ្លួន ខ្លួនបានប្រើប្រាស់ថ្នាំញៀន

ពិតមែន។ ខ្លួនសំណូមពរសុំឲ្យតុលាការសម្រេចទៅតាមច្បាប់ ដោយខ្លួនដឹងអំពីកំហុសរបស់ខ្លួន ហើយស្តាយចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តលើជនរងគ្រោះ។

-តាមអំណានចម្លើយដើមបណ្តឹងឈ្មោ[redacted]នឆ្លើយថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៦និង៣០នាទី ប្អូនស្រីខ្លួន[redacted]ភេទស្រី អាយុ២២ឆ្នាំ មុខរបរបុគ្គលិកខារ៉ាអូខេ ហេងហេង(DN) ស្នាក់នៅផ្ទះជួលលេខ១៦C-១៦D ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានស្រុកកំណើតនៅ ភូមិស្វាយពល ឃុំការ ស្រុកពារាំង ខេត្តព្រៃវែង (ត្រូវជាប្អូនបង្កើតរបស់ខ្លួន) បានចេញពីផ្ទះដោយប្រាប់អ្នកនៅជាមួយថាទៅកក់សក់ រួចក៏ចេញបាត់ទៅ លុះដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៨និង៣០នាទី ខ្លួនបានទទួលដំណឹងតាមរយៈមិត្តភក្រ្តប្អូនស្រីថា ប្អូនស្រីខ្លួនឈ្មោះ[redacted]ត្រូវបានគេសម្លាប់ ឥឡូវសពតម្កល់នៅវត្តស្ទឹងមានជ័យ។ បានដំណឹងនេះខ្លួនក៏ធ្វើដំណើរទៅកាន់វត្តស្ទឹងមានជ័យកន្លែងតម្កល់សពឃើញថា សពនោះពិតជាប្អូនស្រីបង្កើតខ្លួនឈ្មោះ [redacted] ពិតប្រាកដមែន។ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃរបស់ប្អូនស្រីខ្លួនជាប់នឹងខ្លួនមានកងដៃផ្លាកទីនចំនួន ០៣កង , ខ្សែកផ្លាកទីន ០១ខ្សែ ទម្ងន់ប្រហែល ០២ជី , ទូរសព្ទដៃម៉ាក iphon ស៊ិចភ្លើស ០១គ្រឿង ពណ៌ទឹកមាស ប្រើស៊ីមស្មាតលេខ ០៨៧ ៦៧ ៤៧ ៤៧។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]បានឆ្លើយថា ៖ ខ្លួនបានស្គាល់ឈ្[redacted] រយៈពេលមួយឆ្នាំហើយ ពេលធ្វើការជាមួយគាត់នៅខារ៉ាអូអេ ហេងហេង(២) មុំក្បែរប៉ុស្តិ៍នគរបាលផ្សារដេប៉ូ៣។ នៅឆ្នាំ២០១៥ ប្រហែលក្នុងខែ៧ ឆ្នាំ២០១៦ ខ្លួនក៏ឈប់ធ្វើការនៅហេងហេង(២) ហើយទៅធ្វើការនៅឌីយ៉ាម៉ង់វិញ(មុំអូរបែកក្អម)។ [redacted]ាត់មានសង្សារម្នាក់ឈ្មោ[redacted] ភេទប្រុស អាយុប្រហែល ២០ឆ្នាំជាង មានមុខរបរអ្វីពុំដឹងទេ លេខទូរសព្ទមិនស្គាល់ ខ្លួនជួបគាត់នៅផ្ទះជួលរបស់បង [redacted] ជិតខារ៉ាអូខេហេងហេង(២) នាងជួបឈ្មោះ [redacted] ប្រហែល ៣ដង ជួបម្តងៗ មួយភ្លែតៗប៉ុណ្ណោះ ឈ្មោះ[redacted]មានកំពស់ប្រហែល ១,៧០ម៉ែត្រ សក់ស្ពត ច្រមុះស្រួចសម្បុរខ្មៅស្រអែម។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៩និង០០នាទី ខ្លួនបានទូរសព្ទទៅបង[redacted]ខ ០៨៧ ៦៧ ៤៧ ៤៧ ដើម្បីខ្ចីលុយគាត់ ២០$ តែគាត់ថាកំពុងនៅផ្ទះសំណាក់ ចាំគាត់តេមកវិញ ពេលនោះគឺខ្លួនកំពុងនៅខារ៉ាអូខេឌីយ៉ាម៉ង់ អូរបែកក្អម ខ្លួនចាំរហូតដល់ម៉ោង ១០យប់ ថ្ងៃដដែលក៏ទូរសព្ទទៅម្តងទៀតតែពុំចូល រហូតដល់ម៉ោង ១១យប់ តេច្រើនលើកនៅតែពុំចូល។ លុះព្រឹកឡើងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៩និង០០នាទីឈ្មោ[redacted]ភេទស្រី នៅខារ៉ាអូខេជាមួយខ្លួនប្រាប់ថាបង[redacted]ប់ហើយ ត្រូវគេសម្លាប់ លុះព្រឹកឡើងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ខ្លួនក៏ទៅធ្វើបុណ្យគា[redacted]នៅខេត្តព្រៃវែងជាមួយមិត្តភក្រ្ត ០៤នាក់ទៀត។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]នឆ្លើយថា ៖ ខ្លួន និងឈ្មោះ[redacted] បានជួលផ្ទះលេខ១៦C រស់នៅជា[redacted]ក់ រយៈពេលប្រហែល ០៤ខែហើយ ប៉ុន្តែខ្លួនស្គាល់គ្នារយៈពេល ៣ឆ្នាំហើយ។ អ្នកនៅជាមួយគ្នានោះ: ១-ខ្លួនឈ្[redacted]ហៅ លីហ្សា ទូរសព្ទលេខ ០៩៦ ៥៨០ ១២១ ៧ , ២-ឈ្មោះ[redacted]ភេទស្រី អាយុ១៩ឆ្នាំ ទូរសព្ទលេខ ០៩៦ ៥០៨ ៤៤៧ ៦ , ៣-[redacted]ភេទស្រី អាយុប្រហែល ២០ឆ្នាំ ទូរសព្ទលេខ ០១៦ ៥០ ៥៣ ៣៨ , ៤-ឈ្មោ[redacted]ភេទស្រី អាយុប្រហែល ២៨ឆ្នាំ ទូរសព្ទមិនស្គាល់ ទើបមកនៅបានប្រហែល ១អាទិត្យ។ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ២៣រំ២៤ និង ០០នាទី បានមកលេងក្នុងហាងមួយសន្ទុះហើយចេញទៅវិញ លុះម៉ោង ១និង៣០នាទី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ពេលខ្លួនចេញពីកន្លែងធ្វើការមកផ្ទះ ស្រាប់តែឃើ[redacted]ក្នុងផ្ទះជាមួយឈ្មោ[redacted]ក្មួយប្រុសម្នាក់អាយុ ៧ឆ្នាំ និងសង្សា(សព)ឈ្មោះ[redacted] ហើយខ្លួនក៏ចូលដេកនឹងនៅជាមួយគ្នារហូតដល់ម៉ោ១៥ និង៩០នាទី ថ្ងៃខែដដែលទើបខ្លួនចេញទៅកន្លែងធ្វើសក់មុនគេ។ ពេលដែលខ្លួនកំពុងនៅក្នុងបន្ទប់ជាមួយ[redacted]ប់ពី ម៉ោង ១២h

ដល់ម៉ោង១៥h ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ទូរស[redacted] មានមនុស្សប្រុសគេមកប្រហែល ២-៣ដង លើកទី១ ណាត់[redacted]ជួបគ្នាញ៉ាំអីនៅវត្តតំបូកខ្ពស់ តែខ្លួនប្រាប់ [redacted] ថាកុំទៅអីឆ្ងាយណាស់ លើកទី២ គេមកតែ[redacted]អត់លើកទូរសព្ទ លើកទី៣ គេមកម្តងទៀតប្រាប់ទៅជួបពួកម៉ាក់នៅម្តុំក្តាន់ពីរសិនបន្តចទៀតចាជួបគ្នា ដល់ពេល[redacted]ទៅជួបអ្នកដែលទូរសព្ទមកនោះមិនដឹងម៉ោងប៉ុន្មានទេ ព្រោះខ្លួនចេញទៅកន្លែងកក់សក់បាត់ហើយ។ អ្នកដែលគេមកទូរសព្ទ [redacted]:ខ្លួនអត់ស្គាល់លេខទេ ឮតែសម្លេងនិយាយឆ្លើយឆ្លងគឺមនុស្សប្រុស។ លុះម៉ោង២៤ និង០០នាទី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ដោយបាត់ [redacted]មិនមកធ្វើការ ខ្លួនបានទូរសព្ទទៅលេខ ០៨៧ ៦៧ ៨៧ ៨៧ តែគេមិនចូល រហូតដល់ម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ក៏គេមិនចូល លុះម៉ោង១៦ និង០០នាទី ថ្ងៃខែដដែលខ្លួនបើកហ្វេសបុកមើលស្រាប់តែឃើញរូបភាព[redacted]ាប់ដែលគេបង្ហោះ ទើបមានការភ្ញាក់ផ្អើលប្រាប់មិត្តភក្រ្តិតៗគ្នា។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]នឆ្លើយថា ៖ ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់អូយ៉េស លេខ១៧ ផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល៣២ឆ្នាំ ប្រើលេខទូរសព្ទ ០៩៦ ៨៣ ៧៦ ៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ ៨$ បន្ទប់លេខ២០C ជាន់ទី៣ ពេលបង់ប្រាក់រួចភ្ញៀវបានទិញភេសជ្ជៈចំនួន ៤បដ (គោជល់១ដប ទឹកសណ្តែក១ដប បាកាស១កំប៉ុង ទឹកហ្សេនយ៉ា១ដប) ហើយបានឡើងបន្ទប់លេខ២០C ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឲ្យឡើងទៅបន្ទប់លេខ២០C រហូតមកដល់វេលាម៉ោងប្រហែល ១៧និង៥នាទី ភ្ញៀវស្រីម្នាក់មកដល់ក៏សួររកបន្ទប់លេខ២០C ខ្លួនក៏ប្រាប់ឲ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលាម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោះ[redacted]ភេទស្រី អយុ២៨ឆ្នាំ អាយុ២៨ឆ្នាំ ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០C ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែ។ ពេលភ្ញៀវប្រុសចុះចេញពីបន្ទប់លេខ២០C នោះមិនដឹងចុះតាំងពីពេលណាទេ។ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៦និង៥០នាទី ខ្លួនកំពុងតែប្រចាំការនៅកន្លែងទទួលភ្ញៀវ ក៏មានភ្ញៀវដែលនៅបន្ទប់លេខ២០C ជាន់ទី៣ ក្នុងផ្ទះសំណាក់អូយ៉េស ភេទប្រុស (ជនសង្ស័យ)បានទូរសព្ទលើតុ ហើយខ្លួនបានលើក ហើយប្រាប់ខ្លួនថាទិញកាតទូរសព្ទស្មាត ១$១ ចំនួន២សន្លឹក ពេលនោះខ្លួនក៏បានវាយអាយក្មមទៅឈ្មោ[redacted] ភេទប្រុស អាយុ២០ឆ្នាំ ឲ្យមកយកកាតទៅឲ្យភ្ញៀវខាងលើ។ ចំពោះកាតទូរសព្ទ ស្មាត វិន គឺខ្លួនត្រូវបានថៅកែទុកឲ្យលក់ ៥០$ មានប្រភេទស្មាត ១ដុល្លា សែលខាត និងមេតហ្វូន គឺគាត់ទុកឲ្យលក់(ចុចពីម៉ាស៊ីនទុកឲ្យលក់) ហើយលក់អស់ទើបចុចឲ្យខ្ញុំទៀត រីឯលុយគឺគិតតាមកាត ហើយទូទាត់ឲ្យថៅកែ។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថា ៖ កាលពីថ្ងៃទី២៥ ខែ១០ ឆ្នាំ២០១៦ វេលាម៉ោង១១និង៣០នាទី ខ្លួនបានឡើងមកឆែកបន្ទប់លេខ២០C ជាន់ទី៣ ពេលឡើងមកដល់មុខបន្ទប់ឃើញបន្ទប់ជាប់សោររួចបានគោះបន្ទប់ហៅភ្ញៀវខាងក្នុងចំនួន៣ដង តែមិនឃើញភ្ញៀវឆ្លើយតបក៏បានចុះទៅខាងក្រោមយកកូនសោរមកចាក់បន្ទប់លេខ២០C បើកទ្វារ ខ្លួនក៏សួរថាបងថែមម៉ោងឬអត់តែភ្ញៀវដេកដណ្តប់ភួយមិនឆ្លើយ ខ្លួនក៏បានយកដៃទៅអង្រួនជើង ស្រាប់តែឃើញជើងភ្ញៀវត្រជាក់ ពេលនោះនាងខ្ញុំក៏បានហៅអ្នកខាងក្រោមឲ្យជួយពិនិត្យមើល ឃើញភ្ញៀវកំពុងតែដេកស្ដូកមិនកំរើក រួចប្រាប់ទៅម្ចាស់ផ្ទះហើយរាយការណ៍ទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលស្រះចកតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]ានឆ្លើយថា ៖ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦និង៤០នាទី ខ្លួនកំពុងឈរមុខផ្ទះសំណាក់ឃើញមនុស្សម្នាក់ ភេទប្រុស អាយុ

ប្រហែល៣២ឆ្នាំ ស្លៀកពាក់ស៊ីវិល ពាក់អាវសោច់ក្រណាត់ដៃវែងពណ៌ក្រហមក្រឡាការ៉ូ ខោពណ៌ខ្មៅជើងវែង ដើរចូលមកក្នុងផ្ទះសំណាក់ម្នាក់ឯងមកជួបពេ[redacted]ប្រុស (អ្នកគ្រប់គ្រង) រកបន្ទប់ដេក រួចមនុស្សប្រុសនោះដើរឡើងមកបន្ទប់ជាន់ទី៣បាត់រហូត ដល់ម៉ោងប្រហែល ១៧និង០០នាទី ខ្លួនឃើញនារីនោះមកពីទិសខាងកើតផ្ទះសំណាក់ ហើយឈប់មុខផ្ទះសំណាក់ រួចរាប់លុយឲ្យអ្នកឌុបចេញទៅបាត់ ចំណែកនារីនោះក៏ដើរឡើងមកជាន់ទី៣បាត់រហូតដល់ម៉ោង ១៩និង០០នាទី ខ្លួនដល់ម៉ោង ត្រូវឈ្មោះ[redacted]ល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្លួនយាមវិញវេលាម៉ោងប្រហែល១១និង០០នាទី ឈ្មោ[redacted]ទស្រី(អ្នកបោសសម្អាតបន្ទប់) បានប្រាប់ខ្លួនថា បន្ទប់លេខ២០ ជាន់ទី៣ ដែលភ្ញៀវចូលដេកនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (មានស្រីម្នាក់ និងប្រុសម្នាក់) បិទទ្វារហៅមិនមានការឆ្លើយតបក៏ឲ្យខ្ញុំជួយមើល ពេលខ្លួនមើលជាមួយស្រីនាង ឃើញមនុស្សស្រីដេកស្តូកលើពូក ខ្លួនក៏ទៅប្រាប់ម្ចាស់ផ្ទះតែម្តង។តមការចំណាំរបស់ខ្លួនកន្លងមកខ្លួនមិនដែលឃើញបុរសនោះ និងនារីរងគ្រោះចេញចូលផ្ទះសំណាក់នេះទេ(ជាម៉ូយថ្មី)។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦ជាងជិតម៉ោង១៧ ពេលមនុស្សប្រុសនោះទិញកាតបញ្ចូលទឹកប្រាក់ចំនួន១$ ចំនួនពីរសន្លឹកពីពេ[redacted]ន្តែខ្លួនមិនដឹងថាមនុស្សប្រុសនោះចេញពីផ្ទះសំណាក់ពេលណាទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]បានឆ្លើយថា ៖ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្ញុំកំពុងប្រកបអាជីវកម្ម ទិញ-លក់គ្រឿងអលង្ការ យីហោ ចាបមាស តូបលេខ៥0A ផ្សារសាមគ្គី ស្ថិតក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ោងប្រហែល ៩និង០០នាទីព្រឹក មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ បានយកគ្រឿងអលង្ការផ្លាកទីន មានកងដៃចំនួន៣កង និងខ្សែកតូចមួយខ្សែយកមកលក់ ពេលនោះខ្លួនសួរថារបស់ទាំងហ្នឹងទិញពីកន្លែងណាមក ជននោះក៏យកវិក័យបត្រដែលមានយីហោតូបរបស់ខ្លួនមកបង្ហាញ ដោយឃើញវិក័យបត្រនេះខ្ញុំក៏យល់ព្រមទិញហើយបានយកថ្លឹង ដោយកងដៃ៣កងទម្ងន់បួនជីមួយហ៊ុន ចំណែកខ្សែកមានទម្ងន់មួយជីបួនហ៊ុនប៊ី សរុបទាំងអស់ខ្ញុំទិញក្នុងតម្លៃទីផ្សារសរុប ៣៦៥$។ លុះដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ ម៉ោង៩ និង០០នាទីព្រឹក ក្រោយពីខ្លួនដឹងថារបស់ខាងលើពាក់ពន្ធ័ជាវត្ថុតាងនៅអំពើល្មើសច្បាប់ខ្លួនបានសហការណ៍ប្រគល់ឲ្យសមត្ថកិច្ចដើម្បីទុកជាវត្ថុតាង។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា ៖ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១១ថ្ងៃត្រង់ខ្លួនកំពុងនៅហាងលក់ទូរសព្ទ័របស់ឈ្មោះ[redacted]ពលនោះក៏មានមនុស្សចំនួន ០២នាក់ ជិះម៉ូតូម៉ាកហុងដា១២៥ មិនដឹងសេរី បានយកទូរសព្ទ[redacted] iphon ស៊ិចភ្លើសពណ៌ទឹកមាសមកលក់ឲ្យខ្លួនក្នុងតម្លៃ ២១០$ ដោយទូរសព្ទ័នោះមានឆ្នាំងសាក និងកាសគ្រប់គ្រាន់ ទើបនាងខ្ញុំហ៊ានទិញ ក្រោយពីទិញបានហើយខ្លួនក៏បានដាក់ក្នុងទូរសព្ទ័លក់ធម្មតា។ សូមបញ្ជាក់ថា ទូរសព្ទ័នេះខ្ញុំពុំបានដឹងថាពួកគាត់បានមកពីណាទេ។ ទើបមកដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៧និង៣០នាទី ក៏ឃើញមានសមត្ថកិច្ចនាំជនដែលលក់ទូរសព្ទ័ឲ្យខ្លួននោះមកហាងខ្លួន ហើយសមត្ថកិច្ចបានអញ្ជើញខ្លួនមកសួរ ទើបខ្ញុំដឹងថាទូរសព្ទ័នោះពាក់ពន្ធ័នឹងអំពើឃាតុកម្ម ហើយខ្លួនសូមប្រគល់ទូរសព្ទ័នេះជូនសមត្ថកិច្ចវិញដោយស្មគ្រ័ចិត្តមិនតវ៉ាអ្វីទេ។

-តាមអំណានចម្លើយសាក្សីឈ្[redacted]បានឆ្លើយថា ៖ ចំពោះចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅសមត្ថកិច្ច កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ គឺខ្លួនទទួលស្គាល់ដោយមិនមានការកែប្រែទេ។ ខ្លួន និងជនរងគ្រោះ គឺធ្លាប់ទាក់ទងគ្នាជាសង្សាររយៈពេលប្រហែល ០១ឆ្នាំហើយ រីឯជនល្មើសវិញខ្លួនមិនដែលស្គាល់នោះទេ ហើយជនរងគ្រោះក៏មិនដែលប្រាប់ពីព័ត៌មានទាក់ទងនឹងជនល្មើសឲ្យខ្លួនដឹងដែរ។ ថ្ងៃដែលខ្លួនជួបនឹងជនរងគ្រោះចុងក្រោយបំផុត គឺនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ០៤រសៀល ជិតម៉ោង៥រសៀល គឺខ្លួនទៅយកម្ហូបសុវត្ថិភាពនៅផ្ទះរបស់គាត់ជូលហើយក៏បែកគ្នាទៅ។ ថ្ងៃដែលខ្លួនដឹងថាជនរងគ្រោះស្លាប់គឺនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦

ម៉ោងប្រហែល ៥រសៀល តាមរយៈមិត្តភក្តិស្រីរបស់គាត់ឈ្មោះ [redacted] អ្នកទូរសព្ទ័ប្រាប់ខ្លួន។ ខ្លួនបានដឹងតែប៉ុណ្ណឹង ចំពោះរឿងអ្វីផ្សេងទៀតខ្លួនមិនបានដឹងទេ។ [redacted]

**<u>សេចក្តីសន្និដ្ឋានបូកសរុបរបស់តំណាងអយ្យការ</u>**

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ឆ្លងតាមការសួរដេញដោលឃើញថា នៅចំណុច ផ្ទះលេខ២០C ជាន់ទី៣ ផ្ទះសំណាក់យ៉ីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ គឺពិតជាកើតមានអំពើ ឃាតកម្មគិតទុកជាមុន បង្កដោយជនជាប់ចោទឈ្មោះ [redacted] ដែលអំពើនេះបានគិតទុកជាមុន អំពើនេះត្រូវបានបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ជនជាប់ចោទក៏បានសារភាពដែរថា ខ្លួនបានប្រើប្រាស់គ្រឿងញៀនផងដែរ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ទុកជាបានការ និងសុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**<u>សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ</u>**

-លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ យោងតាមការពិភាក្សាដេញដោលឃើញថា កូនក្តីខ្លួនពុំមានទោសពីមុន មានកំរិតវប្បធម៌ទាប និងជាជាងពិដាន ដោយកូនក្តីខ្លួនមានការខឹងជនរងគ្រោះដោយកំហឹង ពុំមែនមានគំរោងសម្លាប់ឡើយ គឺកូនក្តីខ្លួនខឹងភ្លាមក៏ស្ទុះសង្កត់ជនរងគ្រោះ និងច្របាច់ក ក៏បណ្តាលឲ្យជនរងគ្រោះស្លាប់ភ្លាមៗ គឺពុំមានគំរោងពីមុនទេ។ ពេលជនរងគ្រោះស្លាប់ហើយ កូនក្តីខ្លួនក៏ដោះយកសម្ភារៈ ព្រោះសម្ភារៈទាំងនោះជារបស់ដែលកូនក្តីខ្លួនទិញឲ្យជនរងគ្រោះ ហើយកូនក្តីខ្លួនយកទៅគឺដោះដូរ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ដូចនេះខ្លួនសំណូមពរសុំឲ្យក្រុមប្រឹក្សាមេត្តាប្តូរបទចោទប្រកាន់ពីមាត្រា ២០០ ទៅជាមាត្រា ២២៤ វិញ គឺហិង្សាដោយមានមរណៈភាពជនរងគ្រោះ។

**<u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ៣៧ ៖ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបាន ពិនិត្យ ពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

-កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ មានករណី ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កើតឡើងនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យ៉ីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ជានីតិជន និងជាជនមានសមត្ថភាពអាចទទួលខុសត្រូវពីបទព្រហ្មទណ្ឌបាន។

-តាមការអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] បានបញ្ជាក់ថា ៖ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរសព្ទណាត់ជាមួយឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៨ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានជួលបន្ទប់ផ្ទះសំណាក់ លេខ២០C ដល់ម៉ោង ៥និង៣០នាទី [redacted] បានមកដល់ បន្ទាប់មកពួកខ្លួនបានរួមភេទគ្នា ក្រោយពីរួមភេទគ្នារួចម៉ោងប្រហែល ៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឲ្យគាត់ឈប់ធ្វើការជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្អួតខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរសព្ទឆ្លើយឆ្លងនៅចំពោះមុខខ្លួន ពេលនោះខ្លួនខឹងពេកក៏បានសង្គ្រប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែកដោះខ្សែដៃ និងយកទូរសព្ទរបស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង ហើយនៅមុនពេលខ្លួនសម្លាប់ជនរងគ្រោះ ខ្លួនបានព្រមានថាឲ្យឈប់ទាក់ទងជាមួយប្រុសទៀត បើនៅតែធ្វើបែបនេះខ្លួននឹងសម្លាប់ចោល ដែលការសារភាពនេះតុលាការអាចជឿបាន ព្រោះវាស៊ីសង្វាក់នឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់ អូយ៉េស ហើយកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣២ឆ្នាំ ប្រើលេខទូរសព្ទ ០៩៦ ៨៣ ៧៦ ៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ ៨$ បន្ទប់លេខ២០C ជាន់ទី៣ ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឲ្យឡើងទៅបន្ទប់លេខ២០C រហូតមកដល់វេលាម៉ោងប្រហែល ១៧និង០៥នាទី ភ្ញៀវស្រីម្នាក់មកដល់ក៏សួររកបន្ទប់លេខ២០C ខ្លួនក៏ប្រាប់ឲ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលា ម៉ោង១១និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោ[redacted] ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០C ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែមែន។

-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ដែលបានប្រើប្រាស់ថ្នាំញៀននៅមុនពេលសម្លាប់ជនរងគ្រោះ និងគិតថានឹងសម្លាប់ជនរងគ្រោះបើសិនជនរងគ្រោះមានប្រុសក្បត់ខ្លួន ហើយនៅថ្ងៃកើតហេតុជនជាប់ចោទក៏បានច្របាច់កជនរងគ្រោះរហូតស្លាប់ និងដោះយកសម្ភារះជនរងគ្រោះនោះ ត្រូវចាត់ជាអំពើ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-វត្ថុចាប់យករួមមានកៅស៊ូចងសក់ , ពណ៌ខ្មៅចំនួន០៣ , កែវជ័រចំនួន០១និងស្បែកជើងផ្ទាត់ចំនួន០១គូ , ម៉ាសមុខ , កន្សែងពោះគោពណ៌សចំនួន០២ , កន្សែង០១ត្រូវហែកមានប្រឡាក់ឈាម,អាវយឺតមួយពណ៌ស ឆ្នូតពណ៌ខ្មៅ០១ , អាវទ្រនាប់០១ , ខោលីអូ០១ និងកាតទូរស័ព្ទវីងចំនួន០២សន្លឹក,សំបកបាកាស់០១ M150 ១ដប គោជល់០១ដបនិង អាវដៃវែងនិងឆ្នូតក្រហមមួយ គឺជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើស និងជាភស្តុតាងបញ្ជាក់ពីអំពើល្មើសរបស់ជនជាប់ចោទ គប្បីតុលាការរឹបអូសតាមច្បាប់ ។ ចំនែកឯវត្ថុចាប់យក រួមមានកាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌ស ចំនួន០១ , ទូរស័ព្ទដៃ០១គ្រឿងម៉ាកណូគា ពណ៌លឿងនិងខៀវចំនួន០១ , កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ [redacted] ងវិក័យប័ត្រទិញលក់មាសចំនួន០៣សន្លឹក

គឺជាសម្ភារៈរបស់ជនរងគ្រោះនិងជាសម្ភារៈរបស់ជនជាប់ចោទ ហើយពុំមានពាក់ព័ន្ធនឹងអំពើល្មើសឡើយ ដូចនេះតុលាការគប្បីប្រគល់ឲ្យម្ចាស់ដើមវិញ។

-មានពិរុទ្ធភាពលើឈ្មោះ: [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ពីបទឃាតុកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ: [redacted] ពុំបានចូលមកតាំងខ្លួនជាដើមបណ្តឹង និងប្តឹងទាមទារសំណងជម្ងឺចិត្តឡើយ ដូចនេះតុលាការគប្បីទុកសិទ្ធិជូនដើមបណ្តឹងទាមទារសំណងពេលក្រោយតាមច្បាប់។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសឈ្មោះ: [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់ មួយជីវិត ពីបទ: ឃាតុកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌគឺ:

-កៅស៊ូចងសក់ពណ៌ខ្មៅចំនួន០៣ , កែវជ័រចំនួន០១ និងស្បែកជើងផ្ទាត់ចំនួន០១គូ។

-ម៉ាសមុខ , កន្សែងពោះគោពណ៌សចំនួន០២ , កន្សែង០១ ត្រូវហែកមានប្រឡាក់ឈាម។

-អាវរ៉ូបមួយពណ៌ស ឆ្នូតពណ៌ខ្មៅ០១ , អាវទ្រនាប់០១ , ខោលីអូ០១ និងកាតទូរស័ព្ទវីងចំនួន០២សន្លឹក។

-សំបកបាកាស់០១ M150 ១ដប និងគោជល់០១ដប , អាវដៃវែងនិងឆ្នូតក្រហមមួយ។

៣-វត្ថុចាប់យកត្រូវប្រគល់ឲ្យម្ចាស់ដើមវិញគឺ:

-កាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌ស ចំនួន០១។

- ទូរស័ព្ទដៃ០១គ្រឿងម៉ាកណូគា ពណ៌លឿងនិងឌីសចំនួន០១។

-កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ: [redacted] និងវិក័យប័ត្រទិញលក់មាសចំនួន០៣សន្លឹក។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៦-០៣-២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ: [redacted] ហៅ ពៅ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប្រកាសជាសាធារណៈនៅថ្ងៃទី ២៨-០៣-២០១៧ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ត្ថលេខា និងត្រា [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខានិងត្រា [redacted] |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៧

[redacted]

# ឧបសម្ព័ន្ធទី៤

# សាលដីកា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៥៣០
ចុះថ្ងៃទី ១៥ _ ១០ _ ០៩
សាលដីកា
លេខ : ០៥ "ទ្រVI អ"
ចុះថ្ងៃទី ២៧_០១_២០១១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៥៣០ ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០៩ រវាង:

- ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ [redacted] រ) ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនមាន។

មានលោកស្រី [redacted] មេធាវីការពារ។

**<u>ជាប់ចោទពីបទ:</u>** ផ្ដល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤-១០-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៥០. ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]ភេទប្រុស អាយុ ៦០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ ឈ្មោះ[redacted]និងគូកន បានធ្វើកិច្ចសន្យាទិញ និងលក់ដីក្លែងក្លាយ ដោយបានក្លែងស្នាមមេដៃ និងក្លែងដាក់ឈ្មោះ [redacted] ថា បានលក់ដីនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ មកឱ្យខ្លួនឈ្មោះ[redacted]ចយកលិខិតក្លែងនោះទៅប្ដឹងតុលាការក្រុងភ្នំពេញ ដើម្បីឱ្យតុលាការសម្រេចប្រគល់ដីឱ្យខ្លួនធ្វើជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៨ ជ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- ផ្ដន្ទាទោសឈ្មោះ[redacted]ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ដាក់ចូលថវិការដ្ឋ ពីបទ ក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧-០៣-១៩៩៣ និងថ្ងៃទី ១០-០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង ផ្ដន្ទាទោសឈ្មោះ[redacted]ភេទប្រុស អាយុៈ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ពីបទ ផ្ដល់សក្ខីភាពក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤-១០-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សរុបកំណត់ចំនួន ២ឆ្នាំ (ពីរឆ្នាំ) គិតបន្តពីសាលក្រមមុន។

២- បង្គាប់ឱ្យឈ្មោះ[redacted]បង់ពិន័យចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ដាក់ចូលថវិការដ្ឋ ពីបទ ក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧-០៣-១៩៩៣ និងថ្ងៃទី ១០-០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- បដិសេធចោលការសុំចាត់របៀបបង្វិលសំណុំរឿងនេះទៅអយ្យការដើម្បីចោទប្រកាន់លើគូកនរបស់មេធាវីតំណាង និងការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី។

៤- ទុកសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងនៅពេលក្រោយ ។

៥- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]ងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ២៨ ជ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោ[redacted] ( វត្តមាន)

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]មាន)

- លោកស្រី [redacted]ាមេធាវីការពារជនជាប់ចោទ( វត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកដោយតុលាការក្រុងភ្នំពេញដាក់ទោសខ្លួនធ្ងន់ពេក ហើយការទិញដី និងលុយកាក់ទិញដី គឺតាមរយៈឈ្មោះ [redacted]ហើយខ្លួនពុំដែលប្រគល់លុយឱ្យទៅម្ចាស់ដីផ្ទាល់ទេ ។ សំណូមពរ សុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: សំណូមពរ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

លោកស្រី[redacted] ជាមេធាវីការពារជនជាប់ចោទធ្វើការការពារថា: សំណូមពរ សុំឱ្យក្រុមប្រឹក្សាមេត្តាពិចារណាស្រួបទោសឱ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

- ក្រោយពីបានស្តាប់អំណាចចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

- ក្រោយពីបានពិនិត្យពិភាក្សានិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍មានសមត្ថកិច្ចទទួលជំនុំជម្រះបាន យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ក្នុងឆ្នាំ១៩៩៣ ខ្លួនបានទិញដី ១កន្លែង ដោយក្លែងស្នាមមេដៃ និងដាក់ឈ្មោះ [redacted] ហើយថា ឈ្មោះ[redacted]បានលក់ដីឱ្យខ្លួន តែតាមការពិតឈ្មោះ [redacted] ក្លែងឯកសារនេះដើម្បីយកឯកសារនេះទៅប្ដឹងសុំតុលាការក្រមពិតុលាការដើម្បីយកដីនេះទៅលក់ឱ្យអ្នកដទៃផ្សេងទៀត ។

៣- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានឆ្លើយថា ខ្លួនមិនដែលបានធ្វើកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្ដាច់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៩៣ រវាងខ្លួន និងឈ្មោះ[redacted] ទេ ដូច្នេះ លិខិតដែលឈ្មោះ[redacted] ធ្វើទាំងប៉ុន្មាននោះ គឺជាបទល្មើសផ្ដល់សក្ខីភាពក្លែងក្លាយ និងក្លែងលិខិតកិច្ចសន្យាទិញ និងលក់ទាំងស្រុង ។

៤- តាមការយល់ឃើញខាងលើមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] ពិតជាបានប្រព្រឹត្តអំពើផ្ដល់សក្ខីភាពក្លែង កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ និងបទ ក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ១៩៩៣ និងថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៥០, ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- រឿងក្ដីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ២៨ ដ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

## ហេតុដូច្នេះ សភាព្រហ្មទណ្ឌ

## វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផុតរយៈពេលច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៨ ដ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣- បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]តាមនីតិវិធីច្បាប់ ។

៤- សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១១ គំចាំងមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ ។

បើកសិទ្ធិឱ្យប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខ[redacted] | ហត្ថលេខ[redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍. ថ្ងៃទី 09 ខែ 02 ឆ្នាំ២០១១
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

11/09/2017

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាស៊ើបសួរ

សំណុំរឿងសភាស៊ើបសួរ

លេខ២៦៦/២៥-៨-២០១៧

សាលដីកា

លេខ ៣២ក្រVIយ

ចុះថ្ងៃទី០៧-៩-២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

សភាស៊ើបសួរបង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/ រកម/០៧-១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកកិច្ចពិភាក្សាដេញដោលជាអសាធារណៈ នៅបន្ទប់សវនាការសាលាឧទ្ធរណ៍នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

កញ្ញា [redacted]

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងសភាស៊ើបសួរលេខ២៦៦ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ រវាង៖

១-ជនត្រូវចោទឈ្មោះ [redacted] ភេទស្រី អាយុ ២៨ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៧ ។មានមេធាវី [redacted]

២-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៥៨ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ន ភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] ស ប្រពន្ធឈ្មោះ [redacted] មានកូន ៦នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៧។ មានមេធាវី [redacted]

៣-ជនត្រូវចោទឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ។(ក្រៅឃុំ)

៤-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ។(ក្រៅឃុំ)

ត្រូវបានតុលាការដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស ៣០ឆ្នាំ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៧៩F ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**អង្គហេតុ**

កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង៩ម៉ោ០០ ព្រឹក អាជ្ញាសាលានៃអយ្យការអមសាលាដំបូងខេត្តកណ្តាល បានដឹកនាំគណកម្មការចំរុះចុះអនុវត្តដីកាសម្រេច បង្គាប់ឲ្យប្រគល់អចលនវត្ថុលេខ ៦៤ អ.វ "គ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តកណ្តាល មានទីតាំងស្ថិតនៅក្នុងភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលបង្គាប់ឲ្យកូនបំណុលឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ប្រគល់ដីនិងផ្ទះ ដែលស្ថិតនៅទីតាំងដីខាងលើទៅឲ្យឈ្មោះ [redacted] ដែលជាអ្នកដេញថ្លៃបាន ។លុះដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ជនត្រូវចោទទាំងបួននាក់ បានកាត់សោរ របងផ្ទះ និងគាស់ទ្វារផ្ទះ ហើយប្រមូលអីវ៉ាន់ចូលទៅរស់នៅលើដីនិងផ្ទះខាងលើវិញតែម្តង។

**បានឃើញ** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៧៣៥ដក.សយខ/១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចដូចខាងក្រោម ៖

ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ជាបណ្តោះអាសន្នរយៈពេលអតិបរិមា..........ខែ។

**បានឃើញ** ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន លេខ ១៩៨១/១៧ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចដូចខាងក្រោម ៖

-មិនអនុញ្ញាតឲ្យឈ្មោះ [redacted] ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ មានទីលំនៅបច្ចុប្បន្ន ភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ដោយសុចរិត និងធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ហើយដែលត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល លេខឃុំខ្លួន ០៨៩០ ជាប់ឃុំខ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៧ នៅក្រៅឃុំបណ្តោះអាសន្នឡើយ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៧ របស់ឈ្មោះ [redacted] មេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៧៣៥ដក.សយខ/១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ស្នើសុំឲ្យសម្រេចជំនួសលោ [redacted] ចៅក្រមស៊ើបសួរសាលាខេត្តកណ្តាល។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧ របស់មេ[redacted] ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ[redacted]ងនឹងដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន លេខ១៩៨១ /១៧ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ក្រង់ចំណុចដីកាសម្រេចទាំងមូល។ ✓

បានឃើញ របាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ចៅក្រមអានរបាយការណ៍.

ជនត្រូវចោទឈ្មោះ[redacted](អវត្តមាន)

ជនត្រូវចោទឈ្មោះ[redacted]អវត្តមាន)

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]អវត្តមាន)

មេធាវី [redacted] និង មេធាវី [redacted]បានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្ញុំបាទជាមេធាវីការពារឲ្យឈ្មោះ[redacted] និង ឈ្មោះ[redacted]ានប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៩៨១/១៧ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ក្រង់ចំណុចដីកាសម្រេចទាំងមូល។កូនក្តីខ្ញុំទាំង២នាក់ ឈ្មោះ[redacted]និង ឈ្មោះ[redacted]បានសុំនៅក្រៅឃុំ មានមូលហេតុដូចតទៅ៖ កូនក្តីខ្ញុំឈ្មោះ[redacted] មានមុខរបរពិតប្រាកដ មានទីលំនៅពិតប្រាកដ ដែលកំពុងមានជំងឺប្រចាំកាយ ចាំបាច់ត្រូវរស់នៅ និង ហូបចុកគ្រប់គ្រាន់ និង បានព្យាបាលជំងឺជាប់ជាប្រចាំ ។ឯកូនក្តីខ្ញុំឈ្មោះ[redacted]ានមុខរបរពិតប្រាកដ មានទីលំនៅពិតប្រាកដ មានកូនតូចៗក្នុងបន្ទុកចំនួន២នាក់ កំពុងនៅបៅដោះ ។សំណូមពរសុំសម្រេចអនុញ្ញាតឲ្យកូនក្តីខ្លួនឈ្មោះ[redacted]ង ឈ្មោះ[redacted]បាននៅក្រៅឃុំ ដើម្បីបាននៅមើលថែទាំកូនតូចៗទាំង២នាក់ និង ព្យាបាលជំងឺ។

**តំណាងមហាអយ្យការសន្និដ្ឋានថា**

យល់ឃើញថា ជនត្រូវចោទទាំងពីរខាងលើ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទល្មើសគឺ ប្រើហិង្សា ទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។ ដូចនេះដើម្បីបញ្ចប់ បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានសារជាថ្មី ពានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីរក្សាជនត្រូវចោទឲ្យនៅក្នុងឃុំ ដូចការសម្រេចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ។សូមសភាស៊ើបសួរពិនិត្យ និង សម្រេចតាមច្បាប់ ។

តាមចំណាររបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងបញ្ជាក់ថា៖ ជនត្រូវចោទ ប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការ បើឲ្យនៅក្រៅឃុំ មិនបានមកបង្ហាញ ខ្លួនដល់តុលាការ និងអាចប្រឆាំង

សេចក្ដីសម្រេចរបស់តុលាការសារជាថ្មី ។

## សភាស៊ើបសួរ យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ របស់លោ[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោ[redacted]ប្ដឹងឧទ្ធរណ៍សុំឲ្យកូនក្ដីខ្លួននៅក្រៅឃុំបណ្ដោះអាសន្ន ធ្វើឡើងត្រឹមត្រូវ តាមមាត្រា ២១៧ និង ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧ របស់លោក[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ[redacted]ប្ដឹងឧទ្ធរណ៍ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ ១៩៨១ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលធ្វើឡើងត្រឹមត្រូវ តាមមាត្រា២៦៧ និង ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-ជនត្រូវចោទឈ្មោះ [redacted]និងឈ្មោះ [redacted]ត្រូវបានតុលាការដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តិនៅ ភូមិព្រែកជ្រៅ ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

៤-ជនត្រូវចោទទាំង ០២រូបមានមេធាវីធានាត្រឹមត្រូវតាមច្បាប់ ព្យសនកម្មមិនមានលក្ខណៈធ្ងន់ធ្ងរទេ ជនត្រូវចោទទាំង០២រូប ត្រូវបានចៅក្រមធ្វើការកត់ត្រាយកចម្លើយរួចហើយ ដូច្នេះការអនុញ្ញាតឲ្យជនត្រូវចោទនៅក្រៅឃុំ មិនមានការបារម្ភថាប៉ះពាល់ដំណើរការស៊ើបសួរឡើយ ដោយគ្រាន់តែដាក់ជំនួសមកវិញ នូវវិធាននៃការត្រួតពិនិត្យតាមផ្លូវតុលាការមួយចំនួន ដូចមានចែងតាមមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌវិញ។

៥-ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំលេខ ១៩៨១ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរ ពុំមានលក្ខណៈត្រឹមត្រូវទេ គប្បីបដិសេធចោល ហើយសម្រេចតាមការយល់ឃើញខាងលើ ។

ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ របស់លោ[redacted]ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ [redacted]ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ [redacted]ទុកជាត្រឹមត្រូវតាមច្បាប់។

៣-បដិសេធដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ ១៩៨១/១៧ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ចោលជាអសារបង់។

៤-ដោះលែងឈ្មោ[redacted]និងឈ្មោះ [redacted]មានសាវតាជាតិដូចខាងលើ) ដែលត្រូវតុលាការដាក់ក្រោមការពិនិត្យពីបទ ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ដោយ...

សុចរិត និងធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកព្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ បទល្មើសដែលមានចែង ឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៩១០ នៃក្រមព្រហ្មទណ្ឌ អោយនៅក្រៅឃុំ។

៥-បង្គាប់ឲ្យលោកប្រធានមន្ទីរឃុំឃាំង ពន្ធនាគារខេត្តកណ្ដាល ដោះលែងឈ្មោះ [redacted] និងឈ្មោះ [redacted] ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួន ពីបទល្មើសអ្វីផ្សេងទៀតទេ។

៦-ដាក់អោយជនត្រូវចោទឈ្មោ [redacted] ងឈ្មោះ [redacted] ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ៖

-មិនត្រូវចូលទៅទីកន្លែងប្រព្រឹត្តបទល្មើស។

-បង្គាប់អោយចូលបង្ហាញខ្លួន១ខែម្ដង នៅរៀងរាល់ថ្ងៃទី០១ នៃខែនីមួយៗ នៅប៉ុស្ដិ៍នគរបាលរដ្ឋបាល ឃុំកោះកោង២។

-មិនត្រូវចាកចេញក្រៅព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា។

-ករណីជនត្រូវចោទមិនអនុវត្តកាតព្វកិច្ច នៃការត្រួតពិនិត្យនេះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបានតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលដីកានេះ ប្រកាសជាអសាធារណៈនៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៧។

ទុកសិទ្ធិអោយប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី**
ហត្ថលេខា
[redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា
[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា
[redacted]

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៧

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]

១០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ៜៜៜៜៜៜៜ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៖ ២៧០/២៦-៤-២០១០

សាលដីកា

លេខ ៖ ០៣ (ឋ) /២២-០៦-២០១០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាកាជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី២២-០៦-២០១០ ដោយមានសមាសភាពដូចខាងក្រោម ៖

**<u>ក្រុមប្រឹក្សាជំនុំជំរះ</u>**

- ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

- លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៧០ ចុះថ្ងៃទី ២៦-០៤-២០១០ រវាង ៖

-ពិរុទ្ធជនឈ្មោះ [redacted] ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរពេទ្យឈ្នួល កើតនៅភូមិពោធិបាក់ក ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ទីលំនៅភូមិកំពង់រទេះ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោ[redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោ[redacted] ហ្វូន មានកូន ០២នាក់ ទោសពីមុន គ្មាន ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ ។ (ប្តឹងឧទ្ធរណ៍)

ត្រូវចោទពីបទ ៖ **ឆបោក** ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី២០០៥ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (តំណាង) ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកមណ្ឌលសុខភាពខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។

**បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២-៣-២០១០ លើចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល។

## ឯរឿងហេតុមានដូចតទៅ ៖

សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

កាលពីអំឡុងឆ្នាំ ២០០០ ជនជាប់ចោទឈ្មោ[redacted] បានធ្វើជាមេតុងទីន ដោយមានសមាជិកតុងទីនជាង ១៨នាក់ គឺក្នុងនោះមានក្បាល ៥០.០០០ រៀល និងក្បាល ១០០.០០០រៀល ហើយសមាជិកតុងទីនដែលឈ្មោ[redacted]ជំពាក់ប្រាក់នោះ គឺមានឈ្មោះ និងចំនួនប្រាក់ដូចខាងក្រោម ៖

១- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល
២- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល
៣- ឈ្មោះ [redacted] ចំនួន ៧.៨៥០.០០០ រៀល
៤- ឈ្មោះ [redacted] ចំនួន ១.៧០០.០០០ រៀល
៥- ឈ្មោះ [redacted] ចំនួន ១.៣០០.០០០ រៀល
៦- ឈ្មោះ [redacted] ចំនួន ១.៦០០.០០០ រៀល
៧- ឈ្មោ[redacted] ចំនួន ២.០០០.០០០ រៀល
៨- ឈ្មោ[redacted] ចំនួន ១.០០០.០០០ រៀល
៩- ឈ្មោះ [redacted] ចំនួន ២.៣០០.០០០ រៀល
១០- ឈ្មោះ [redacted] ចំនួន ៣.០០០.០០០ រៀល
១១- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល
១២- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល
១៣- ឈ្មោះ [redacted] ចំនួន ៦.១០០.០០០ រៀល
១៤- ឈ្មោះ [redacted] ចំនួន ៧.០០០.០០០ រៀល
១៥- ឈ្មោះ [redacted] ចំនួន ៦.៥៥០.០០០ រៀល
១៦- ឈ្មោះ [redacted] ចំនួន ១.០០០.០០០ រៀល
១៧- ឈ្មោ[redacted] ចំនួន ៣.០០០.០០០ រៀល
១៨- ឈ្មោ[redacted] ចំនួន ៧.១០០.០០០ រៀល ។

នៅពេលប្រមូលប្រាក់តុងទីនបានហើយ ជនជាប់ចោទឈ្មោះ [redacted] បានប្រើល្បិចកលភូតកុហកដល់សមាជិកតុងទីនថា សមាជិកនេះ ឬសមាជិកនោះដេញបានបន្តបន្ទាប់ជារៀងរាល់ខែ ហើយលុះដល់ថ្ងៃខែមិនចាំ ឆ្នាំ២០០៤ ជនជាប់ចោទរត់គេចខ្លួនបាត់ ដោយពុំបានធ្វើការទូទាត់ប្រាក់ឲ្យសមាជិកតុងទីនដែលនៅសល់ឡើយ ។

បានឃើញសេចក្តីសំរេចរបស់សាលាដំបូងខេត្តកំពង់ធំ សម្រេចតាមអំណាចសាលក្រមលេខ ២៧-គ ចុះថ្ងៃទី០២-០៣-២០១០ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ កំណត់ដាក់ពន្ធនាគាររយៈពេល ០២ ឆ្នាំ (ពីរឆ្នាំ) ពីបទ៖ **ឆបោក** ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីឆ្នាំ២០០៥ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ ។

២-បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ក្នុងពេលនេះតែម្តង ។

៣-បង្គាប់ឲ្យសងសំណង និងជំងឺចិត្តចំនួន ៦០.៤០០.០០០ រៀល និងជំងឺចិត្តសរុបជាប្រាក់ចំនួន ១៦.៩០០.០០០ រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះ [redacted] សំណូមពរលើសពីនេះត្រូវបដិសេធចោល ដែលក្នុងនោះត្រូវសងទៅ ៖

១- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល និងជំងឺចិត្តចំនួន ៥០០.០០០ រៀល
២- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
៣- ឈ្មោះ [redacted] ចំនួន ៧.៨៥០.០០០ រៀល និងជំងឺចិត្តចំនួន ៣.០០០.០០០រៀល
៤- ឈ្មោះ [redacted] ចំនួន ១.៧០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៥- ឈ្មោះ [redacted] ចំនួន ១.៣០០.០០០ រៀល និងជំងឺចិត្តចំនួន ៥០០.០០០រៀល
៦- ឈ្មោះ [redacted] ចំនួន ១.៦០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៧- ឈ្មោះ [redacted] ចំនួន ២.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៨- ឈ្មោះ [redacted] ចំនួន ១.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៩- ឈ្មោះ [redacted] ចំនួន ២.៣០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
១០- ឈ្មោះ [redacted] ចំនួន ៣.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
១១- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
១២- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
១៣- ឈ្មោះ [redacted] ចំនួន ៦.១០០.០០០ រៀល និងជំងឺចិត្តចំនួន ៣.០០០.០០០រៀល
១៤- ឈ្មោះ [redacted] ចំនួន ៧.០០០.០០០ រៀល និងជំងឺចិត្តចំនួន ២.០០០.០០០រៀល
១៥- ឈ្មោះ [redacted] ចំនួន ៦.៥៥០.០០០ រៀល និងជំងឺចិត្តចំនួន ៣.០០០.០០០រៀល
១៦- ឈ្មោះ [redacted] ចំនួន ១.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
១៧- ឈ្មោះ [redacted] ចំនួន ៣.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
១៨- ឈ្មោះ [redacted] ចំនួន ៧ ១០០.០០០ រៀល និងជំងឺចិត្តចំនួន ២០០.០០០រៀល ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខគូភាគី ។

បើកសិទ្ធិឲ្យប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃផុតកំណត់បណ្តឹងទាស់ ។

**បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១០ របស់ជនជាប់ចោទឈ្មោ[redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២-៣-២០១០ លើចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល។

**បានឃើញ** របាយការណ៍រឿងចុះថ្ងៃទី ០៥-០៥-២០១០ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

**បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ៧-០៥-២០១០ របស់មហាអយ្យការអមតុលាការសាលាឧទ្ធរណ៍ភ្នំពេញ។

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបអង្គហេតុ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]បានឆ្លើយថា ៖ ឈ្មោះ [redacted]ធ្វើជាមេតុងទីន ខ្ញុំសុំសំណងប្រាក់ដើម និងជំងឺចិត្តវិញតាមការសម្រេចរបស់សាលាដំបូង ។

<u>**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖**</u>

-ជនល្មើសឈ្មោះ[redacted] ពិតជាប្រើល្បិចកិច្ចកលយកប្រាក់ជនរងគ្រោះជាច្រើននាក់ ការសម្រេចរបស់តុលាការខេត្តកំពង់ធំ មានលក្ខណៈសមស្របគប្បីតម្កល់សាលក្រម ។

-មេធ[redacted]បានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីខ្ញុំត្រូវបានកូនតុងទីនចំនួន ០៨ នាក់ឆបោក រត់គេចវេសបាត់ កូនក្តីខ្ញុំក៏រងគ្រោះដែរ ចំនួនប្រាក់ដើមសុំទទួលស្គាល់ រីឯសំណងជំងឺចិត្តសុំបន្ថយ និងបន្ថយទណ្ឌកម្មដាក់ពន្ធនាគារ ។ កូនក្តីខ្ញុំទទួលស្គាល់ការជំពាក់ប្រាក់កូនតុងទីន ហើយបានតម្កល់ប្រាក់ធានាចំនួន ៨.០០០.០០០រៀល និងមានដី នឹងផ្ទះមានតំលៃជាង ៣០.០០០ដុល្លាអាមេរិក កូនក្តីខ្ញុំមានទីលំនៅពិតប្រាកដ សុំឲ្យសម្រេចទណ្ឌកម្ម កូនក្តីខ្ញុំជាទោសព្យួរ។

## សាលាឧទ្ធរណ៍

**យល់ឃើញថា ៖**

១. បណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី១៩-៤-២០១០ របស់ពិរុទ្ធជនឈ្មោ[redacted] ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២.មានភស្តុតាងជាចម្លើយសារភាពរបស់ពិរុទ្ធជន ចម្លើយរបស់ដើមបណ្តឹង សាក្សី អាចកំណត់បានថា ពិរុទ្ធជនឈ្មោះ [redacted]នប្រព្រឹត្តអំពើឆបោកយកប្រាក់ចំនួន ៦០.៤០០.០០០រៀល ពីជនរងគ្រោះចំនួន ១៨នាក់ ដូចមានសំអាងហេតុក្នុងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី ០២-០៣-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ប្រាកដមែន សាលាឧទ្ធរណ៍ឯកភាពទាំងស្រុងលើការលើកសំអាងហេតុនៅក្នុងសាលក្រមដោយពុំចាំបាច់សរសេរបញ្ជាក់សារជាថ្មីឡើងវិញទេ។

៣-ជនជាប់ចោទមិនដែលត្រូវបានផ្តន្ទាទោសពីមុនមកទេ ហើយមេធាវីការពារបានសុំឲ្យ សម្រេចទោសព្យួរ ដើម្បីមានឱកាសបានរកស៊ីចិញ្ចឹមជីវិត និងខិតខំប្រឹងប្រែងរកស៊ីយកប្រាក់ សងបំណុលទៅដើមបណ្តឹងវិញ ម្យ៉ាងទៀតពិរុទ្ធជនមានដីផ្ទះ ដែលរស់នៅសព្វថ្ងៃ និងបានបង់ប្រាក់ចំនួន ៨.០០០.០០០ រៀល តម្កល់ទុកនៅនាយកក្រឡាបញ្ជីតាមពាក្យស្នើសុំចុះថ្ងៃទី ១៧-៦-២០១០ និងតាមបង្កាន់ដៃបង់ប្រាក់ ចុះថ្ងៃ

ទី ២១-៦-២០១០ ដើម្បីសុំឲ្យគិតលើស្ថានសំរាលព្យួរទោសដល់កូនក្តីនោះ គប្បីតុលាការ ពិចារណាលើសំណើនេះ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២-០៣-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចទី១ ដែលត្រូវកែប្រែ ដូចមានសំអាងហេតុខាងលើ។

## ហេតុដូច្នេះ

## ខនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី១៩-៤-២០១០ របស់ពិរុទ្ធជនឈ្មោ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២-០៣-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការ លើកលែងតែចំណុចទី១ ត្រូវកែប្រែដូចខាងក្រោម ៖

-ចំណុចទី១នៃសាលក្រមត្រង់ (ដាក់ពន្ធនាគារចំនួន ២ឆ្នាំ) ត្រូវកែប្រែជា (ដាក់ពន្ធនាគារចំនួន ២ឆ្នាំ តែទោសនេះត្រូវអនុវត្តន៍ ៖

-ទោសដាក់ពន្ធនាគារ២ខែ ១៥ថ្ងៃ គិតពីថ្ងៃទី០៩-៤-២០១០

-ទោសនៅសល់ត្រូវព្យួរ (ទោសព្យួរធម្មតា )។ ចំណុចក្រៅពីនោះនៅរក្សាទុកដដែល តាមមាត្រា១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ។

៣-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី១៧-៦-២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២-៦-២០១០ ចំពោះមុខតណាងដើមបណ្តឹងឈ្មោះ [redacted] កំបាំងមុខពិរុទ្ធជនឈ្មោ [redacted]

បើកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងសារទក្ខ តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី........ខែ........ ឆ្នាំ២០១០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]